មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ ព្រាំ យឹម ភេទប្រុស អាយុ៦៣ឆ្នាំ

**មុខងាររជនាន់ខ្មែរក្រហម ៖ យោធា**

**ស្រុកកំណើតនៅភូមិត្រពាំងក្រវ៉ាន់ ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង**

**សព្វថ្ងៃនៅភូមិស្រះជ្រៃ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយ ៖ ឌី ខាំបូលី**

**០២:២២:៣១**

**៧៣ ទំព័រ**

យឹម ៖ វែងឆ្ងាយដែរបើនិយាយពីការតស៊ូនោះ ។

បូលី ៖ បាទ ។

យឹម ៖ តាំងពីមកពីផ្ទះ បើនិយាយទៅតាំងពី៧០-៧១៦ណោះ កាលពីយើងនៅក្មេង គេថាក្មេងឈាមរាវ អាយុ១៧ ១៨ ។

បូលី ៖ អ៊ីចឹងសុំស្គាល់ឈ្មោះពូផង ពូ?

យឹម ៖ ខ្ញុំឈ្មោះ ព្រាំ យឹម ។

បូលី ៖ សព្វថ្ងៃពូអាយុប៉ុន្មានហើយ?

យឹម ៖ ខ្ញុំអាយុ៦៣ ។

បូលី ៖ អ៊ីចឹងពូកើតនៅឆ្នាំណាដែរ?

យឹម ៖ ឆ្នាំ១៩៥២ ៥១ឬ៥២ទេនែក?

បូលី ៖ ៥១ ឬក៏៥០គត់?

យឹម ៖ ៥១

បូលី ៖ ពូកើតជិតឯករាជ្យហើយអ៊ីចឹង?

យឹម ៖ បាទ

បូលី ៖ ពីរឆ្នាំឯករាជ្យ ស្រុកកំណើតពូនៅភូមិ ឃុំអីដែរ?

យឹម ៖ នៅកំពង់ចាម នៅភូមិត្រពាំងក្រវ៉ាន់

បូលី ៖ ត្រពាំងក្រវ៉ាន់?

យឹម ៖ បាទ ត្រពាំងក្រវ៉ាន់ ឃុំព្រៃមូល ស្រុករលាផ្អៀរ ខេត្តកំពង់ឆ្នាំង ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

បូលី  :  ចុះបច្ចុប្បន្ននេះភូមិឃុំអីដែរ?

យឹម  :  អូឥឡូវនៅភូមិស្រះជ្រៃ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

បូលី  :  អីចឹងភូមិនេះយើងហៅភូមិស្រះជ្រៃ?

យឹម  :  បាទ ស្រះជ្រៃ

បូលី  :  មានន័យអីទេពូស្រះជ្រៃនឹងមើលទៅ?

យឹម  :  ស្រះជ្រៃនឹងតាមមើលគេសម្គាល់អាស្រះមួយនេះឯង ។

បូលី  :  អីចឹងស្រះហ្នឹងមែនពូទើបជីកទេ?

យឹម  :  ទេ! ជីកកាលយើងជំនាន់តស៊ូដែរហ្នឹង ជំនាន់តាម៉ុក គាត់ចាប់ផ្តើមកសាងភូមិនៅកន្លែងនេះហ្អាស?

បូលី  :  បាទ!

យឹម  :  គាត់កាយដីនឹងទៅយកទៅធ្វើផ្លូវទៅអន្លង់វែងនោះ អន្លង់វែងកាលនោះមានតែផ្លូវរទេះគោទេ ពីយើងនេះទៅ អាផ្លូវ(មិនច្បាស់)នៅតាមព្រំដែន តាំងពីដើមផ្ទះៗដូចនៅអន្លង់វែង ផ្លូវផ្តៅខាងអូរម៉ៃ គេហៅភូមិបាក់អន្លង់ ភូមិបាក់អន្លង់ នឹងភូមិចាស់ពីមុនមក ។

បូលី  :  អីចឹងពូ?

យឹម  :  បាទ! ភូមិចាស់តាំងពីជំនាន់ដូនតាដែលគាត់នៅតាមព្រំដែននេះណា៎ មិនដឹងតាំងពីជំនាន់ណាមកទេ ខ្ញុំមិនដឹងដែរទេ ។

បូលី  :  គេហៅភូមិបាក់អន្លង់?

យឹម  :  បាទ ភូមិបាក់អន្លង់ ភូមិអន្លង់វែង ពីត្រឹមហ្នឹងមកទៅអន្លង់វែងហ្នឹងទៅ ។

បូលី  :  រួចចុះយើងមិនប្រើឈ្មោះចាស់របស់គេទៅ យើង?

យឹម  :  ពីមុនយើងប្រើតើឈ្មោះហ្នឹង ឃុំបាក់អន្លង់ ។

បូលី  :  ឃុំបាក់អន្លង់?

យឹម  :  បាទ! នៅក្នុងឃុំបាក់អន្លង់ ឥឡូវនេះណាក្នុងស្រុកត្រពាំងប្រាសាទហ្នឹងណា ។

បូលី  :  អីចឹងពីដើមឃុំនេះមិនមែនឃុំត្រពាំងប្រាសាទទេ?

យឹម  :  ឃុំនេះឃុំត្រពាំងប្រាសាទហ្នឹងឯង តែឃុំមួយទៀតដែលមានឈ្មោះភូមិបាក់អន្លង់ ពីដើមមកនោះ ឥឡូវហ្នឹងគេដូរឈ្មោះនឹងមកដាក់ឈ្មោះឃុំបាក់អន្លង់ ស្រុកត្រពាំងប្រាសាទ ខាងកើតអូរម៉ាចនោះណា អាហ្នឹងគេហៅឃុំបាក់អន្លង់ ឈ្មោះភូមិបាក់អន្លង់ពីមុនមក

បូលី ៖ ចុះដែលថាស្រះជ្រៃហ្នឹង ដោយសារតែមានស្រះមួយ ហើយមានដើមជ្រៃអី បានយើងដាក់ស្រះជ្រៃអីចឹង?

យឹម ៖ កាលមុនមានដើមជ្រៃមួយដែរនៅខាងក្រោយស្រះនោះ ឥឡូវវាងាប់បាត់ទៅដើមហ្នឹងនោះ

បូលី ៖ អីចឹងបានចេញជាប្រវត្តិភូមិស្រះជ្រៃនឹងនោះ ។

យឹម ៖ បាទ!

បូលី ៖ អីចឹងពូនៅលើទីតាំងប្រវត្តិសាស្ត្រហើយអីចឹង ។

យឹម ៖ ហើយខ្ញុំក៏អត់ស្គាល់ដែរទេប្រវត្តិត្រពាំងប្រាសាទនេះ កាលហ្នឹងតាម៉ុកគាត់ចុះពីភ្នំមកទៅនៅអន្លង់វែងជុំគ្នាឯនោះ ហើយនៅម្ដុំយើងហ្នឹង ស្រុកត្រពាំងប្រាសាទចាស់ហ្នឹងមានតែបងប្អូនជនជាតិតែប្រហែលជាមួយក្រុមទេ តាម៉ុក គាត់ឲ្យមករៀបចំនៅត្រង់នឹងដើម្បីការពារទឹកនឹងផង ហើយនិងរៀបចំ កាលនឹងគេនៅវ៉ៃគ្នានោះ ប្រហែលជា៩៦-៩៧ អីប៉ុណ្ណឹងឯងកាលនឹងនោះ ក្រោយពីយើងកិច្ចព្រមព្រៀង៩៣មកនឹង តំបន់នឹងត្រូវរៀបចំពីងគេ ដើម្បីរៀបចំភូមិ បង្កើតភូមិនៅកន្លែងនឹងផង សុទ្ធតែព្រៃទេកន្លែងនេះពីមុនមកនោះ ព្រៃសុទ្ធ អន្លង់វែងគេមានភូមិចាស់គេតាំងពីអើយមក កន្លែងនេះគ្មានទេ ហើយត្រពាំងប្រាសាទនេះ ឈ្មោះអាត្រពាំងយើងត្រង់នេះឯង នោះអាត្រពាំងដែលនៅខាងទល់មុខសាលាស្រុកនឹង ។

បូលី ៖ មិនមែនគេយកតាមឈ្មោះអាប្រាសាទបុរាណមួយនៅជិតវត្តនេះទេអីពូ?

យឹម ៖ បាទ!អាប្រាសាទនឹងហើយ អាត្រពាំងហ្នឹងឯង ត្រពាំងដែលតាំង តាមមើលបែបតាំងពីដំនាន់កើតប្រាសសាទនឹងឯង

បូលី ៖ ប្រហែលអីចឹងហើយតាមមើល បានគេដាក់ឈ្មោះត្រពាំងប្រាសាទ?

យឹម ៖ បាទ! បើតាមចាស់ទុំដែលគាត់ដឹងពីប្រវត្តិរឿងប្រាសាទនឹង

បូលី ៖ បាទព្រោះតាំងពីដើមមកយើងមានតែអន្លង់វែង

យឹម ៖ បាទមានតែអន្លង់វែង

បូលី ៖ ត្រពាំងប្រាសាទយើងអត់ដែលមានទេ

យឹម ៖ បាទអត់ដែលមានទេ

បូលី ៖ ចុះឪពុកពូឈ្មោះអីដែរ?

យឹម ៖ នែ៎.. យ៉ាន់

បូលី ៖ អី យ៉ាន់ ទៅ?

យឹម ៖ ព្រាប យ៉ាន់

បូលី : គាត់នៅរស់ទេសព្វថ្ងៃ?

យីម : ស្លាប់ហើយ

បូលី : ស្លាប់តាំងពីណាមក?

យីម : ស្លាប់ឆ្នាំ មិនដឹងជាអាយុប៉ុន្មានទេ ព្រោះកាលហ្នឹងខ្ញុំមិនសូវដែរបានជួបគាត់នោះ ។

បូលី : សម័យណា?

យីម : សម័យយើងរំដោះហើយទេ រំដោះ៧មករានោះណា ។

បូលី : អ្ហូ! ៧មករា អ៊ំ ។ ៧៩ហើយអីចឹង?

យីម : បាទ៧៩ហើយ ។

បូលី : គាត់ខូចនៅស្រុក ឬខូចនៅឯណា?

យីម : កាត់ចេញពីភូមិត្រពាំងក្រញ៉ាន់ចាស់នឹង គាត់មកនៅឯនេះផ្សេងទៀត នៅភូមិព្រះរាមឯនេះ នៅភូមិព្រះរាមថ្មី ជិតត្រង់ហ្នឹងដែរទេ នៅប្រហែលជា២គីឡូពីភូមិ

បូលី : នៅស្រុកត្រពាំងប្រាសាទនឹងដែរ?

យីម : អត់ទេនៅស្រុកកំណើតឯនោះ នៅឯស្រុកកំណើតភូមិឃុំចាស់ឯនោះណា!

បូលី : បាទ!

យីម : នៅត្រពាំងក្រញ៉ាន់ឯណោះ ខ្ញុំមកនេះមកតែឯងទេ ម៉ែឪ នៅផ្ទះទាំងអស់ (សើច)

បូលី : ចុះម្ដាយពូគាត់ឈ្មោះអី?

យីម : ម្ដាយក៏ស្លាប់ដែរ ព្រំ សុទ្ធ ។

បូលី : ពូយកត្រកូលតាមម្ដាយ ឬក៏យ៉ាងម៉េច?

យីម : យកត្រកូលម្ដាយ (សើច) ។

បូលី : ម៉េចបានអីចឹងវិញពូ?

យីម : ខ្ញុំប្ដូរទៅ យកតាមម៉ែខ្ញុំ ។

បូលី : អត់យកតាមត្រកូលឪពុកនេះ?

យីម : បាទ! ព្រោះវាជ្រុលបាត់ទៅហើយ ឲ្យទៅតាមដំណើរទៅ ។

បូលី : ពូមានបងប្អូនប៉ុន្មាននាក់សរុបទៅ?

យីម : បងប្អូនខ្ញុំ ៥នាក់ ។

បូលី : នៅទាំងអស់ឬក៏យ៉ាងម៉េច?

យីម : ស្លាប់អស់ហើយ សល់តែបីទេឥឡូវហ្នឹង នៅស្រុកឯណោះ២ ខ្ញុំឯណេះ១ ។

បូលី ៖ កូនទីមួយពីណាគេ?

យឹម ៖ កូនទីមួយបងខ្ញុំនោះស្លាប់ហើយ ឈ្មោះ យឺន ។

បូលី ៖ ព្រំ យឺន?

យឹម ៖ យឹម យឺន

បូលី ៖ យឹម យឺន វិញ?

យឹម ៖ បាទ!

បូលី ៖ ទីពីរ?

យឹម ៖ ទីពីរឯណោះ នៃ យឹម សឺន ។

បូលី ៖ យឹម សឺន?

យឹម ៖ អូ ខ្ញុំនេះឯង ។

បូលី ៖ ពូ ព្រំ យឹម ទីពីរណោះ?

យឹម ៖ បាទ! បាទ ខ្ញុំនេះឯង ។

បូលី ៖ ទីមួយប្រុសក៏ស្រី?

យឹម ៖ ទីមួយប្រុស ។

បូលី ៖ ចុះទីបី?

យឹម ៖ ទីបី យឹម សឺន ស្លាប់ដែរហើយហ្នឹង ។

បូលី ៖ ស្រីក៏ប្រុសហ្នឹង?

យឹម ៖ ស្រី!

បូលី ៖ គាត់ស្លាប់ពេលណាពូ?

យឹម ៖ ស្លាប់យូរហើយតាំងពីយើង៧៣ឯណោះ តាំងពីយើងនៅតស៊ូជាមួយអាមេរិកឯណោះ យូរហើយ ព្រោះខ្ញុំកាលហ្នឹងវាចូលមករណសិរ្សខ្មែរក្រហមហ្នឹងហើយ បាទ! ចូលតស៊ូតាំងពី៧១ ៧២ ៧៣ បានវាស្លាប់ ។

បូលី ៖ ស្លាប់យ៉ាងម៉េច?

យឹម ៖ ស្លាប់ឈឺខ្យល់គរ ។

បូលី ៖ ចុះទីបួន?

យឹម ៖ ទីបួន ឈ្មោះ យឹម វឹន ស្រី ។

បូលី ៖ នៅរស់?

យឹម ៈ ហ្នឹងនៅរស់ ។

បូលី ៈ រស់នៅឯណា នៅស្រុកកំណើត?

យឹម ៈ នៅស្រុកកំណើតហ្នឹងឯង នៅភូមិរាមឯណោះ អូ! ៦នាក់ឯណោះ មិនមែន៥ទេ ។

បូលី ៈ ប្រាំមួយអ្នកស?

យឹម ៈ បាទ! ស្រី៤ ប្រុស២ ។

បូលី ៈ ទីប្រាំនោះពីណាគេ?

យឹម ៈ ទីប្រាំ យឹម សាវួន ស្លាប់ហើយ

បូលី ៈ ស្រី ឬប្រុស?

យឹម ៈ ស្រី ។

បូលី ៈ ស្លាប់ពេលណាដែលអ៊ំ?

យឹម ៈ ទើបតែស្លាប់ឥឡូវ នែ៎ ឆ្នាំ២០០០ មើលឥឡូវយើងឆ្នាំ២០១៣ហើយណោះ?

បូលី ៈ បាទ ២០១៣ ហើយ ។

យឹម ៈ ស្លាប់២ឆ្នាំ ២០១០ ២០១០នេះឯង ។

បូលី ៈ គាត់ឈឺមែនអ៊ំ?

យឹម ៈ បាទ! គាត់ឈឺ ។

បូលី ៈ ពៅគេឈ្មោះអី?

យឹម ៈ សូវ៉ាត ។

បូលី ៈ សូវ៉ាត គាត់នៅរស់?

យឹម ៈ បាទ! គាត់នៅរស់ ។

បូលី ៈ បាទ! សព្វថ្ងៃគាត់នៅឯណា?

យឹម ៈ ស្រុកនឹងដែរ ។

បូលី ៈ ស្រុកកំណើត?

យឹម ៈ បាទ! នៅរាម ហ្នឹងឯង ។

បូលី ៈ ពូចូល កាលហ្នឹងយើងចូលបដិវត្តន៍នឹងចូលតាំងពីឆ្នាំណាដែរ?

យឹម ៈ ខ្ញុំតាំងពីឆ្នាំ៧០ឯណោះ ។

បូលី ៈ ៧០គត់អ្នកស?

យឹម ៈ បាទ!

បូលី ៈ បានន័យថារដ្ឋប្រហារក្លាមពូចូលភ្លាម?

យឹម ៈ បាទ!

បូលី ៈ ហេតុផលអីបានយើងចូលពេលហ្នឹង?

យឹម ៈ កាលហ្នឹងមិនដឹងហេតុផលអីទេ អត់យល់ពីរឿងអីផង ។

បូលី ៈ ម៉េចបានយើងដឹងថាត្រូវចូលម៉េចអីម៉េចទៅអីចឹង?

យឹម ៈ ឃើញគេទៅគគ្រឹកគគ្រេងចេះតែទៅជាមួយគេទៅ ហើយត្រូវកាលហ្នឹង សម្ដេចតាហ្នឹង គាត់ឃោសនារឿងព្រៃម៉ាក់គីនោះ គេនិយាយថា ចូលព្រៃម៉ាក់គីដើម្បីតស៊ូរំដោះសម្ដេចឪហ្នឹងណា ចំពោះខ្ញុំមានតែប៉ុណ្ណឹង ។

បូលី ៈ អីចឹងកាលដែលចូលតស៊ូហ្នឹងគឺចូលតាមការអំពាវនាវរបស់សម្ដេចឪ ។

យឹម ៈ បាទ!

បូលី ៈ ដែលជួបសម្ដេចឪទេ?

យឹម ៈ មិនដែលជួបផង តែខ្ញុំនៅ កាលនោះនៅក្មេងបានទៅទទួលគាត់ អាយុខ្ញុំវាមើល ១៧-១៨ នឹង គាត់មកសម្ពោធនៅកំពង់ឆ្នាំហ្នឹងបាទ មកសម្ពោធសាលារៀនមួយនៅវត្ត វត្តនៅឯជិតសាលាលេខប្រាំនោះ ខ្ញុំភ្លេចឈ្មោះនឹងទៀតអ្នកស សម្ដេចគាត់មកសម្ពោធនៅនឹងបាទ ទៅទទួលគាត់នៅហ្នឹង ។

បូលី ៈ បានចាប់ដៃទេ?

យឹម ៈ ក្មេងៗ យុវជន អត់បានទេ ព្រោះមនុស្សវាច្រើន ខ្ញុំកាលហ្នឹងវានៅក្រុមយុវន កងជីវពលហាត់កងជីវពល កងអាសាស្មគ្រ័របស់សម្ដេចតាហ្នឹងកាលហ្នឹង ។

បូលី ៈ យ៉ាងម៉េចដែលហៅថាកងអាសាស្មគ្រ័នោះ អត្ថន័យគេយ៉ាងម៉េច?

យឹម ៈ មិនយល់ដែលអាហ្នឹង ។

បូលី ៈ ការពារភូមិឃុំ ឬយ៉ាងម៉េច?

យឹម ៈ ព្រោះកាលហ្នឹងគេត្រូវកំណែយុវជនដែលនៅក្រោម១៨ ទៅហាត់ក្បួន គេហៅថាកងយុវណ្ណករ អាសាស្មគ្រ័ហ្នឹង ។

បូលី ៈ បាទ តែយើងមិនបានដឹងថាតួនាទីរបស់កង?

យឹម ៈ វា គេមិនបានអប់រំយ៉ាងម៉េចផងកាលហ្នឹង យើងដឹងថាទៅហាត់រៀនដើម្បីការពារពេលគ្រែងលោមានប្រទេសជាតិ កើតអាសន្នអីចឹងទៅក៏ ដឹងថាគេទាម ពេលមានចម្បាំង ឬពេលមានបញ្ហាអីចឹងតាមមើលណា ។

បូលី : បាទ! ហើយដែលចូលទៅហ្នឹង ចូលដោយស្ម័គ្រចិត្ត ឬក៏យ៉ាងម៉េច?

យឹម : កាលហ្នឹងភូមិឃុំគេជ្រើសរើសយើងឲ្យចូល ។

បូលី : គេរើសដែរហ្អេស?

យឹម : បាទ! រើសតើ

បូលី : ខាងណាអ្នករើស?

យឹម : មេភូមិ មេឃុំដែលនៅស្រុកកំណើតឯហ្នឹង ។

បូលី : បាទ! ពេលដែលពូចូលហ្នឹងទីរួមខេត្តអន្លង់វែងហ្នឹងស្ថិតក្រោមការគ្រប់គ្រងរបស់ពីណាដែរ?

យឹម : អ៊ូ! អាហ្នឹង អត់ទេ នៅឯនោះ នៅឯត្រពាំងក្រពាំនឯនោះ ។

បូលី : អ៊ូ! សុំទោសនៅទីរួមខេត្តកំពង់ឆ្នាំង?

យឹម : ចាំមើលសិន ខ្ញុំមិនស្គាល់ ភ្លេចឈ្មោះគាត់ទៀតណា ព្រោះវាយូរដែរហើយ ។

បូលី : ចង់និយាយថាស្ថិតក្រោមការគ្រប់គ្រងរបស់ខាង លន់ នល់ ឬក៏ខាងខ្មែរក្រហមពេលហ្នឹង?

យឹម : ពេលហ្នឹងនៅក្រោមការគ្រប់គ្រងរបស់សម្ដេច សីហនុ តើ ជំនាន់រាជា ណែ៎!

បូលី : កំពង់ឆ្នាំហ្នឹង?

យឹម : បាទ! ជំនាន់គ្រប់គ្រងរបស់សម្ដេច សីហនុ កាលហ្នឹងហៅស្អី?

បូលី : សង្គមរាស្ត្រនិយម?

យឹម : បាទ សង្គមរាស្ត្រនិយម ហ្នឹងហើយ ។

បូលី : ខ្ញុំចង់សួរពេលដែលពូចូលបដិវត្តក្រោយរដ្ឋប្រហារហ្នឹងពូ ។

យឹម : ក្រោយរដ្ឋប្រហារឆ្នាំ៧០ហ្អេស?

បូលី : បាទ! កាលហ្នឹងពូចូលទៅហ្នឹងមានគេមកណែនាំ មកជ្រើសរើស ឬក៏បង្ខំ ឬក៏ពូចូលដោយស្ម័គ្រចិត្ត?

យឹម : ចូលព្រៃអ្ហេស?

បូលី : បាទចូលព្រៃ

យឹម : ចូលព្រៃតស៊ូហ្នឹង ចូលដោយស្ម័គ្រចិត្ត ។

បូលី : អត់មានអ្នកណាមកបង្ខំអ្ហេស?

យឹម : បាទ! អត់ទេ ។

បូលី : មានគេមកបញ្ចុះបញ្ចូលទេ ឃោសនាអី?

យឹម  :  មុនហ្នឹងមានមកហ្នឹង មានពួកខ្មែរក្រហមហ្នឹងគេមកហ្នឹង កាលដែលយើង៧០ហើយហ្នឹង ខាងទ័ពខ្មែរក្រហមហ្នឹងគេចូលមកដែរ គេចូលមកតាមភូមិឃុំយើងគេមកឃោសនា គេមកអប់រំពន្យល់ដែលពីរឿងតស៊ូហ្នឹងអ្ហាស ។

បូលី  :  គេឃោសនាថាម៉េចខ្លះ?

យឹម  :  គេឃោសនាកាលហ្នឹងនិយាយពីរឿងចូលព្រៃដើម្បីរំដោះសម្ដេចឪហ្នឹងឯង តាមការអំពាវនាវរបស់សម្ដេចឪហ្នឹង ព្រោះ លន់ នល់ គាត់ធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ហើយ ហើយបើយើងមិនតស៊ូទេយើងមិនអាចការពារ គាត់បានទេ ទាល់តែចូលដើម្បីតស៊ូរំដោះសម្ដេច វាហ្នឹងការឃោសនារបស់គេវាអីចឹងណា៎! ព្រោះហេតុផលអីទៀតខ្ញុំមិនដឹងទេ ព្រោះបើមើលឃើញតែប៉ុណ្ណឹងឯង

បូលី  :  ពេលដែលពូចូលទៅហ្នឹងចូលប៉ុន្មាននាក់?

យឹម  :  ខ្ញុំចូលទៅហ្នឹង ៣-៤នាក់ដែរក្មេងៗជំទង់ៗ ស្របាលៗគ្នាហ្នឹង ហើយវាថែមទាំងទាហានខាង លន់ នល់ គេមកកែនមកចាប់ផង ពួកខ្ញុំហ្នឹងរត់គេចចូលទៅព្រៃទេ ពេលទាហានមកនោះ អត់ហ៊ាននៅផ្ទះទេ

បូលី  :  គេកែនធ្វើទាហានដែរខាង លន់ នល់?

យឹម  :  គេមកកែន គេមកចាប់នោះ មកចាប់ក្មេងៗយុវជននឹងនៅតាមភូមិ ហើយតែមកហើយថាចាប់បោះដាក់ឡានតែម្ដង ចុះកាលហ្នឹងអត់ហ៊ាននៅផ្ទះឯណា ភ័យខ្លាច ។

បូលី  :  ចាប់បោះដាក់លើឡានហ្នុង?

យឹម  :  បាទ! បើយើងមិនទៅវាបន្ទុំចាប់បោះដាក់លើឡានហ្នុងកាលហ្នឹងអ្ហាស!

បូលី  :  អត់ខ្លាចថាយើងក្ដៅក្រហាយ កាន់កាំភ្លើងបានហើយបាញ់តបវិញអី អត់ខ្លាចអីចឹងអ្ហេស?

យឹម  :  បាទ! មិនដឹងគេ បើវាត្រូវកែនប្រជាជនទៅធ្វើសង្គ្រាមអីចឹងទៅហើយ ខ្ញុំមិនបានដល់៧០អីចឹងទេ ខ្ញុំហ្នឹងវាលើ៧០ទៅហើយ ចូលចុងឆ្នាំ៧០ហើយ ចូល៧១ហើយ បាទវាជិតចុងឆ្នាំ៧០ហើយ នៅក្នុងរវង់ខែ វាចុងឆ្នាំ៧០ហើយដែលចូលអ្ហាស ប្រហែលជាចូលខែ១២ ហើយដែលចូលព្រៃនោះ មិនមែនរដ្ឋប្រហារភ្លាមខ្ញុំចូលព្រៃភ្លាមទេ យូរដែរ ។

បូលី  :  ពេលដែលចូលទៅហ្នឹងដំបូងចូលទៅកន្លែងណា?

យឹម  :  ចូលកាលហ្នឹងនៅក្រោយខ្នងភូមិខ្ញុំហ្នឹងគេមានព្រៃ ភូមិខ្ញុំកាលហ្នឹងមានព្រៃច្រើនណាស់ ភូមិចាស់យើងខាងលិចអីចឹងទៅ ទៅខាងក្រោយភូមិខ្ញុំហ្នឹងវាភាគច្រើនគឺសុទ្ធតែព្រៃ តំបន់នោះភាគច្រើនគឺតំបន់របស់ខ្មែរក្រហមហ្នឹងឯង ពួកទាហានទៅមិនសូវដល់ទេ

បូលី ៖ នៅក្នុងស្រុករលាប្អៀរហ្នឹង?

យឹម ៖ បាទ! ចាប់ពីភូមិ និយាយរួមចាប់ពីព្រៃខ្មែរនឹងមក ពីព្រៃខ្មែរ ពីភូមិ អីខ្លះទេ ម្ដុំនោះ ខ្ញុំមិនសូវចាំទេឯនឹង ។

បូលី ៖ ពូរត់ចូលព្រៃហ្នឹងនៅខាងណោះផ្លូវជាតិណោះ?

យឹម ៖ ខ្ញុំនៅឯណោះវិញទេ នៅខាងណោះផ្លូវជាតិ អាផ្លូវទៅរមាសអ្ហាស ខ្ញុំនៅឯណោះ នៅណោះផ្លូវ មកឯខាងលិចវិញទេ ។

បូលី ៖ អ៊ូ! មកខាងណោះ ទៅមួយជំនៀរខាងទឹកផុស ។

យឹម ៖ បាទ មិនដល់ទឹកផុសទេ មកខាងនេះវិញ មកម្ដុំតាំងស្កា មកម្ដុំអាដេញន៉ែ!

បូលី ៖ ស្ដុកកាច់រមាសអី?

យឹម ៖ អត់ទេ! មកម្ដុំជិតនែ មកជិតម្ដុំត្រពាំងធ្លូក ម្ដុំអីខាងនេះវិញ ពង្រ ពង្រទៅលិចកំពង់ឆ្នាំអ្ហាស

បូលី ៖ ពេលដែលចូលទៅជំបូងជួបពីណា? ទៅដល់?

យឹម ៖ កាលនឹងមេឈ្លប មេកងឈ្លបខ្ញុំហ្នឹងគេចូល ទៅជំបូងចូលកងឈ្លបទេ ឈ្លបភូមិ អ្ហា ឈ្លបឃុំ អ្ហាស តែកម្លាំងកាលហ្នឹងគេពង្រាយនៅតាមភូមិរបស់ឈ្លបឃុំគេហ្នឹង គ្នាប្រហែលជា២០ នាក់ទេដែលទើបតែចូល ។

បូលី ៖ គេឲ្យកាន់អាវុធនៅពេលហ្នឹង?

យឹម ៖ នៅទេ! គេគ្រាន់តែឲ្យយើងនៅដើម្បីគេអប់រំរៀនសូត្រអីហ្នឹង តិចតួចៗហ្នឹង ហ្វឹកហាត់ បច្ចេកទេសយោធាអីតិចតួចហ្នឹងអ្ហាស ។

បូលី ៖ ហើយដល់ពេលធ្វើឈ្លបភូមិ ឈ្លបឃុំ ហ្នឹងបានមួយរយៈមកធ្វើអីទៀត គេឲ្យធ្វើអីទៀត?

យឹម ៖ ខ្ញុំ គេឲ្យខ្ញុំធ្វើពេទ្យ ពេទ្យហ្នឹងគ្រាន់តែចាក់ថ្នាំសង្គ្រោះពេលដែលកម្លាំងយើងទៅតស៊ូហ្នឹងរបួស សង្គ្រោះបន្ទាន់អ្ហាស បាទ! លាងចាក់ថ្នាំបាត់ឈាមអីតិចតួចប៉ុណ្ណោះឯង

បូលី ៖ អ៊ូ! ពូមានប្រវត្តិរៀនពេទ្យអីខ្លះបានគេឲ្យពូធ្វើពេទ្យ?

យឹម ៖ ខ្ញុំកាលណោះ កាលនៅផ្ទះនោះខ្ញុំរៀនពេទ្យសត្វ តែវាមិនបានច្រើនអីទេ គ្រាន់តែរៀនចាក់ថ្នាំ ចាក់អីការពារជំងឺមាន់តិចតួចហ្នឹងអ្ហាស ។

បូលី ៖ ដល់តែធ្លាប់ធ្វើពេទ្យសត្វអីចឹងទៅគេឲ្យធ្វើពេទ្យហ្នុងទៅ?

យឹម ៖ បាទគេឲ្យទៅពេទ្យ ហើយទៅពេទ្យហ្នឹង ហឹយយើងវា ពេទ្យកាលហ្នឹងមិនមែនបានរៀនអីណា គេឲ្យយើងចាក់ដាក់ស្តែង

បូលី ៖ គេបង្ហាត់ប៉ុន្មានថ្ងៃប៉ុន្មានខែដែរ បានចាប់ផ្ដើមអនុវត្តន៍?

យឺម ៖ បន្ទាត់ដាក់ស្ពែន កន្លែងតិចៗចឹងទៅណា ។

បូលី ៖ ប្រាប់ភ្លាមចាប់តែម្តង?

យឺម ៖ បាទ! អត់ទេរៀនចាក់ធ្វើកូនខ្មោយហ្នឹង ។

បូលី ៖ គេរៀនចាក់កូនខ្មោយសិន?

យឺម ៖ ចាក់ដុំ ចាក់ដាក់ស្ពែនយ៉ាងម៉េចហ្នឹងគេបន្ទាត់ បង្រៀនយើងតាមវិធីសាស្ត្រអីចឹងទៅណា ។ មុនពេលយើងចាក់ដាក់ស្ពែន នៅពេលមានអ្នករបួសអ្នកអីមកក៏ ចាក់ដាក់ស្ពែនថែមទៀតទៅ ។

បូលី ៖ ដល់ពេលហ្នឹង មានដែលចាក់ខុស ចាក់ច្រលំអីទេចឹង?

យឺម ៖ អត់ដែរ!

បូលី ៖ អត់អីដែរ ។

យឺម ៖ ព្រោះប្រយ័ត្នប្រយែងដែរ យើងនៅនេះក៏មើលដែរហ្នឹង ។

បូលី ៖ ពេទ្យហ្នឹង ពេទ្យនៅណា?

យឺម ៖ នៅកន្លែងអគ្គភាពឆ្លូងហ្នឹងឯង ។

បូលី ៖ អគ្គភាពស្រុករលាប្អៀរហ្នឹងដែរ?

យឺម ៖ បាទ! ពេទ្យឃុំទេ ។ មានសមត្ថភាពតូចតាចទេ រៀនគ្រាន់តែគេសង្គ្រោះ ចេះចាក់ថ្នាំ ចេះរុំរបួសអីបន្តិចបន្តួចហ្នឹងណា ។ គេគ្រាន់តែមានជំនាញច្រើនដូចខ្ញុំ គេពង្រីកកម្លាំងទ័ព ដើម្បីជួយការងារគេហ្នឹង ។ ខ្ញុំដឹបូងគ្រាន់តែបានជួររបួស ពុំទាន់បានចេះចាក់ថ្នាំអីស្ទាត់ជំនាញទេ ។

បូលី ៖ ចុះម៉េចទៀតទៅ ធ្វើអីទៀតទៅ?

យឺម ៖ ចុះមកធ្វើកងទ័ពស្រុក ។

បូលី ៖ កងទ័ពស្រុកហ៎?

យឺម ៖ បាទ! ចេញពីឆ្លូងមក ។

បូលី ៖ ស្រុកអីគេ?

យឺម ៖ ស្រុករលាប្អៀរហ្នឹងហើយ ។

បូលី ៖ ពេលហ្នឹង មិនទាន់បែក៧៥ ទេ?

យឺម ៖ ទេ! បែកហើយ ។ អ៊ូនៅទេ ។

បូលី ៖ នៅទេ?

យឺម ៖ បាទ! នៅទេ ។ តស៊ូតាំងពី៧១,៧២ ហ្នឹងមកដល់៧៥ បានយើងរំដោះ ។

បូលី : ចឹងចន្លោះពី៧១ មក៧៥ហ្នឹងពូ ធ្វើ ឈ្លបឃុំ ធ្វើពេទ្យឃុំ?

យឹម : កងទ័ពស្រុក ។

បូលី : ស្រុកអីគេ?

យឹម : ស្រុក ហើយបានមកកងទ័ពតំបន់ ។

បូលី : ស្រុករលាប្អៀរ?

យឹម : ស្រុករលាប្អៀហ្នឹង ។

បូលី : ពេលណាបានពូមកធ្វើកងទ័ពតំបន់?

យឹម : ទ័ពតំបន់បានចូលមកឆ្នាំ៧៣, ពាក់កណ្ដាលឆ្នាំ៧៣ហ្នឹងមកហើយ ។

បូលី : (ស្ដាប់ពុំបាន) តំបន់ប៉ុន្មាន?

យឹម : តំបន់ គេហៅតំបន់អីគេកាលហ្នឹង តំបន់១០០ប៉ុន្មានទេ កំពង់ឆ្នាំង ។

បូលី : កំពង់ឆ្នាំងយើងភូមិភាគបស្ចឹម?

យឹម : បាទ!ភូមិភាគបស្ចឹម ។ តំបន់ប៉ុន្មានទេ កំពង់ឆ្នាំង!

បូលី : ភូមិភាគបស្ចឹម តំបន់៣១?

យឹម : ហ្នឹងហើយ! ៣១ហ្នឹងដឹង ។

បូលី : ៣១ , ៣២, ៣៧, តំបន់១៥ និងតំបន់១១ ។ ពីណាគេ មេភូមិភាគកាលហ្នឹង?

យឹម : មិនដឹងទេ កាលហ្នឹងនរណាគេមេភូមិនោះ ។

បូលី : ដែលឮសូរឈ្មោះ តាជូ យេតទេ?

យឹម : ឮតែឈ្មោះ មិនដែលឃើញមុខ ។

បូលី : មិនដែលឃើញមុខទេណ៎?

យឹម : បាទ!

បូលី : តំបន់៣១ ឬ៣៧មិនដឹង, នេះបស្ចឹម យើងនៅម្ដុំនេះ ។ កំពង់ឆ្នាំ, បូព៌ា,ឧត្ដរ, នេះបស្ចឹមហ៎ ពូ! បស្ចឹម មានកំពង់ឆ្នាំង ផ្នែកខ្លះនៃខេត្តកំពង់ស្ពឺ អើខេត្តកោះកុង បាទ! ចូលគ្នា ។

យឹម : (និយាយទូរស័ព្ទ) ។

បូលី : អ្ហូ! ចឹងតំបន់៣១ហើយចឹង?

យឹម : បាទ! នៅខេត្តកំពង់ឆ្នាំងនៅឡើយទេ ។

បូលី : នៅខេត្តកំពង់ឆ្នាំង បើ៣២នៅកំពង់ស្ពឺហ្នឹងឯង?

យឹម : ខ្ញុំនៅខេត្តកំពង់ឆ្នាំងទេ! ខ្ញុំនៅរហូតទាល់តែរំដោះ៧៥ ។

បូលី : ពូនៅកងទ័ពតំបន់ហ្នឹង គេហៅអីគេ? វរសេនាតូច ឬវរសេនាធំ ឬក៏កងពល?

យឹម : កាលហ្នឹង! កងតំបន់ហ្នឹងគេហៅកងតំបន់ គ្រាន់តែគេរៀបចំ ជាអង្គភាព ដូចជាអត់មានដល់វរសេនា ។

បូលី : អនុសេនាធំ?

យឹម : អាចមានដល់អនុសេនាធំប៉ុន្តែ ប្រចាំផងអង្គភាពកងពល អត់មានទេ ។

បូលី : នរណាគេគណៈតំបន់កាលហ្នឹង របស់៣១?

យឹម : ៣១ មិនដឹងនរណាគេទេ ខ្ញុំមិនចូលជ្រៅដែរ អារឿងហ្នឹង ។

បូលី : ចុះមេទាហាន ដែលក្តោបក្តាប់ អើកម្លាំងរបស់តំបន់ពីណាគេ?

យឹម : មេទាហានក៏មិនដឹងទៀត ។

បូលី : ភ្លេចហើយណ៎ពូ?

យឹម : ភ្លេចហើយ! ភ្លេចទាំងឈ្មោះគាត់ហ្នឹងទៀត ។

បូលី : ចុះពូធ្វើកងទ័ពតំបន់រហូតដល់បែក៧៥តែម្តង?

យឹម : បាទ! បែក៧៥ ។ កងរបស់ពូមានវាយចូលភ្នំពេញទេ?

បូលី : ខាងខ្ញុំនៅវាយនោះទេ នៅវាយតាមខេត្តនោះទេ?

យឹម : ទេ! កាលហ្នឹង៧៤ គេបញ្ជូនមកមកជួយវាយនៅភ្នំពេញហើយ កង(ស្តាប់ពុំបាន) បញ្ជូនមកជួយវាយហ៊ុមពទ្ធ័ជុំវិញហើយ ប្រមូលផ្តុំគ្នា ចូលមកភ្នំបេញហើយ ។

បូលី : ចូលតាមណាកាលហ្នឹង?

យឹម : កងខ្ញុំកាលហ្នឹងចូលវាយច្រក ត្រង់ព្រែកលាប មុំព្រែកលាបហ្នឹងឯងមកខាងហ្នឹង ព្រោះភ្លេចហើយកន្លែងតស៊ូនៅខាងហ្នឹង ។

បូលី : អត់ចូលតាមផ្លូវជាតិទេណ៎? កំពង់ឆ្នាំងទៅតាមផ្លូវជាតិ បំបែកចូលមកកាត់តាមព្រែកក្តាមព្រែកព្នៅ វត្តក្រួស ។

យឹម : ខ្ញុំកាលហ្នឹង មើល! កងខ្ញុំដូចគេបញ្ជូលមកភូមិភាគ ឡើងមកដល់ភូមិភាគហើយ ។

បូលី : ភូមិភាគអីគេ?

យឹម : ឡើងមកដល់ អាកង! មិនដឹងភូមិភាគអីទេ តែនៅកងតំបន់ គេហៅតំបន់៣១ ខ្ញុំកាលហ្នឹងមេកងខ្ញុំគាត់ឈ្មោះតា រកនឹកសិន ភ្លេចឈ្មោះគាត់ទៀត គាត់មេ ប្រធានវាយរូពវាភ្លេចមេៗ ។

បូលី : ចុះពេលដែលពូវាយចូលមកភ្នំពេញហ្នឹង បានចូលមកដល់ភ្នំពេញទេ?

យឹម : ពួកខ្ញុំចូលមកដល់ភ្នំពេញដែរតា ។

បូលី : ទៅឈរជើងនៅម្តុំណាវិញ?

យឹម : ឈរជើងនៅម្តុំវ៉ារទះភ្លើង វ៉ារទះភ្លើងពីមុន ស្អី!

បូលី : អយស្ម័យយាន ។

យឹម : បាទ! ស្អីត្រង់ហ្នឹងគេហៅស្អីពីដើមទេ ។

បូលី : មិនមែនជិតទទួលទស្សន៍ប៉ុស្តិ៍លេខ៣ទេ?

យឹម : ស្អីគេហៅ!

បូលី : សក្យមុនីចេតិយ?

យឹម : មិនមែនទេ ។ ហៅស្អី! វ៉ារទះភ្លើងពីដើម វ៉ាតាំងពីជំនាន់សម្តេចហ្នឹងណា ។

បូលី : វាមកខាងត្បូងផ្សារថ្មី?

យឹម : ខាងហ្នឹង ដូចនៅខាងឈាង ត្បូងឈាងខាងលិច ខាងជើងភ្នំពេញហ្នឹង ប៉ុនមិនដឹងត្រង់ណាទេ ។

បូលី : ជិតសាលាពេទ្យ? សាលាក្រហម សាលាពេទ្យ?

យឹម : ភ្នំពេញ មិនសូចស្គាល់ទេ កាហ្នឹងនៅខាងហ្នឹង ។

បូលី : ដឹងតែវ៉ារទះភ្លើង?

យឹម : មិនដែលមក ពិបាក!

បូលី : ហើយពេលចូលទៅដល់ភ្នំពេញគេឲ្យធ្វើអីទៅពូ?

យឹម : ចូលដល់ភ្នំពេញហ្នឹង មិនបានប៉ុន្មានផងគេអត់ឲ្យមកនៅឯជាំចោឯនេះ ។ ខាងត្បូងពេញណា ។

បូលី : មកនៅចោមចៅទៅណា ។ មកធ្វើអីនៅចោមចៅ?

យឹម : ៧៥ហ្នឹង កាលហ្នឹងគេឲ្យនៅយាមការពាររបស់ក្រវាត់ខ្សែភ្នំពេញ គ្រាន់តែយាមមិនធ្វើអីទេ ។ នៅយាមដើម្បីការពារទីក្រុងភ្នំពេញហ្នឹងឯង ។

បូលី : ពី៧៥ ទៅ៧៩ ពូនៅណា នៅភ្នំពេញរហូត ឬនៅគេបញ្ជូនទៅណាទៀត?

យឹម : ខ្ញុំនៅបាន ចន្លោះ៧៥ មកដល់មិនបាន១ឆ្នាំទេ ។ ខ្ញុំនៅធ្វើស្រែ ស្រែនោះណាកងទ័ពរំដោះហើយហ្នឹង នៅធ្វើស្រែចោមចៅកាលហ្នឹង មានធ្វើនឹងកម្លាំង កងទ័ពនៅនេះខ្លះ(ស្តាប់ពុំបាន) មានគោមានក្របីធ្វើស្រែហ្នឹងកម្លាំង នៅចោមចៅហ្នឹងឯង ។ ប្រជាជនភ្នំពេញនៅភ្នំពេញកាលហ្នឹងគេជម្លៀសអស់ហើយ អត់មានទេ ។

បូលី : ពូមានបានឃើញប្រជាជនចេញទេ?

យឹម ៖ ខ្ញុំរំដោះហើយ ប្រជាជនជម្លៀសចេញហូរហែរ ក្រោយពីគេរំដោះភ្លាមនោះ ៗ ភ្នំពេញស្ងាត់អស់គ្មានមនុស្សទេ ៗ

បូលី ៖ ប៉ុនពេលដែលប្រជាជនដើរចេញមានបានឃើញទេ?

យឹម ៖ បាទ! ឃើញតា ៗ

បូលី ៖ យើងមានដាក់បុស្តិ៍យាមតាមច្រកចេញហ្នឹងទេ?

យឹម ៖ បាទ! ដែលគេឲ្យនៅ នៅតាមទាហានលន់ នល់ ហ្នឹងណា ហើយសល់អីគេមានមកធ្វើសកម្មភាពវិញណា ៗ

បូលី ៖ ហ៊ូ! ចឹងបុស្តិ៍នៅច្រែកចោមចៅវិញ?

យឹម ៖ នៅការពារ ក្រែងលោមាន ពួកលន់ នល់នៅសេសសល់បង្កប់នៅទីណាទីណី មកធ្វើសកម្មភាព យើងការពារចឹងឯង ៗ

បូលី ៖ យើងមានឆែករកអត្តសញ្ញាណប័ណ្ណលន់ នល់ អីទេ?

យឹម ៖ អត់ទេ! អត់បានឆែកទេ ៗ

បូលី ៖ អត់បានឆែកទេ?

យឹម ៖ បាទ! យើងយាមធម្មតា តែគេមកឆែកអី គេភ្លេចអីខ្ញុំមិនដឹងទេណា ៗ មកកងខ្ញុំនេះអត់ទេធម្មតាទេ នៅការពារកន្លែងនេះធម្មតាទេ អត់ធ្វើសកម្មភាពអីទេ ៗ យើងចេះធ្វើដំណើរ យើងមិនបានទៅសាកសួរនាំអីគាត់ គេយកទៅណាៗខ្ញុំមិនដឹងទេកាលហ្នឹងណា ៗ

បូលី ៖ មេៗ គេមានប្រាប់ទេថា មូលហេតុអីបានជាគេជម្លៀសប្រជាជនចេញចឹង?

យឹម ៖ គេជម្លៀស ប្រជាជនចេញគឺថាដើម្បី ការពារទីក្រុងភ្នំពេញ ដើម្បីរុករក កម្លាំងទាហានដែលបាក់បែកបង្កប់នៅកន្លែងណាដើម្បីគេងាយរុករកឲ្យឃើញលន់ នល់ បង្កប់ខ្លួននៅក្នុងហ្នឹង គេនិយាយចឹងឯង ដកចេញទៅក្រៅសិនដើម្បីការពារទីក្រុងភ្នំពេញ ៗ

បូលី ៖ ប្រាសសំអាតសិន?

យឹម ៖ សំអាតខ្មាំងណា ក្រែងលោមានទ័ពបង្កប់នៅតាមច្រកល្ហកផ្ទះថ្ម ផ្ទះអី មកប្រជាជននៅច្របូកច្របល់អីចឹង យើងមិនងាយរកឃើញទេ ព្រោះទាហានលន់ នល់ ដែលចាញ់ទៅវាបង្កប់ខ្លួននៅក្នុងហ្នឹងបាន ៗ

បូលី ៖ ពូនៅបានប៉ុន្មានខែនៅភ្នំពេញហ្នឹង?

យឹម : ខ្ញុំនៅមើលយើង៧៥ ខ្ញុំថានៅ ខ្ញុំនៅធ្វើស្រែ ខ្ញុំមិនបានដល់ប្រូតទេ ខ្ញុំនៅបានតែមួយស្ទួង។ យើងស្ទួងមើលអាចខែ៦ ខែ៧ បើខ្មែរអាចខែជេស្ឋ ខែធម្មាសាឍហើយទៅតាមមើល។ អាចជេស្ឋហើយតាមមើល ខែពិសាខណា។

បូលី : បាទ! បានគេឲ្យធ្វើម៉េចទៀតទៅ?

យឹម : ឥលូវគេមកឲ្យខ្ញុំមកធ្វើការនៅព្រៃនប់។

បូលី : ព្រៃនប់នៅខាង កំពង់សោម?

យឹម : បាទ! ស្រុកព្រៃនប់ ស្រុក!

បូលី : ស្រុកស្រែអំបិល?

យឹម : ឃុំដងកំពែង នៅក្នុងស្រុកអី?

បូលី : ឃុំអី?

យឹម : ឃុំដងកំពែង! ស្រុកស្រែអំបិល?

បូលី : ស្រែអំបិល នៅក្នុងខេត្តកោះកុង។

យឹម : ហើយកាលហ្នឹង កងខ្ញុំគេដកឲ្យមកនៅស្រុកស្រែអំបិលនោះឯង។

បូលី : កងអីគេដកមកហ្នឹង?

យឹម : កងតំបន់ កងតំបន់នេះដែរ។

បូលី : វរ ឬក៏អនុសេនា?

យឹម : តំបន់១០១។ បានរៀបចំជាកង មានរហូតដល់កងពលហើយហ្នឹងនោះ មានកងពល មានវរសេនាធំ។

បូលី : តំបន់១០១ នៅខាងត្បូសានវិញទេពូ?

យឹម : ១០១ ត្បូសាន!

បូលី : ១០១ នៅខាងសៀមប៉ាង។

យឹម : ខ្ញុំនៅក្នុងកងតំបន់៣១ នឹងឯង។ មិនមែនកងតំបន់ទេ ចូលភូមិភាគហើយហ្នឹងនោះ ក្រោយរំដោះហើយចូល ភូមិភាគហើយហ្នឹងនោះ។

បូលី : ភូមិភាគអីវិញ?

យឹម : កាលនោះតាសឿង មេកងខ្ញុំ ហើយតាសឿង ។

បូលី : តាសឿន ឬក៏តាសឿង?

យឹម : សឿង។

បូលី  :  កងអីគេពូនៅចាំទេ?  កងពល  ឬក៏វរៈ  ឬក៏?

យឹម  :  កាលហ្នឹងគេរៀបចំប្រធានកងពលហើយ  ខ្ញុំនោះ ។

បូលី  :  កងពលលេខប៉ុន្មាន?

យឹម  :  កងពល១០១ហ្នឹងឯង  មិនមែនតំបន់១០១ទេ  កងពល១០១ហ្នឹងឯង ។

បូលី  :  ដូចជាមិនដែលឮឈ្មោះ ។

យឹម  :  មានឬទេ?

បូលី  :  ដូចជាមិនដែលឮ!

យឹម  :  មិនដែលឮ?

បូលី  :  បាទ!  បើ៨០១  កងរបស់តាសារឿន!  នៅខាងស្លាសានណា៎  ខាងរតនគិរីតា០៥ ។

យឹម  :  មើលកង  អាហ្នឹងខ្ញុំជួបភូមិភាគហើយ  កងតាហឿងហ្នឹងឯង  គាត់មេប្រធានកងណា ។

បូលី  :  ពូឈរជើងនៅម្ដុំណាកងពូ?

យឹម  :  គេចែកជាវរសេនាធំ  ចែកជាវរសេនាតូចអស់ហើយ  ខ្ញុំឈរជើងនៅ!

បូលី  :  ខេត្តអីគេ?

យឹម  :  នៅស្រុកព្រៃនប់  ប៉ុន្តែទៅធ្វើការនៅឯមាត់សមុទ្រ  នៅឯកោះខ្យង ។

បូលី  :  ពូទៅនៅកោះខ្យងហេ៎?

យឹម  :  បាទ!

បូលី  :  នៅកោះខ្យង  ចឹងពូនៅមួយតាមុត?

យឹម  :  អត់ទេ!

បូលី  :  ខាងកំពង់សោម ។

យឹម  :  ខាងកំពង់សោម  ប៉ុនកាលហ្នឹងខ្ញុំនៅតាសៀងនៅឡើយ ។

បូលី  :  តាសៀង?

យឹម  :  បាទ!

បូលី  :  ធ្វើអីម្ដុំហ្នឹងពូ?

យឹម  :  ទីហ្នឹង  ដូចជាមិនធ្វើអីទេ!នៅការពារស្ដីទេហ្នឹង ។

បូលី  :  ពូនៅកោះខ្យងហ្នឹង?

យឹម  :  បាទ!  នៅកោះខ្យង  ប៉ុនបាននៅយូរទេខ្ញុំនោះ ។

បូលី  :  នៅបានរយៈពេលប៉ុន្មាន?

យឹម ៖ នៅបានរយៈពេល ប៉ុន្មានខែ គេឲ្យខ្ញុំមកធ្វើការ នៅមូលដ្ឋានវិញហើយ ។

បូលី ៖ មូលដ្ឋានណាវិញ?

យឹម ៖ មកនៅទីអីណាស្រុកថាមិញ ស្រុកអី ឃុំដងពែង ស្រុកស្អីទីហ្នឹង!

បូលី ៖ ខេត្តអី?

យឹម ៖ ចូលកោះកុងហើយ ។

បូលី ៖ អាចស្រែអំបិល, វាអាចបុទុមសាគរ ។

យឹម ៖ នេះហើយ ស្រុកស្រែអំបិល ។

បូលី ៖ ស្រែអំបិលនែក?

យឹម ៖ ស្រុកស្រែអំបិលហើយ ខ្ញុំនៅឃុំដងពែង ។

បូលី ៖ មកធ្វើអីវិញនៅស្រែអំបិល?

យឹម ៖ ធ្វើការមូលដ្ឋាន កាលហ្នឹងគេដកខ្ញុំពីកងទ័ព មកធ្វើការមូលដ្ឋាន ។

បូលី ៖ លែងជាកងទ័ពហើយចឹង?

យឹម ៖ នៅដែរ! នៅជាកងទ័ពមួយកំណាត់ នៅតាមដ្ឋដែរហ្នឹង ។

បូលី ៖ ធ្វើអីទៅ?

យឹម ៖ នៅជួយការងារប្រជាជន ដកស្ទូងហ្នឹង ។

បូលី ៖ ធ្វើស្រែចឹង?

យឹម ៖ បាទ! ធ្វើស្រែ ។

បូលី ៖ នៅហ្នឹងរហូត ឬក៏យ៉ាងម៉េច?

យឹម ៖ អត់រហូតទេ!អាហ្នឹង៧០ ខ្ញុំទៅនៅហ្នឹង៧៦, ៧៧ហើយ ។ ៧៧,៧៨ ខែយើងស្ទូងដែរ ខែវស្សា អាក្នុងខែដកស្ទូង មើលខ្មែរអាចក្នុងខែ៥ ទៅ៦ ហើយតាមមើលនោះ ។ គេបញ្ជូនខ្ញុំមកនៅរតនគិរី ធ្វើការមូលដ្ឋាននៅហ្នឹង ។

បូលី ៖ ធ្វើការនៅរតនគិរីនៅម្តុំណា?

យឹម ៖ នៅតំបន់១០១ ជាមួយតាធិន ។

បូលី ៖ លី ធិនហេ៎?

យឹម ៖ បាទ! គាត់គណតំបន់កាលហ្នឹង ។

បូលី ៖ គណៈតំបន់១០១?

យឹម ៖ បាទ! តំបន់១០១ ឈ្មោះធិនហ្នឹងហើយ ។

បូលី ៖ ផិនហ្នឹង មកកាន់តំបន់ហេ៎?

យឹម ៖ បាទ! កាលហ្នឹងមកមានខ្ញុំ មានតាយឿន មានខ្មោចតាខេង គាត់ស្លាប់ហើយ ។ មានតាវឿន ផលូវនេះគាត់នៅ កងពលលេខប៉ុន្មានហើយផលូវនេះ ។ ឃើញ៣ ទៅ៤នាក់ដែលបញ្ជូនមកធ្វើការនេះ មូលដ្ឋានហ្នឹង ។

បូលី ៖ ១០១ ឈរជើងនៅស្រុកអីពូ?

យឹម ៖ នៅស្រុក ឈ្មោះស្រុក!

បូលី ៖ តាវេន?

យឹម ៖ ដូចជាស្រុកសេសាន ប្តុក៏! គាត់នៅជាប់ហ្នឹងមាត់ទន្លេ មើលអាទន្លេសេសាន ហើយទន្លេមួយមកពីខាងនោះមក វាជាប់ពាមគ្នា អាទន្លេសេសាន ។

បូលី ៖ ទន្លេស្រែពក?

យឹម ៖ ទន្លេស្រែពក ។

បូលី ៖ ទន្លេសេសាន ទន្លេស្រែពក?

យឹម ៖ កាលហ្នឹងកងពល៨០១ កងពលរបស់ខ្មោចតាសាវឿននេះណា គាត់នៅច្រាំងម្ខាងទន្លេខាងកើត ។ កងទ័ពរបស់គាត់ហ្នឹង កងពល៨០១ហ្នឹង ហើយខ្ញុំមូលដ្ឋានហ្នឹង ជាមួយបងសិទ្ធនៅខាងលិចច្រាំងខាងលិច មានប៉ូលីសយន្តហោះមួយនៅហ្នឹងកន្លែងទីរួមតំបន់ហ្នឹងឯង នៅផ្ទះខាងលិចណា ។

បូលី ៖ វឺនសៃទេអី?

យឹម ៖ អត់ទេ! ហេ៎អាហ្នឹងយស្រុកវឺនសៃនេះឯង ។

បូលី ៖ វឺនសៃណ៎? ព្រោះទីតាំង!

យឹម ៖ នៅទីនេះមានប៉ូលីសយន្តហោះមួយ អាយន្តហោះអាដាកត្តាអាតូចទៅបាន ។

បូលី ៖ បាទ! អាដាកត្តា?

យឹម ៖ បាទ!

បូលី ៖ ព្រោះបើទីតាំងកងពលរបស់តាសាវឿននៅខាងកើតទន្លេ នៅវឺនសៃ ហ្នឹងឯង ។ ។

យឹម ៖ នៅវឺនសៃ នៅខាងកើតទន្លេ ហ្នឹងហើយ នៅស្រុកវឺនសៃហ្នឹងឯង ។

បូលី ៖ ស្រុកវឺនសៃហ្នឹង?

យឹម ៖ បាទ! នៅពាមស្រែពក ។

បូលី ៖ ព្រោះអាហ្នឹង បានៗ មានទន្លេ ចឹងមិនមែន១០១ទេ តំបន់១០០?

យឹម ៖ តំបន់១០១ ។ បាទ! ១០១ ច្បាស់ណាស់ ។

បូលី ៖ ច្បាស់ថា១០១ចឹងតែម្ដង ។

យឹម ៖ ១០១ រតនគិរី ហ្នឹងនៅស្រុកវឺនសៃហ្នឹងឯង នៅរតនគិរី ។ ១០៣ នៅស្ទឹងត្រែងហេ៎?

បូលី ៖ ១០៣ ស្ទឹងត្រែង, ១០២ នៅរតនគិរីដែរ, ១០៧ រតនគិរីដែរ?

យឹម ៖ ហ៊ូ! គេចែកជា ខណ្ឌស្រុក ។

បូលី ៖ ព្រំប្រទល់ខេត្ត ១០៨ស្ទឹងត្រែងដែរ ។

យឹម ៖ ១០៨ស្ទឹងត្រែង ។

បូលី ៖ ទន្លេច្រើន ទន្លេស្រែពក ។

យឹម ៖ ខ្ញុំកាលហ្នឹងគេរៀបចំឲ្យខ្ញុំមិនទាន់ចូលឈរជើងនៅក្នុងស្រុកណា មួយទេ ព្រោះខ្ញុំមកនៅ មកនៅជំនួយការរបស់ធិនហ្នឹង នៅជាមួយគាត់ហ្នឹងឯង ។ ខ្ញុំមក បានពេលខ្លីដែរមើលពេល គិតៗទៅខ្ញុំមក៧៨ហ្នឹង ដូចខ្ញុំនិយាយមិញចឹងមកដល់ខែស្ទួន ខ្ញុំចុះទាដូធ្វើការឲ្យទៅឡើងទៅ លើទៅហើយបានបងប្អូននៅលើហ្នឹងគេហៅភូមិអីទេ ខ្ញុំភ្លេចបាត់ហើយមិនចាំទេកាលហ្នឹង ខ្លាច ទៀតព្រោះកាលដែលតាប៉ុល ពតគាត់ឲ្យខ្ញុំរៀបចំមក ឮថាទៅរតនគិរី នឹកឃើញ រឿងមួយ កាលខ្ញុំនៅតូចៗ គាត់តែងនិយាយថាជនជាតិស៊ីមនុស្ស នឹកឃើញថាហេ៎ ទៅ រតនគិរី តំបន់ជនជាតិហ្នឹងអត់ស្រួលទេ ។ ចាស់ៗ តែងនិយាយថាមិនស្រួលស៊ីមនុស្សអីណា ខ្ញុំនៅក្មេង ដូចមានអារម្មណ៍ខ្លាចអាហ្នឹង ហើយភិភ័យដែរ អាកន្លែង! មិនដែលឮ មិនដែល ស្គាល់ទេ ហើយឮថាចាស់ៗជនជាតិ ។

បូលី ៖ នរណាអ្នកចាត់តាំង?

យឹម ៖ កាលហ្នឹង មិនដឹងជានរណា ។ តាសឿង គាត់អ្នកចាត់តាំងឲ្យទៅ ។

បូលី ៖ តាសឿងនៅខាង កងពលខ្ញុំមិញ ។

យឹម ៖ តាសឿងនៅខាងព្រៃទប់ហ្នឹងហេ៎?

បូលី ៖ បាទ! ខាងកោះខ្យង គាត់ឲ្យទៅ?

យឹម ៖ បាទ! គាត់មេគ្រប់គ្រង កងខ្ញុំនៅហ្នឹង ។

បូលី ៖ ម៉េចបានគេបញ្ជូនទៅខាងកោះខ្យងទៅដល់រតនគិរីចម្ងាយណាណី?

យឹម ៖ មិនដឹងទេ ព្រោះគាត់មកអប់រំទៅ ដូចថានៅក្នុងខេត្តរតនគិរីហ្នឹង វាជាតំបន់ដែលជាប់ព្រំដែន យួនជាមួយ វៀតណាមណានោះ ហើយមេដឹកនាំភាគច្រើនគឺក្បត់ វាចឹង ចឹងគឺត្រូវយក កម្មាភិបាលពីកន្លែងផ្សេងៗទៅដើម្បីបញ្ជូនទៅធ្វើការងារនៅកន្លែងហ្នឹង ។

បូលី  :  ឆ្នាំប៉ុន្មានដែរពូទៅ ហ្នឹង?

យឹម  :  ៧៨ ។ មុន៧៩បន្តិច ។

បូលី  :  ៧៨ គេចាប់ច្រើនណាស់នៅខាងរតនគិរីហ្នឹងណា?

យឹម  :  បាទ!

បូលី  :  គ្រាន់តែកងតាសារឿន ប្រហែលចាប់ជាប់ជាង៤០០នាក់ ។

យឹម  :  ខ្ញុំទៅហ្នឹងឃើញសភាពការណ៍ហ្នឹង រឹករវមែនកាហ្នឹង ច្របូក ច្របល់មែនទែនតែម្តងទៅ សភាពការណ៍នៅរតនគិរីកាលហ្នឹង ។

បូលី  :  ពូទៅតាមណា ពូជិះអីទៅ?

យឹម  :  កាលហ្នឹងតាប៉ុល ពត ឲ្យជិះយន្តហោះ ជិះអាយន្តហោះ អាដាកត្តាតូចហ្នឹង ។

បូលី  :  អាដាគត្តា?

យឹម  :  បាទ!

បូលី  :  គ្នាប៉ុន្មាននាក់កាលហ្នឹង?

យឹម  :  ទាំងអង្គរក្សផង គ្នាប្រហែលជា១០នាក់ជាង ។

បូលី  :  តាប៉ុល ពត អ្នកបញ្ជូនទៅតែម្តង?

យឹម  :  មុនហ្នឹងខ្ញុំចេញពីស្រែអំបិល ចេញពីកោះកុងនេះទៅ ទៅជុំគ្នានៅព្រៃទប់នៅកន្លែងតាសៀង ហ្នឹងឯង ។ គាត់ណែនាំអីគ្រប់យ៉ាងអស់ហើយ ទៅដេកនៅកន្លែងគាត់នោះ១យប់ ២យប់ គាត់ ។ គាត់ណែនាំអស់ហើយ មួយចំនួនធំអប់រំណា ។

បូលី  :  ណែនាំថាម៉េច?

យឹម  :  ដូចខ្ញុំនិយាយមិញចឹង មកធ្វើការនៅ ដើកាលហ្នឹងគាត់មិនទាន់និយាយពីរឿង ធ្វើការនៅ រតនគិរី ដល់តែកន្លែងតាប៉ុល ពត បានគាត់ណែនាំបន្ថែមទៀត ។

បូលី  :  កន្លែងតាប៉ុល ពតនៅឯណា?

យឹម  :  នៅភ្នំពេញ ។

បូលី  :  ហ៊ូ! ចឹងពូចេញពីព្រៃទប់មកភ្នំពេញសិន?

យឹម  :  បាទ! មកភ្នំពេញសិន ។

បូលី  :  មកភ្នំពេញដេកប៉ុន្មានថ្ងៃ?

យឹម  :  មកភ្នំពេញទៅ(ស្តាប់ពុំបាន) នោះ២,៣យប់ ។

បូលី  :  ៣យប់ហ៎?

យឹម : បាទ! ៣យប់ៗ

បូលី : សម្រាកនៅម្តុំណា?

យឹម : ភ្លេចបាត់ហើយៗ

បូលី : ប៉ុន្តែផ្ទះហ្នឹង ផ្ទះរបស់កម្មាភិបាល ឬផ្ទះប្រជាជន?

យឹម : ផ្ទះយើងពីសង្គម ជំនាន់ប្រជាជនហ្នឹងឯង ដែលគាត់យកទីតាំងមកធ្វើ ខ្ញុំភ្លេចហើយអាហ្នឹងៗ

បូលី : ហើយបានជួបតាប៉ុល ពតៗ

យឹម : បាទ! មុនហ្នឹងចេញមក បានយកទៅអប់រំរៀនសូត្រពន្យល់ពី ហេតុផលនៃគ្រប់បែបយ៉ាង ដូចខ្ញុំនិយាយម៉េចចឹងៗ

បូលី : បាទ! គាត់ពន្យល់ថាម៉េចចឹង?

យឹម : ពន្យល់ពីរឿង ពន្យល់ពីសភាពការណ៍នៅព្រំដែនខាងកើតហ្នឹង គឺនិយាយពីអ្នកក្បត់ហ្នឹងវាច្រើន ហើយនិយាយពីខ្មាំងសត្រូវយួនហ្នឹង ដូលមកបន្កប់នៅកន្លែងហ្នឹងក៏ខ្មាំងដែរៗ ពាក្យដែលគាត់យកមកបង្រៀនគាត់ យកតែគោលមកបង្រៀនទេណាៗ

បូលី : បាទ!

យឹម : គាត់អប់រំច្រើនណាស ពីវិធីដែលត្រូវទៅហ្នឹង ខ្ញុំយ៉ាងម៉េច បានគាត់ណែនាំៗ

បូលី : ប៉ុន្មានម៉ោង?

យឹម : គាត់រៀនប្រហែលជាមួយព្រឹកទេដឹង!

បូលី : ហ៊ូ! យូរដែរៗ ហើយអ្នកចូលរួមច្រើនទេ?

យឹម : ចូលរៀនតែពួកខ្ញុំប៉ុន្មានអ្នកដែលត្រូវទៅតែប៉ុណ្ណឹងឯងៗ

បូលី : ១០នាក់ជាងហ្នឹង?

យឹម : បាទ! បើយើងមានការងារទៅហ្នឹងគឺ ហើយគាត់មុនហ្នឹងទៅគាត់ឲ្យតាសារៀនហ្នឹងមក ធ្វើការហ្នឹងដែរ ជូនពួកខ្ញុំមកជាមួយពួកគាត់ហ្នឹងឯងៗ មកជាមួយតាកងពលហ្នឹងណា មកជាមួយគ្នាៗហ្នឹង!

បូលី : មករៀនមួយព្រឹកចឹង?

យឹម : បាទ!

បូលី : ក្រៅពីប៉ុល ពត មាននរណាផ្សេងទេ? ឬមានតែប៉ុល ពតមួយគត់ៗ

យឹម ៖ ប្រពន្ធគាត់ហៅទៅនៃណាំចឹងណា តែគ្រន់តែមុនហ្នឹងវា គេឲ្យយើងទៅសម្រាកដើរកំស្តាន មើលអីលិចកើតនៅភ្នំពេញហ្នឹងឯង ។ ស្រាប់តែគេជិតមកបានគាត់ ហៅទៅណែនាំប្រហែលមួយព្រឹកចេញដំណើរទៅ ។

បូលី ៖ ហើយចេញពីកន្លែងគាត់ហ្នឹង ទៅពោធិ៍ចិនតុង ទៅឡើងនៅពោធិ៍ចិនតុង ឬទៅនៅឯណា?

យឹម ៖ ទៅពោធិ៍ចិនតុង ។

បូលី ៖ ជិះអីទៅពូ?

យឹម ៖ ជិះអាកត្តាតូចហ្នឹង ។

បូលី ៖ ពីកន្លែងកន្លែងរៀន ទៅពោធិ៍ចិនតុង?

យឹម ៖ ជិះឡាន ។

បូលី ៖ ជិះឡានទៅ?

យឹម ៖ បាទ!

បូលី ៖ ជិះឡានប៉ុណ្ណាដែរ?

យឹម ៖ ឡានទ្រុងធំដែរ ។

បូលី ៖ មិនមែនអាកំម៉ុងការទេ?

យឹម ៖ ឡាននេះទ្រើសដែរ!

បូលី ៖ ហើយឡើងយន្តហោះត្រូវការប៉ុន្មានម៉ោងបានដល់រតនគិរី?

យឹម ៖ អត់បានផ្ទៀងម៉ោង មិនដឹងប៉ុន្មានទេ!

បូលី ៖ ជិះយូរទេ?

យឹម ៖ ដូចជាមិនយូរប៉ុន្មានដែរ ។ គាត់ណែនាំថា ជិះកុំឲ្យឆ្ងាយពីទន្លេ ក្រែងលោវាមានឧបត្តិហេតុអីទៅវាស្រណុក ។

បូលី ៖ ចុះទន្លេ ។

យឹម ៖ ក្បែរគ្នាអីចឹងទៅ ស្រណុកចុះទន្លេហ្នឹងតែម្តងទៅ គាត់ថាណា ។ កាលនោះយន្តហោះសល់ពីសង្គ្រាមនោះ ។ យន្តហោះនោះ វាមិនធានាតាមផ្លូវ ហីទៅគាត់ថាហោះតាមមាត់ទន្លេនោះទៅ ។

បូលី ៖ គាត់ណែនាំចឹងទៀត?

យឹម ៖ បាទ!

បូលី ៖ ដល់មាត់ទន្លេ! ដល់ពេលពូទៅដល់ហ្នឹង ចុង៧/៨ហើយ?

យឹម ៖ វាមិនទាន់ទៅទេ ព្រោះខ្ញុំទៅវាបានធ្វើស្រែវស្សា ដូចថាមិនចឹងខែ៦ ខែ៧ ខ្ញុំទៅ ខ្ញុំចុះនៅធ្វើការធ្វើស្រែជាមួយបងប្អូន ។

បូលី ៖ គេចាត់ចែងឲ្យពូធ្វើអី ដល់ភ្លាម?

យឹម ៖ ដល់ភ្លាម! អត់ឲ្យធ្វើអីទេ ព្រោះយើងនៅស្មែងយល់ពីគេ គេស្វែងយល់ពីយើងនៅធ្វើការកន្លែងជាមួយបងផិនហ្នឹងឯង ។

បូលី ៖ ព្រោះតែគេបញ្ជូន ពីមជ្ឈិមទៅបានន័យថាគេបញ្ជូនទៅឲ្យគ្រប់គ្រងចឹង?

យឹម ៖ បាទ!

បូលី ៖ ដើម្បីមើលស្ថានការណ៍ឲ្យវាមកល្អប្រសើរវិញណា ។ ចឹងពេលដែលទៅដល់ គេមានចាត់ចែងការងារសំខាន់ខ្លះ ឲ្យពូទទួលខុសត្រូវមើលទៅ?

យឹម ៖ ឲ្យតា!

បូលី ៖ ដូចជាអ្វីខ្លះពូ?

យឹម ៖ ដូចជាការងារនៅតាមមូលដ្ឋានដើម្បីក្តាប់ និងពង្រឹងប្រជាជននៅតាមមូលដ្ឋាន នឹងជួយធ្វើស្រែ អប់រំប្រជាជនយើងពីវិធីស្រែ ព្រោះកាលនោះបងប្អូនយើងអត់ចេះធ្វើស្រែទេ ។ ជំនាន់គាត់ពីមុនធ្វើតែចម្ការនោះ បានមកដល់យើងសម័យខ្មែរក្រហមនេះ អប់រំយើងឲ្យចេះធ្វើស្រែ ធ្វើនង្គ័ល ។ ដកស្ទូង ចេះសាបព្រោះ មើលគាត់ធ្វើចម្ការតទៅទៀតទេ ។ ចឹងនៅធ្វើស្រែធ្វើចម្ការ នៅធ្វើតិចតួចទៅកាលដែលខ្ញុំទៅនោះ ប៉ុន្តែភាគច្រើនគឺទៅធ្វើស្រែអស់ហើយប្រជាជននោះ ។

បូលី ៖ ហើយដល់ពេលព្រឹត្តិការណ៍ក្រោយៗមកទៀតមានការបន្តចាប់ខ្លួនតទៅទៀតទេពូ អ្នកដែលនៅគ្បាសាននោះ?

យឹម ៖ ឃើញចាប់ហូរហែរដែរ ។

បូលី ៖ ខុសរឿងអីបានគេចាប់?

យឹម ៖ ខុសហ្នឹងតាមដឹង ថាយើងហ្នឹងវាចូលដៃចូលជើង ។

បូលី ៖ ចូលមែនទេពូ?

យឹម ៖ ពិបាកយល់ដែរ ព្រោះការសួរចម្លើយហ្នឹងរបស់គេដែលចាប់ វាមានដំណាក់ៗរបស់គេណា ហើយមានអ្នកខ្លះចូលដែរ ។ ការសួរចម្លើយរបស់គេ វាចូលដៃ ។

បូលី ៖ ចូលជើងអីចឹងទៅ ចូលមែនទេពូ?

យីម ៖ វាពិបាក ការសួរចម្លើយហ្នឹងរបស់គេដែលចាប់ទៅ វាមានដំណាក់ៗគ្នាណា ។ ហើយមានអ្នកខ្លះចូលដែរ មិនអត់ទេតាមមើល ។

បូលី ៖ ចាប់ទៅ គេចាប់យកទៅម្តុំណា?

យីម ៖ ចាប់ទៅ គេមានកន្លែងសន្តិសុខគេមួយ ។

បូលី ៖ នៅណា?

យីម ៖ នៅ! ភ្លេចបាត់ទៀតណា នៅរតនគិរីហ្នឹងដែរ នៅឆ្ងាយពីកន្លែងដែរខ្ញុំនៅ វីនសៃហ្នឹង ។ មានកន្លែងគេសម្រាប់ឃុំឃាំងដាក់គុកនៅហ្នឹងឯង ។

បូលី ៖ ពូដែលព្ធមន្ទីរសន្តិសុខ បឹងកន្សែងទេ?

យីម ៖ នៅរតនគិរី?

បូលី ៖ បាទ! នៅរតនគិរី ហើយនៅបានលុង?

យីម ៖ បាទ! ខ្ញុំមិនដែលបានទៅដល់ទេទីហ្នឹង ។

បូលី ៖ បឹងកន្សែងកាលហ្នឹង ។ គេចាប់អ្នកទោសទៅ គេយកទៅដាក់នៅម្តុំបឹងកន្សែង?

យីម ៖ អាហ្នឹង ទាល់តែតាម តំបន់ហ្នឹងគេបញ្ជូនទៅអ្នកទោសធំៗ គេបញ្ជូនទៅហ្នឹងឯង ។ អ្នកដែលវានៅល្មមៗ គេទុកនៅកន្លែងការិយាល័យទេ ។

បូលី ៖ ឈ្មោះអីមន្ទីរ?

យីម ៖ មេខ្ទាំងគុក ខ្ញុំអត់បានដឹងទេកាលហ្នឹង តែភ្លេចឈ្មោះទៀតណា ។

បូលី ៖ ប៉ុនមន្ទីរហ្នឹងឈ្មោះមន្ទីរអីគេ?

យីម ៖ មិនចាំដែរ ភ្លេចបាត់ហើយ ។

បូលី ៖ នៅបាន១វស្សាហើយ បានវៀតណាមវាយចូល?

យីម ៖ បាទ! ខែ! ចូលឆ្នាំ ៧៩ហ្នឹង ។ ខែ១ចាប់ផ្តើម វៀតណាមចូលហើយ ។

បូលី ៖ ចូលមកធ្វើម៉េចទៅខាងខ្មែរក្រហម?

យីម ៖ ចូលមកកាលហ្នឹង គេឲ្យជម្លៀសប្រជាជនចេញមកខាងនេះ ខាងលិចទន្លេទាំងអស់ ។

បូលី ៖ ចេញមកខាងលិចទន្លេ!

យីម ៖ ខាងលិចទន្លេមេគង្គ ។

បូលី ៖ បានន័យថាឆ្លងទន្លេ?

យីម ៖ មកម្តុំហ្នឹងព្រះនន្ទ័លអីហ្នឹង ជម្លៀសប្រជាជនមកហ្នឹង ។ ប៉ុន្តែអត់បានមកទេ ប្រជាជនហ្នឹងនោះ ។ មកភាគច្រើនតែពួកមន្ទីរពួកក្រសួង ។

បូលី ៖ ម៉េចចឹងពូ?

យឹម ៖ ប្រជាជនអត់មក ។

បូលី ៖ អត់ព្រមមក! ក្រែងយើងផែនការជម្លៀស យើងអាច?

យឹម ៖ បាទ! យើងផែនការជម្លៀស ប៉ុន្តែជម្លៀសអត់ទាន់ទេ វាបុកមកខ្លាំងដែរកាលហ្នឹង ។ ឈឺបៗមកបណ្តោយ យើងមកអត់ទាន់ទេ ។ ផែនការជម្លៀសដែរ តែជម្លៀសអត់ទាន់ យួនគាត់ចូលមកលឿនពេក ទៅបានៗពួកក្រសួង ពួកមន្ទីរពេក ។ កន្លែងមន្ទីរតាធិនហ្នឹង ហើយនឹងកន្លែងកងពល៨០១ ពួកគ្រួសារកងទ័ពនៅខាងក្រោយហ្នឹង ភាគច្រើន គឺកម្លាំងនៅហ្នឹងឯង ។ ប្រជាជនភាគតិចដែលបានមក ។

បូលី ៖ មកតែខាងកម្មាភិបាលកងទ័ព ហើយហ្នឹងគ្រួសារកងទ័ពអីចឹង?

យឹម ៖ តែមេៗ នៅតាមមូលដ្ឋាន គ្រួសារមេៗហ្នឹង ហើយខាងក្រសួងមន្ទីរមកមូលដ្ឋានហ្នឹង នៅកន្លែងហ្នឹងឯង កងទ័ពហ្នឹងគឺ ព្រមគ្នា ជាមួយគ្នាហ្នឹងឯង គាត់នៅជាប់គ្នាហ្នឹងនោះ ។ ម្នាងទន្លេម្នាក់ ។

បូលី ៖ ពូមាននាទីជាអីនៅជាមួយតាធិនហ្នឹង?

យឹម ៖ ខ្ញុំមិនទាន់មានតួនាទីអីនៅឡើយទេកាលហ្នឹងនោះ យើងមានជំនួយការអី នៅជាមួយគាត់នៅឡើយទេ ។

បូលី ៖ ព្រោះខាងមជ្ឈិមបញ្ជូនទៅចឹងមិនតូចទេណា ពេលដែលតាប៉ុល ពត បញ្ជូនមកបង្ហាត់ផ្ទាល់ចឹងណា ។

យឹម ៖ ព្រោះតាមផែនការ គេឲ្យខ្ញុំទៅខាងស្រុកគេ ។

បូលី ៖ ស្រុកហេ៎?

យឹម ៖ បាទ! តែខ្ញុំ មិនទាន់បានចូលស្រុកនៅឡើយទេខ្ញុំនោះ មិនទាន់ច្បាស់ថាស្រុកណាមួយនៅឡើយទេកាលហ្នឹងនោះ ។ នៅខាងផែនការគេឲ្យខ្ញុំ កាន់ខាងស្រុក ។

បូលី ៖ ពេលបញ្ជូនទៅគេមានឲ្យក្រដាសស្នាមលិខិតស្នាមវាយត្រា វាយអីបញ្ជូនទៅទេ?

យឹម ៖ អត់ទេ!

បូលី ៖ ប្រាប់តែមាត់ ណែនាំតែមាត់ទេ ទៅកាន់តែស្រុកមួយចឹង?

យឹម ៖ ទៅកាន់នៅរតនគិរី(ស្តាប់ពុំបាន) ។

បូលី ៖ ហើយពូជិះអីឆ្លងទន្លេកាលហ្នឹង?

យឹម ៖ ជិះកាណូត ។ ពីភ្នំពេញទៅ?

បូលី ៖ អត់ទេ! ពេលដែលវៀតណាម វាយចូល ។

យឹម ៖ គឺចេញពីកន្លែងនោះមកជិះឡាន ។ ជិះឡានរហូតមកដល់ស្ទឹងត្រែង ។

បូលី ៖ មកស្ទឹងត្រែងសិន បានមកឆ្លងទន្លេអីទន្លេមេគគង្គយើងហ្នឹងណា ។

យឹម ៖ ពីរតនគីរីជិះឡានរហូត ។

បូលី ៖ ជិះមកស្ទឹងត្រែង គាត់មកតាមអូរពងមាន់អត់ទេពូ?

យឹម ៖ នោះហើយកាត់តាមអូរពងមាន់ដែរ ។

បូលី ៖ ចឹង! ពីរតនគីរីមកអូរពងមាន់សិន?

យឹម ៖ បាទ! តាមផ្លូវហ្នឹងឬ ។

បូលី ៖ បានមកទីរួមខេត្តស្ទឹងត្រែង?

យឹម ៖ បាទ! ស្ទឹងត្រែងហើយបានឆ្លងទន្លេ ។ ហ្នឹងជាមួយគ្នាហ្នឹង គាត់នៅខាងកងពល៨០១ហ្នឹងឯង ។

បូលី ៖ ហ៊ូ! អឹមស្រី ។

យឹម ៖ គាត់ហៅកងនារីនោះ ។ ឈ្មោះគាត់គេហៅ០៨ !

បូលី ៖ ០៨?

យឹម ៖ បាទ! កងពលរបស់នារី កងពល៨០១ហ្នឹងណា ។

បូលី ៖ គាត់មេកងពល?

យឹម ៖ អត់ទេ! មេអង្គភាពគេហ្នឹង តែឈ្មោះកងគេហ្នឹងលេខ០៨ ។

បូលី ៖ ពីណាមេកង០៨?

យឹម ៖ ទល់តែសួរគាត់បានដឹង! ខ្ញុំមិនដឹងដែរ ។

បូលី ៖ មិនមែនគាត់ទេ?

យឹម ៖ មិនមែនគាត់ទេ គាត់កូនទាហានគេទេ ។

បូលី ៖ ព្រោះឈ្មោះ០៨ហ្នឹងធំណាស់ ។

យឹម ៖ ០៨ហ្នឹង អង្គភាពរបស់កងនារីគេហ្នឹងឯង ។

បូលី ៖ បើ០៥នៅ?

យឹម ៖ បាទ! បើ០៥ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាសារឿនហ្នឹងឯង ។ មានអង្គភាពរបស់គេនារីមួយកង ក្នុងកងពល៨០១ហ្នឹងណា ។ គេហៅកង០៨ហ្នឹងកងនារី ។

បូលី ៖ ហើយពេលដែលឆ្លងទន្លេមក មកដល់ណាទៀតទៅ?

យឹម : ឆ្លងទន្លេមក មកតាមព្រំដែននេះ មកភូមិព្រះនន្ទ័ល ។ ភូមិព្រះនន្ទ័លយើងជាប់នឹងទន្លេមេគង្គហ្នឹង ។

បូលី : ព្រះនន្ទ័ល មិនមែនព្រះអង្គិលទេ?

យឹម : មិនមែនទេ! ព្រះនន្ទ័លនៅក្នុងស្រុកថាឡាបរិវាត់ ។

បូលី : ហើយទៅយ៉ាងម៉េចទៀតទៅ?

យឹម : ហើយពួកខ្ញុំអស់ឡានហើយ កាលហ្នឹងដើរហើយ ឡានចោលនៅខាងកើតទន្លេទាំងអស់ហើយ ។

បូលី : ម៉េចបានយើងចោលឡានកាលហ្នឹង?

យឹម : ឡានមកបានតែឡាន២ ទៅ៣គ្រឿងទេ ឆ្លងសាឡាងមក វាអស់សាំងចាក់ វាមានសាំងណាចាក់ បើសាំងនៅកន្លែងនោះ មិនបានយកសាំងមកច្រើនឯណា ។

បូលី : ហើយមកតាមផ្លូវបានអីហូបចុកទៅ ធ្វើដំណើរ?

យឹម : ចូលតាមភូមិ រកស្បៀងតាមភូមិហ្នឹងទៅ បុកអង្ករបុកអីទៅ កាលហ្នឹងខ្ញុំចេញពីរតនគីរីមកដូចខ្ញុំនិយាយមិញចឹង ចូលមកព្រះនន្ទ័ល ហើយស្នាក់ហ្នឹង កាលហ្នឹងវៀតយណាមគេបុកមកមិនឆ្លងទន្លេភ្លាមៗ វានៅពាក់កណ្តាលទន្លេនៅឡើយទេណា ។ ហើយពួកខ្ញុំវានៅរៀបចំ ដែនការហ្នឹងត្រៀមស្បៀងត្រៀមអីរកធ្វើអង្ករធ្វើអីនៅមុំព្រះនន្ទ័លហ្នឹង ហើយបានចេញដំណើរមកទៀត ។ អមមកទន្លេមេគង្គបានឡើងមកលើមក រហូតមកដល់កំពង់ស្រឡៅនេះ ហើយបានចេញមក ដូចខ្ញុំនិយាយមិញចឹង មកដល់បាក់អន្លង់ហ្នឹង អន្លង់វែងទៅលិចចឹងទៅទៅរហូត ។

បូលី : ពូទៅដល់ខាងណាចុងបញ្ចប់?

យឹម : ចុងបញ្ចប់ទៅដល់អីនែក គេហៅអូរអន្លង់ អូរល្ហុង ចម្ការដូង ចម្ការចេក បារាំងធ្លាក់ភ្នំបារាំងធ្លាក់ ។

បូលី : ភ្នំបារាំងធ្លាក់នៅស្រុកអីគេពូ?

យឹម : មិនដឹងស្រុកអីគេទេកាលហ្នឹង ដូចមិនទាន់មានស្រុកទេ ។ ដល់ខេត្តបាត់ដំបងហើយទេមិនដឹង ។

បូលី : ម៉ាឡៃ! សំពៅលូន?

យឹម : ខ្ញុំមិនយល់ដែរ រឿងស្រុកនោះព្រោះខ្ញុំមិនដែលស្គាល់បាត់ដំបងផងចេះតែទៅចឹងទៅ ពូគេថានែកអូរល្ហុក នែកចម្ការដូង ចម្ការចេក ចេះតែតាមគេទៅណា ទៅណារួច(ស្តាប់ពុំបាន) ។

បូលី : ប្រហែលជានៅមុំម៉ាឡៃ ហើយមើលទៅ! ម៉ាឡៃ វានៅក្នុង!

យីម ៖ ភ្នំបារាំងធ្លាក់ ភ្នំអីនោះឯង ។

បូលី ៖ នៅក្នុងបាត់ដំបងដែរចឹង?

យីម ៖ បាទ! (ស្តាប់ពុំបាន) នៅក្នុងខេត្តបាត់ដំបងហ្នឹង ។

បូលី ៖ បារាំងធ្លាក់ ។ ពេលពូធ្វើដំណើរមកនេះ ពូរត់មក ពូមិនឆ្លងស៊ីងត្រែង ពូនៅកន្លែងនេះ? ហើយពូរត់មកដល់ហ្នឹងឆ្ងាយណាស់ ។

យីម ៖ បាទ! ឆ្ងាយណាស់ ។

បូលី ៖ ពេលហ្នឹងនៅក្នុងកំឡុងពេលហ្នឹងពូ ស្នាក់នៅឯណាសិន មុនមកដល់ភូមិចម្ការដូងហ្នឹង?

យីម ៖ ដូចខ្ញុំនិយាយមិញចឹង ដំណើរហូរហែរចឹងមក តាមសរសៀព្រំដែនចឹងឯង ។

បូលី ៖ ប៉ុន្មានខែ បានមកដល់?

យីម ៖ យូរដែរតាំងពី៧៩មក មើលច្រើនខែដែលហ្នឹង ។

បូលី ៖ ខែ៩ ឆ្នាំ៧៩?

យីម ៖ បាទ! មិនដឹងទេ ។ យួនបុកភ្លាមកាលហ្នឹងខែប៉ុន្មាន?

បូលី ៖ យួនបុកចូលខែ១ ។

យីម ៖ អើខែ១ហ្នឹងឯង ។ ចេញពីហ្នឹងរហូតដល់ខែ ខ្ញុំមិនទាន់ដល់កំរៀងភ្លាមទេកាលហ្នឹងនោះ ។ ខ្ញុំទៅនៅម្តុំនោះនែក បន្ទាយឆ្មារ ទៅធ្វើអីបន្ទាយឆ្មា ។

បូលី ៖ ទៅធ្វើអីបន្ទាយឆ្មា នៅម្តុំហ្នឹង?

យីម ៖ នៅស្នាក់ហ្នឹងយូរដែរ នៅបន្ទាយឆ្មា ។

បូលី ៖ ការធ្វើដំណើរតាមឡាន ឬក៏ដើរ?

យីម ៖ ដើរ ដើររហូត ។ គ្នារាប់ពាន់អ្នកនោះដើរ ។

បូលី ៖ ដើររហូតតែម្តង?

យីម ៖ សំណាងហើយមានតែ៨០១ទេ តាំងពីកងពលមណ្ឌលគិរីមកនេះកងពលរបស់នែក អ៊ឹសានក៏មកពីនេះដែរ ។

បូលី ៖ ៩២០?

យីម ៖ បាទ! ៩២០ ។ មកបានដូចតែគ្នាចឹង ភាគច្រើនគឺ បានតែពួកជុំវិញមន្ទីរទេ ។

បូលី ៖ ដើរមក រហូតបានមកស្នាក់នៅស្នាក់នៅបន្ទាយឆ្មារ១រយៈ?

យីម ៖ បាទ! មកនៅបន្ទាយឆ្មារបាន១រយៈ ។

បូលី ៖ គេឲ្យធ្វើអីនៅបន្ទាយឆ្មារ?

យឹម : អត់មានធ្វើអីទេ ព្រោះយើងធ្វើហ្នឹងតម្រូវថាគេច គេចពីកម្លាំងទាហានវៀតណាមហ្នឹងណា គេចរហូតបានន័យថាការពារប្រជាជនដែលនៅជាប់ហ្នឹងខ្លួន ការពារកម្លាំងតែប៉ុណ្ណឹង ។ ធ្វើយ៉ាងម៉េចកុំឲ្យមានកម្លាំងរប៉ះរប៉ោះទៅណា ។ ហើយនាំកម្លាំងរត់គេច ព្រោះកម្លាំងភាគច្រើនកម្លាំងរបស់តាសារឿនទេ មូលដ្ឋានបានមកតិចតួចទេ ។ មកអស់ជាមួយគាត់ ពួកខ្ញុំនោះ ។ ហើយគាត់ហ្នឹងមានមេគេគ្រប់គ្រងហ្នឹងតាមុនសម្រាប់គ្រប់គ្រងរបស់ខាងមន្ទីររបស់តាសឺនសាន នោះ តាសារឿនហ្នឹង តាមុន ។ តាមុនហ្នឹង គឺគាត់! តាសារឿនណែនាំថាម៉េច ការពារកម្លាំងបានកុំឲ្យនរណាម្នាក់ ព្រោះភាគច្រើនសុទ្ធតែនិរសាកងទ័ពនោះ ។ កុំឲ្យនរណាម្នាក់ខ្មាំងចាប់បាន ធ្វើម៉េចការពារប្រពន្ធកូនគាត់ឲ្យបាន និងភារកិច្ចខាងមានតែចឹងទេ មានតែរត់គេចការពារកម្លាំងកុំឲ្យគេចាប់បាន ប៉ុណ្ណឹងឯង ។

បូលី : ចុះការហូបចុកអីនរណាគេអ្នកផ្គត់ផ្គង់ ហូបអាហារ?

យឹម : ចាត់ការខ្លួនឯង ។

បូលី : ធ្វើម៉េចបានៗម្ហូបហូប?

យឹម : ម្ហូបនោះដាក់ស្លែង យើងមករក មានអូរមានអីទៅក៏រកអី ចឹងទៅតាមអូរតាមអីហ្នឹងណាបាទ! គេបាច គេចញ្ចត់អីចឹងទៅ ម្ហូបដោះស្រាយចឹង ។ ហើអំបិលអីតាមដាក់ស្លេងយើងរកភូមិដែលមានប្រជាជន ភាគច្រើនអត់មាននៅទេរត់បាត់អស់ហើយ ។ ដូចម្តុំខ្ញុំនិយាយចឹងព្រះនគ្គលអត់មានមនុស្សបាត់អស់រលីងប្រជាជន ហើយ(ស្តាប់ពុំបាន) ព្រោះកាលហ្នឹងខ្មែរក្រហមយើងគេជម្លៀសប្រជាជនដាក់នៅម្តុំណា មិនមែននៅបាន មិននៅតាមភូមិ ដែលគាត់ធ្លាប់នៅបាន បើគេប្រមូលផ្តុំតែ១កន្លែងៗអស់ ។ ភាគច្រើន អ្នកដែលនៅតាមភូមិចាស់ៗហ្នឹងក៏សុទ្ធតែជាកន្លែងកងទ័ពដែរ ដែលស្នាក់នៅហ្នឹង កងទ័ពរបស់ខ្មែរក្រហមណ៎ ។

បូលី : យើងមានបានដាំដុះស្រូវទេ ពេលដំណាក់កាលនៃការដើរតាមព្រំដែនសរសៀរ?

យឹម : អត់ទេ!

បូលី : អត់ទេណ៎!

យឹម : បាទ! ដាំឯណាបាន បើគេដេញតាមក្រោយគូទរហូត?

បូលី : ប្រហែលខែប៉ុន្មានដែលពូមកដល់ កន្លែងបារាំងធ្លាក់?

យឹម : មកដល់បារាំងធ្លាក់!

បូលី : ខែ១ ឆ្នាំ៧៩ ពូចេញមកហើយណា! ចាប់ផ្តើមឆ្លងទន្លេចេញមក?

យឹម : បាទ! ខ្ញុំមកនៅឯបន្ទាយឆ្មារយូរដែរហើយ ច្រើនខែ ប្រហែលជា២ខែមិនដឹង បានយួនវា វាយមួយសារទៀតមកវាយនៅក្បែរបន្ទាយឆ្មារនេះបានរត់ទៅថៃ ។ ដំបូងថាមិនចូលទៅ ថៃស្រាក់គ្នាថាមិនចូលទេ ចុះខ្លាចថាថៃធ្វើបាប ព្រោះម្យ៉ាងនៅខាងក្រោយនៅព្រំដែនហ្នឹង មានកម្លាំងប៉ុល្ពតនោះ ប៉ុល្ពតពួកតាសឺនសាន បានតាមទុកភ្នំដងរែកហ្នឹងណា ហើយនោម្តុំបន្ទាយឆ្មារ ពយព្រិចក៏មានពួកប៉ុល្ពតនៅដែរ ។ ហើយពួកហ្នឹងហើយដែលបានចាប់ប្រជាជន យើងទៅដែរ ។ អ្នកដែលរត់ជាច់ គឺយកទៅតែម្តង ។

បូលី : ចឹងពូឆ្លងទៅថៃ ឆ្លងតាមច្រកអីគេ ឈូកគគី ឬក៏ច្រកអី?

យឹម : បន្ទាយឆ្មារ មិនដឹងជាទៅច្រកខាងណាទេនេះ ។

បូលី : អត់បានចាំទេណ៎?

យឹម : អត់ចាំទេ!

បូលី : ពួកប៉ុល្ពតនៅម្តុំបន្ទាយអំពិល ម្តុំអី?

យឹម : ទេ! តាមើលដូច បន្ទាយឆ្មារដូចម្តុំឈូកគគីដែលមើលតាមដឹងបើវានៅអាចុងភ្នំយើងដងរែកណា ។ វាចុងប៉ូចហើយដងរែក នៅអាកន្លែងហ្នឹងវាអស់ភ្នំដងរែកហើយ ។

បូលី : វាចូលមកភ្នំក្រវាញវិញ?

យឹម : ភ្នំកំប៉េក កំប៉ុកតូចទេ!

បូលី : ចុងប៉ូច វានៅឈូកគគីហ្នឹងឯង ។

យឹម : អាហ្នឹងហើយតាមមើល ។

បូលី : ចុងប៉ូចគេ ។

យឹម : មានភ្នំណា ។ ភ្នំតូចៗទេ! រត់ឡើងភ្នំសម្រុកចូលដីថៃបណ្តោយ និងដុំគ្នាជាមួយខាងហ្នឹងពួកខាងពាយព្យ ខាងបាត់ដំបងណា ប្រជាជនភាគច្រើនគេមករស់នៅហ្នឹងច្រើនដែរ គេមកនៅហ្នឹងបន្ទាយឆ្មារហ្នឹងឯង ។

បូលី : ពីណាអ្នកគ្រប់គ្រងធំនៅបន្ទាយឆ្មារហ្នឹង?

យឹម : អត់ទេ! តាមអន្តភាពនីមួយៗ ។

បូលី : ចុះអន្តភាពពូពីណាគេ?

យឹម : អន្តភាព ខ្ញុំដូចនិយាយអំបាញមិញចឹង តាមុនហ្នឹង គាត់មេរួមតែម្តង គាត់គ្រប់គ្រង ខ្ញុំចូលអែបជាមួយគាត់កម្លាំងមូលដ្ឋាន៨០០នាក់នោះ ។

បូលី : កម្លាំងតា០៥អីភាគច្រើន មកនៅទន្លេល្ពៅ មកនៅម៉ុំ៣ ហើយពូមកធ្លាយដល់នេះវិញ?

យឹម : ខ្ញុំប្រុបាច់ចូលគ្នាអស់ហើយ មូលដ្ឋានរំលាយចូលគ្នាជាមួយ៨០១អស់ហើយ ។

បូលី : ប៉ុនកងពល ៨០១ គេមកម្តុំគ្នានៅ១០០១នេះ ហើយពូឆ្លាយទៅដល់បន្ទាយឆ្មារនោះវិញ?

យឹម : បន្ទាយឆ្មារដូចខ្ញុំនិយាយអំបាញ់មិញចឹង បន្ទាយឆ្មារបានយួនបុកចូលហើយ ខ្ញុំចូលថៃបណ្តោយ ។ ទៅថៃ បានថៃគេដឹក ទៅកំរៀងនោះ ។

បូលី : ដឹកតាំងពីកំរៀង មកនេះវិញ?

យឹម : បាទ! ដឹកតាំងពីព្រំដែនថៃ-ខ្មែរយើងពីនេះទៅ ពីបន្ទាយឆ្មារនេះទៅ ហើយក៏ដឹកទៅពីនេះទៅទាំងយប់ ។ ១យប់ទល់ភ្លឺ ទៅភ្លឺនៅនោះឯង ។

បូលី : អត់បានសម្រាកដីថៃមួយទេនោះ?

យឹម : អត់ទេ!

បូលី : ចូលភ្លាមដឹកភ្លាមតែម្តង?

យឹម : ទេនៅបាន២ ទៅ៣យប់ដែរ ។

បូលី : បានអីដេកពួនទៅ នៅពេលដែលចូលដីថៃចឹង?

យឹម : វេទនាណាស់ អាហ្នឹងដេកដី ។

បូលី : លើដីតែម្តង?

យឹម : បាទ! គ្មានមុងអីផង ។

បូលី : ហូបចុកអីយ៉ាងម៉េចទៅ?

យឹម : ហូបចុកតាមជាក់ស្តែងចឹងឯង ។ ដែលយើងយកបាន ប៉ុន្មានហូបប៉ុណ្ណឹងទៅ ព្រោះយើងមានស្បៀងត្រៀមរបស់យើងណា ។ មានរបួសដែលតាកាលហ្នឹង របួសស្លាប់មួយចំនួនដែរប្រជាជន តែមិនដឹងខាងណាទេ ខាងខ្ញុំអត់ទេណា ខាងគេទេ ។ កាលហ្នឹងយួនវាមកបំបែកនៅបន្ទាយឆ្មារដល់កន្លែងដែរ ហើយស្កាត់ពីក្រោយកម្លាំង ពីក្រោយមួយចំនួន ចោលផ្ទះ ចោលគោចោលក្របីហើយ ប្រជាជនយើងនៅបាត់ដំបង ដែលគាត់គ្រប់គ្រងគ្នានៅហ្នឹង អាហ្នឹងគេហៅកម្លាំង តាចាយ ហ្នឹងតាលាវ ខាងបាត់ដំបងណា ។ ឈ្មោះ តាចាយ និងតាលាវគាត់គ្រប់គ្រងកម្លាំងគាត់នៅហ្នឹង ។ នៅច្រើនណាស់កម្លាំងរាប់ពាន់នាក់ ហើយកម្លាំងភាគច្រើននៅឯអីម៉ាខ្លៀ នៅឯម្តុំចម្ការល្ហុង ម្តុំចម្ការអូរពេជ្រចិន្តានោះឯង ។ កម្លាំងរបស់តាលាវតាចាយ ។ តាចាយ កាលហ្នឹងដូចគាត់នៅគណៈតំបន់នៅ ពាយព្យក៏មិនដឹង ឬតែគេនិយាយ ។

បូលី : ដល់ពេលមកដល់កំរៀងពូមកនៅណាវិញ?

ឃឹម : មកដល់កំរៀង!

បូលី : ដីថៃ ដីខ្មែរ?

ឃឹម : នៅតាមខ្សែស្រប នៅដីខ្មែរយើង នៅតាមព្រំដែន។

បូលី : ពីណាគេអ្នកគ្រប់គ្រងនៅកំរៀងហ្នឹង?

ឃឹម : គេ! ដូចជាមិនដឹងគេហ្នឹង ដូចជាច្របូកច្របល់ណាស់ ច្របូកច្របល់ខ្ញុំនៅជាមួយអង្គភាពកម្លាំងរបស់តាមុនហ្នឹងគឺ នៅជាមួយតែគាត់ហ្នឹងឯង។ ចល័តរ៉េទៅរ៉េមកដែរហ្នឹង។

បូលី : មានចូលក្នុងកងពលណាទេ?

ឃឹម : អត់ទាន់ចូលឡើយទេ! កម្លាំងរបស់៨០១ គឺរក្សាកម្លាំងរបស់គេតែម្ដុំហ្នឹងតែម្ដង។

បូលី : អត់មានចូលទៅណាទៅណីទេ?

ឃឹម : ខាងនោះដែលមានខាងអង្គការមនុស្សធម៌មកជួយខ្លះ មកជួយជាស្បៀងអាហារណា នៅកំរៀងហ្នឹងមានផ្ដល់ជាស្បៀងអាហារខ្លះហើយ តែមិនទាន់បានច្រើនទេ អាចតាមប្រហែលថៃគេផ្ដល់ឲ្យកាលហ្នឹងនោះ។

បូលី : អាហ្នឹងឆ្នាំប៉ុន្មានពូ ឆ្នាំ៨០នៅ?

ឃឹម : ជិតចូល៨០ហើយ។ អាចខែ៩ ខែ១០ហើយមើលទៅនោះ ព្រោះខែភ្លៀងខ្ញុំដើរ តាមផ្លូវព្រំដែន ជាប់ជើងដីក្រហមនោះ ជាប់ជើងដើរមិនរួចទេ តាមព្រំដែននោះ។

បូលី : ហើយមកម៉េច ទៀតទៅពូ?

ឃឹម : ក្រោយមកដល់៨០! អាចខែ ឬខែ២ដែរតាមមើល ខ្ញុំនៅបាន៥ខែ។ បានគេរៀបចំកម្លាំងពីខាងកើតឲ្យមក នែកគេហៅក្រុមមក១០០១ គេហៅភ្នំ១០០១។

បូលី : ពីណាគេអ្នករៀប?

ឃឹម : កាលហ្នឹង តាម៉ុកអីគាត់មកហើយ។ កម្លាំងភូមិភាគច្រើនកាលហ្នឹង តាម៉ុកគាត់នៅរៀបចំឯលិចនោះឯង។ ហើយរៀបចមកម្លាំងតស៊ូនោះណា បាទ! គាត់នៅចាត់ចែង គាត់នៅរៀបចំកម្លាំងគ្រប់គ្រងទាំងអស់។ គ្រប់មុខសញ្ញាដែលទៅដល់កន្លែងហ្នឹងហើយ គឺវានេរៀបចំឯហ្នឹង។ ហើយពួកខ្ញុំដែលមកពីក្បាសាននេះ គេឲ្យកម្លាំងរបស់កងពល៨០១នោះ ត្រូវធ្វើដំណើរមក១០០១ នេះវិញ។

បូលី : ទាំង១ក្រុមរបស់អង្គភាពអីតែម្ដង?

ឃឹម : និយាយរួមអ្នកមកពីបែកក្បាសានទាំងអស់ទាំងកងរបស់តាសាន ទាំងអីហ្នឹង។

បូលី : ១០០១?

យឹម : បាទ! វិលមក១០០១ ទាំងអស់ ។

បូលី : ជិះអីមក?

យឹម : កាលហ្នឹងថៃ ដឹកមកវិញដែរ ។

បូលី : ជិះឡានតាមថៃ?

យឹម : បាទ! ដឹកមកចូលក្នុងដីថៃមក មកចុះនៅត្រង់ណាទេមកហ្នឹង គិតទៅឡានជិះមួយយប់ដែល គិតទាំងពីយើងពីកំរៀងមក មក១០០១ហ្នឹងណា ។

បូលី : ឆ្ងាយណាស់បើយើងមើលដែនទី ។

យឹម : គិតទៅជិះ១យប់ ទល់ភ្លឺ ឡានខាងនេះគេបិទឃ្ញុបជិត មិនឲ្យនរណាឃើញឡាននោះគេដឹកឡានថៃ ។

បូលី : បិទ! ឃ្ញុបជិតតែម្ដង? មិនហប់ស្លាប់ហើយ!

យឹម : បាទ! បិទឃ្ញុបជិតឈឹង ឡើងណែនក្តាន់ដែលហ្នឹងមួយឡានៗ(ស្ដាប់ពុំបាន) ចេញពីកំរៀងនោះមក ប្រហែលជា៥ ទៅ៦ល្ងាច ,២៧ ចេញពីនោះមក ។ មកដល់ភ្នំ១០០១ គេឲ្យយើងចុះ ភ្លឺល្មម ម៉ោង៥ភ្លឺ ។

បូលី : បាទ! មកដល់យើង រៀបចំចូលកងពលណាខ្លះ ម្តុំរបស់ពូ?

យឹម : កាលហ្នឹងគេឲ្យ កងពលរបស់៨០១ ចូល៨០១ ហើយកម្លាំងដែលបាក់បែក ជួនកាលគេកងទ័ពហ្នឹងក៏កេណ្ឌទន្ទេមកបណ្ដើរៗ ដែលនៅខាងក្រោយហ្នឹងមានតែពួកពិការ អ្នកកាន់កាំភ្លើងហ្នឹង ការពារកម្លាំង គ្រួសារកងទ័ពហ្នឹង ហើយហ្នឹងកម្លាំងកេឲ្យរៀបចំមួយចំនួនថែមមកដើម្បីការពារកម្លាំងហ្នឹង ការពារកម្លាំងរបស់ពួកកងពលនោះ ហើយកម្លាំងល្អភាគច្រើននៅសមរភូមិទេ អត់ទាន់មកទេ ១៩៨០ហ្នឹង ។

បូលី : មកដល់យើងរៀបចំជាភូមិ ជាឃុំអីទេ?

យឹម : អត់ទេ! នៅជាអង្គភាពកងទ័ព ។

បូលី : អង្គភាពណា អង្គភាពដែលទៅ?

យឹម : បាទ! កងពលនៅកងពល៨០១ហ្នឹង ។ កងពល៩២០ ទៅ ហើយគេចែកតាមច្រកៗគ្នានៅនោះ តាម១អង្គភាពៗទៅ ។

បូលី : ហើយយើង មានធ្វើផ្ទះធ្វើសម្បែងទេពេលហ្នឹង?

យឹម : យើងនៅភ្នំដងរែក ១០០១ យើងធ្វើហើយ ។ ផ្ទះតូចៗ ល្មមតែយើងនៅបានហ្នឹងណា ។

បូលី : ប៉ុណ្ណាបើយើង ប្រៀបធៀប?

យឹម : បើប្រៀបធៀបប្រហែល ទ្រើសជម្រុកហ្នឹងតិច ព្រោះយើងនៅក្នុងលក្ខណៈត្រៀមសង្គ្រាម នោះមិនជានៅយុទ្ធសាស្ត្រអី ប្រក់ស្បូវប្រក់អីចឹង ។

បូលី : ប្រក់ស្បូវអីចឹង?

យឹម : បាទ!

បូលី : ជញ្ជាំងអីគេ?

យឹម : ជញ្ជាំងឫស្សី សម្បូរឫស្សីនៅភ្នំ បាំងឫស្សី រនាបឫស្សី ។

បូលី : ហើយកូនអីនៅជាមួយពូដែរ?

យឹម : ខ្ញុំកាលនោះទើបតែមានកូនមួយទេ ។

បូលី : មួយណា?

យឹម : នៅ១០០១នោះ ។ នោះបងនៅនោះ!

បូលី : ប្រុសហេ៎?

យឹម : បាទ! ប្រុស ។

បូលី : នេះអត់ទាន់កើតទេ?

យឹម : បាទ!(ស្លាប់ពុំបាន) ។

បូលី : នេះកើតក្រោយទេ?

យឹម : អាបងនេះកើត៨២ ។

បូលី : ៨២?

យឹម : បាទ!

បូលី : ហ៊ូ! ៨២ស្រករខ្ញុំ ។

យឹម : កើត៨២កាលហ្នឹង!

បូលី : នេះកើតក្រោយមកដល់ត្រពាំងប្រាសាទនេះទេ?

យឹម : បាទ! អានេះត្រពាំងប្រាសាទហើយទេ ។

បូលី : ខាងក្រោយកៅប៉ុន្មាន?

យឹម : ៩៧ហេ៎! ភ្លេចបាត់ហើយ!

បូលី : ហ៊ូ! ៩៧៨នោក្មេងតែមួយ អាយុទើបតែ១៦ ទៅ១៧ហ្នឹង ។

យឹម : ខ្ញុំកូន៧ទាំងអស់ ។

បូលី ៖ ៧?

យឹម ៖ បាទ!

បូលី ៖ ហើយការអស់ប៉ុន្មានហើយ?

យឹម ៖ អស់៣ហើយ នៅ៤ទៀត?

បូលី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យឹម ៖ ប្រុស៣ ។

បូលី ៖ ការសុទ្ធតែប្រុសទាំងអស់?

យឹម ៖ បាទ! ប្រុស២ ស្រី១ការ ។

បូលី ៖ សល់៤ទៀត?

យឹម ៖ បាទ! សល់៤ ។ ប្រុស៣ ស្រី១ទៀត ។

បូលី ៖ ៤ទៀត ធំទន់ដែរហ្នឹង?

យឹម ៖ បាទ! ធំទន់ដែរ ។

បូលី ៖ ការមួយចែកគោយន្តមួយអត់ទេ?

យឹម ៖ (សើច) គ្មានទេ!

បូលី ៖ អ្នកខ្លះគេរាងធូរធារ គេការឲ្យមួយចែកគោយន្តមួយ ហើយដីមួយបូង់ធ្វើស្រែ ធ្វើចម្ការ ទៅ បេះតែរកទៅ ។

យឹម ៖ បាទ!

បូលី ៖ ជួនការគាត់អត់ប្រើ គាត់ទិញត្រៀមទុកតែម្តង ទុកឲ្យកូនតែម្តង ។ ហើយនៅលើភ្នំ១០០១ ហ្នឹង ការហូបចុកយ៉ាងម៉េចពូ ពីណាគ្រប់គ្រង?

យឹម ៖ អាហ្នឹង! របប ការពិត ជំនួយភាគច្រើន គឺមកពីចិននោះឯង ។

បូលី ៖ ចិនហេ៎?

យឹម ៖ បាទ! ចិនគាត់គ្រប់គ្រង ផ្តល់ឲ្យណា ។ ឃើញរបស់តាំងពីសម្លៀកបំពាក់ ស្បៀកជើង មុង ភួយ ហូបចុក ថ្នាំពេទ្យភាគច្រើនពេទ្យតែម្តងយើងឃើញណា ។

បូលី ៖ ជាដូចរបស់ចិនតែម្តង?

យឹម ៖ បាទ! និយាយរួមរបស់ចិនទាំងអស់! និយាយរួម ១កំប៉េ៉តែម្តង ។

បូលី ៖ ចុះម្ហូបអាហារហ្នឹង មានដូចអីខ្លះ?

យឹម : ផ្នែកខាងកងទ័ព ផ្នែកខាងគ្រួសារអាហ្នឹង អំណោយបានមកពីកាកបាទមនុស្សធម៌ ពីអង្គការសហប្រជាជាតិនេះឯងនាំមក! បានតែស្រីៗ និងកូនទេ! ប្ដីគេអត់ឲ្យទេ។

បូលី : ម៉េចចឹង?

យឹម : ប្ដីគេថា គេមិនឲ្យកាលហ្នឹង ឲ្យតែប្រពន្ធហ្នឹងកូន។

បូលី : មកពីអី មកពីប្ដីទាហាន?

យឹម : ប្ដីទាហាន។

បូលី : គេអត់ជួយទាហានទេ?

យឹម : គេអត់ជួយទេ។ ជួយតែប្រពន្ធហើយហ្នឹងកូនទេ ក្មេង និងស្ត្រី។

បូលី : ហ៎ូ! មានរើសអើងទៀត?

យឹម : បាទ! ព្រោះគេមិនឲ្យ ព្រោះយើងយករបស់នោះ ទៅវាយគ្នា ហើយវាមានកម្លាំងវាយគ្នា គេមិនឲ្យទេ។ គេឧបត្ថម្ភតែប្រពន្ធហើយ និងកូន។

បូលី : ជនស៊ីវិល?

យឹម : បាទ! ជនស៊ីវិល ព្រោះអាហ្នឹងយើងគ្រួសារកងទ័ព យើងមិនមែននៅក្នុងនេះទេ។

បូលី : ចុះប្រពន្ធយើងយករបស់ទៅ មិនឲ្យប្ដីហូបដែរ?

យឹម : ទេ អាហ្នឹង វាត្រូវបានហើយព្រោះមេដឹកនាំយើងកាលហ្នឹងវាឆ្លាតដែរណា!

បូលី : គេថាស៊ីវិល អត់ឲ្យចឹងទៅ?

យឹម : បាទ! ចឹង១ផ្នែក បានមកពីហ្នឹង ហើយ១ផ្នែក ភាគច្រើនមកពីចិនតែម្ដង។

បូលី : របស់ដែលគេដែលគេចែកឲ្យ ជាម្ហូបអាហារហ្នឹង មានដូចជាអីខ្លះ ពូអាចរៀបរាប់បានទេ?

យឹម : ឃើញ! មានបើនិយាយទៅ គេមាន បើនិយាយពីប្រហុកឃើញមានអាប្រហុកដួកត្រីកំប៉ុងហ្នឹង ប្រហុកត្រីខ សាច់ប៉ាត់តេ និយាយរួមសុទ្ធតែអាម្ហូបកំប៉ុងគេឧបត្ថម្ភមកហ្នឹង។ ត្រីខសាច់ប៉ាត់តេ ហើយនឹងបន្លែហ្នឹង គឺមានស្ពៃ មានអីចឹងទៅ។

បូលី : ប៉ុន្មានថ្ងៃគេបើកឲ្យម្ដង?

យឹម : ១អាទិត្យម្ដង។

បូលី : ប្រចាំចឹងតែម្ដង?

យឹម : បាទ! អាហ្នឹងផ្នែកខាងមីង១ណា។

បូលី : ហូបគ្រាន់ទេ?

យឹម : ហូបហ្នឹងសល់ផង។

បូលី : សល់ទៀត ។

យឹម : មានឆ្នៀតយកទៅឲ្យថៃវិញនោះ មីង១នៅឯក្រោយនោះ ។

បូលី : ចឹងគេចែកឲ្យច្រើនដែរចឹង?

យឹម : និយាយរួម១គ្រប់ បើនិយាទៅអត់ខ្វះដែលទេ ។ តាមសមាជិកគ្រួសារយើងដែរមាន ។ មានប៉ុន្មានឲ្យប៉ុណ្ណឹង ។

បូលី : ហើយពូត្រូវធ្វើកងទ័ព វាយនៅជួរភ្នំ?

យឹម : បាទ! ជួរភ្នំ ។

បូលី : ពូនៅក្នុងកងពលលេខប៉ុន្មាន?

យឹម : ខ្ញុំ!

បូលី : ៣០១ ដដែរ?

យឹម : កាលហ្នឹងមិនទាន់ចូលទេ! ៨០,៨១,៨២ នេះខ្ញុំនៅធ្វើការជាមួយ នៅ១០០១ ហ្នឹង គេឲ្យនៅធ្វើការមូលដ្ឋាននៅឡើយទេ ខ្ញុំនៅឯ១០០១ គេនៅធ្វើការមូលដ្ឋាន តែខ្ញុំមកធ្វើការនៅស្រុកឆែប ព្រះវិហារ ។

បូលី : អ្ហូ! នៅឆែបហ៎?

យឹម : គេបញ្ជូនចុះទៅខាងក្នុង ទៅកសាងប្រជាជននៅតាមភូមិហ្នឹងណា ។ ពន្យល់ពីរឿង យើងសង្គ្រាមហ្នឹង ។

បូលី : កសាងបានទេពូ?

យឹម : បានដែរតា!

បូលី : ប្រជាជន គេជឿយើង?

យឹម : ជឿ! ១ចំនួនគេប្រឆាំងយើង ហើយ១ចំនួនក៏នៅគាំទ្រយើង ។

បូលី : យើងទៅកសាងគេថាម៉េចខ្លះទៅ?

យឹម : កសាងនិយាយពីរឿងយួនឈ្លានពានអីចឹងទៅណា ។

បូលី : បាទ!

យឹម : យួនយកទឹកដី យកអី ។ មិនមែនមកជួយខ្មែរទេ ទិសដៅគឺយកទឹកដីយើងចឹងទៅ អត្តការអប់រំពីលើទៅណា ។

បូលី : ក្រៅពីយួនយកទឹកដី យើងមានបង្ហាញអំពីប្រធានបទផ្សេងអីទៀតទេ ដើម្បីកសាងគេបាន?

យឹម : បាទ! បង្ហាញពីការតស៊ូរបស់យើងហ្នឹង ។

បូលី ៖ ដើម្បីវាយយួនដដែរហ្នឹង?

យឹម ៖ បាទ! វាយយួនដដែរ ទិសដៅដើម្បីវាយយួនដដែរ ។ កសាងកម្លាំងឲ្យប្រជាជន គាត់ឃើញពីគោលនយោបាយរបស់ខ្មែរក្រហមទេណា ពីអ្នកតស៊ូអីដើម្បីបង្កើនកម្លាំងវាយយួនដដែរ ។ តែប្រជាជនភាគច្រើនគាត់ឧបត្ថម្ភយើងតា ។ មានស្បៀងជាអាហារ លាក់បំពួនអីហ្នឹង ភាគច្រើន គឺគាំទ្រ ចឹងបានយើងមានមូលដ្ឋាននៅឈរជើងបាន ។ អ្នកដែលគេនៅជៀជាក់ខាងនោះ គេនៅតែប្រឆាំងអ្នកខាងព្រៃនេះដដែរទេ អ្នកដែលគេមកគាំទ្រយើង នៅខាងនោះដដែរ ប៉ុន្តែអ្នកដែលគេជៀមកខាងនេះ គេគាំទ្រយើង គេលាក់បំពួនយើង ឧបត្ថម្ភបាយទឹកស្បៀងអាហារហ្នឹង ព្រោះទៅក្នុងយៀងអត់មានយកអ្វីទេបានទេ យើងទៅឆ្ងាយណាស់ពីភ្នំដងរែក ទៅចូលធ្វើការនៅក្នុងនោះ ។ ស្ពាយអង្ករពីនេះទៅបានម្នាក់ ១០គីឡូអីទេ បានមួយធ្វើដំណើរទេ អង្ករនៅក្នុងជាមួយប្រជាជន និយាយរួមធ្វើអំពើល្អហ្នឹងតែម្តង ។ ដល់គាត់ឃើញយើងធ្វើអំពើល្អសព្វបែបយ៉ាងទៅគាត់ស្រលាញ់យើងវិញដែរ ។ អាកំហឹងពីជំនាន់ប៉ុល ពតដែលធ្វើបាបនោះក៏ដូចថាវាសាបរលាបអស់១ចំនួនទៅ ។ ឃើញពីរឿងយួនឈ្លានពានទៅវិញនោះ ។

បូលី ៖ អ្វីដែលយើងយកទៅប្រើ គឺយួនឈ្លានពានតែម្តង?

យឹម ៖ បាទ! (ស្តាប់ពុំបាន) ប្រមូលកម្លាំងដើម្បីតស៊ូ វាយយួនហ្នឹងឯង ។

បូលី ៖ រំដោះទឹកដីនែក?

យឹម ៖ បាទ! រំដោះទឹកដី ឃើញមានប្រសិទ្ធភាពដែរ តែខាងមូលដ្ឋានខ្ញុំអត់មានធ្វើការងារចឹងទេ អត់មានវាយតប់អីទេ ។ ទៅតែរឿងធ្វើនយោបាយហ្នឹងឯង្ស ទៅកសាងកម្លាំងនិយាយឲ្យខ្ចីទៅកសាងកម្លាំង ។ កងទ័ពគិតតែពីរឿងវាយទេ តែក៏មិនធ្វើអីដល់ប្រជាជនដែរ កងទ័ពនោះ ។

បូលី ៖ កសាងកម្លាំង ពួចុះទៅកសាង មានប៉ុន្មាននាក់?

យឹម ៖ ពួកខ្ញុំគ្នា៣០ ទៅ៤០នាក់ដែរហ្នឹងណា ។ គេប្រដាប់អាវុធដែរ ខាងយោធាទេ កាំភ្លើងការពារខ្លួនទេ ។

បូលី ៖ ហើយចុះសម្រាកនៅឯណាទៅ?

យឹម ៖ តាមព្រៃ ។

បូលី ៖ អត់មានធ្វើខ្ទម ធ្វើអីទេ?

យឹម ៖ អត់ទេ! ចងហ្នឹងអង្រឹង កៅស៊ូយើងធម្មតាប្រក់ទៅ ។

បូលី ៈ មិនមូសខាំនាប់ហើយ?

យឹម ៈ មុង!

បូលី ៈ មានមុង?

យឹម ៈ បាទ! មុងអង្រឹងយើងហ្នឹង ។ មុងក្រែយើង ធ្វើជាមុងអង្រឹង ។ សម្រាកតែព្រៃទេ អត់មានផ្ទះសំបែងទេ ។

បូលី ៈ ហើយចានឆ្នាំងអី អង្ករស្ពាយតាមខ្លួន?

យឹម ៈ បាទ! ស្ពាយជាប់ ។ ២ ទៅ៣ថ្ងៃចឹងសម្រាកនៅហ្នឹងទៅ ចល័តទៅកន្លែងផ្សេង២ ទៅ៣ថ្ងៃទៅ ចល័តរហូត ។

បូលី ៈ ចល័តរហូត?

យឹម ៈ បាទ! អត់នៅមួយកន្លែងបានទេ ។

បូលី ៈ ចុះបើនៅមួយកន្លែង?

យឹម ៈ នៅមួយកន្លែងគេមកវាយយើង ដល់កន្លែង ។ ចឹងទាល់តែចល័តរហូត ផ្លាស់ប្ដូរទីតាំងរហូត ។

បូលី ៈ នៅក្នុងព្រៃហ្នឹង នៅកៀកៗភូមិ ឬនៅឆ្ងាយពីភូមិ?

យឹម ៈ បើសភាពការណ៍យើងនៅតាមភូមិមិនសូវ បើល្អណា៎ និយាយរួមខ្មាំងខាងនោះ ទៅចូលមកទេ យើងទៅនៅកៀកហ្នឹងបាន បើភូមិជាប់មាត់ព្រែក ហ្នឹងទៅដេកចម្ងាយពីភូមិប្រហែលជាកន្លះគីឡូអី ចឹងធ្វើបាន ឬក៏២០០ ទៅ៣០០ម៉ែត្រក៏បានដែរ តែអត់បានយូរទេ ។ យ៉ាងយូរបានតែ២យប់អីហ្នឹង ៣យ៉ាងយូរបានផ្លាស់កន្លែងទៀត ។

បូលី ៈ ដែលខាងកងទ័ពខាងវៀតណាម កងទ័ពវៀតណាមវាយទេ?

យឹម ៈ វាយដែរតា ។

បូលី ៈ វាយ!

យឹម ៈ ពេលខ្លះគេស៊ើបការណ៍ គេដឹងកន្លែង គេវាយដល់កន្លែង ។ កំពុងតែដេកអីចឹងទៅ ជិតភ្លឺជិតស្លាប់សឹងតែទាំងអស់ ក៏មានដែរ ។ ចុះបើមិនប្រយ័ត្នណា ។

បូលី ៈ យើងក្រោកមិនទាន់?

យឹម ៈ បាទ! មិនទាន់ទេ! បើដេកលក់ចេះ ហើយអង្រឹងចឹងចងមានមុង គ្រប់ពីលើទៀត កុំឲ្យមូសចាក់នោះ ។

បូលី ៈ មានដែលរត់បោលចានឆ្នាំងទេ?

យឹម ៈ ដែរ ។

បូលី : ដល់រត់ចោលចឹង យើងបានបានអីស្នាក់នៅទៀតទៅ?

យឹម : ទៅរកទិញពីក្នុង ទិញពីប្រជាជនមក ។

បូលី : ទិញមកពីប្រជាជនមកថែមទៀត ។

យឹម : បាទ! ទិញថែមមកទៀត ។

បូលី : ហើយប៉ុន្មានខែបានវិញមកមូលដ្ឋាន មកលើភ្នំវិញម្តង?

យឹម : ១ឆ្នាំ!

បូលី : ចឹងកិច្ចការដែលការគេឲ្យយើងចុះមក មូលដ្ឋានយើងគឺរយៈពេល១ឆ្នាំតែម្តង?

យឹម : បាទ! ១ឆ្នាំ តាមសភាពការជាក់ស្តែង បើសិនជាខាងលើនេះគេត្រូវការទៅរៀនសូត្រ យ៉ាងយូរអី៦ខែ ៧ខែឡើងមកហើយ ។ ប៉ុន្តែវាអត់មានការរៀនសូត្រអីទេ នឹងដល់១ឆ្នាំ ។

បូលី : ចុះយើងបានទាក់ទងគ្នាតាមណាទៅ?

យឹម : តាមសភាពការជាក់ស្តែងដែរទេ បើសិនជាខាងលើនេះគេតម្រូវការ ទៅរៀនសូត្រយ៉ាងយូរ៦ខែ ទៅ៧ខែ ឡើងមកហើយ ។ គ្រាន់តែវាអត់មានការរៀនសូត្រអីទេ នៅហ្នឹងបាន១ឆ្នាំ ។

បូលី : ចុះយើងទាក់ទងគ្នាតាមណាទៅ?

យឹម : តាមតេអូ អាគេហៅអាទូរលេខនោះ អាតេតៗ! ជំនាន់ហ្នឹងប្រើអាហ្នឹងឯង ។

បូលី : អញ្ចឹងបានន័យថាអង្គភាពពូដែលចុះមកខាងក្នុងមានតេអូមួយ?

យឹម : បាទ! មានតេអូហ្នឹងមួយ មិនមែនអាសម្រាប់និយាយទេ គេចុចណា ដូចថាមានកូនជ្រុកវាសម្រាប់ចុចតេតៗ! វាយសារតាមលេខណា ។

បូលី : វាយសារទូរលេខទៅ?

យឹម : បាទ!ហ្នឹងឯង ហើយគេពីនោះមកយើងមានលេខសំងាត់វា បកសារហ្នឹង បានចេញជាអក្សរបាន ទាល់តែរៀនអាហ្នឹងនោះ ។

បូលី : ទាល់គេអ្នកចេះបកដែរហ្នឹងនោះ?

យឹម : បាទ! ទាល់តែរៀនៗ បើយើងអត់ដឹងដែរ មិនដឹងវាយទៅជាស្អី សុទ្ធតែជាលេខទាំងអស់ ប៉ុន្តែលេខស្ថិតនៅក្នុងអាគន្លឹះនោះឯង ។ នៅលើខ្នងអក្សរដែលគេបកមកវិញហ្នឹងណាស្រះអា( ា ) លេខប៉ុន្មាន (ក) លេខប៉ុន្មាន (ង) លេខប៉ុន្មានអីចឹងទៅ វាលេខនៅលើហ្នឹងស្រេច ។ ដល់បកមកវាក្បួនវានៅក្នុងនោះគេបក (ក) លេខអី(ង) ស្រះ(ា) លេខអី ព្យញ្ជនៈអីលេខអីវានៅក្នុងនោះស្រេចតែម្តង ហើយបានគេយកមកផ្គុំចេញជាអក្សរ ។

បូលី : អ្នកវាយ និងអ្នកទទួលទាល់តែចេះដូចគ្នាហើយណ៎?

យឺម ៖ បាទ! ទាល់តែចះ ៗ បើនិយាយពីសំងាត់វិញគេអត់ឲ្យដឹងទៀត អ្នកវាយដឹងតែវាយទេ អ្នកបកសារ ដឹងតែពីបក ព្រោះអាហ្នឹង គេនៅចាប់បានដែរ ។ គេមានប្រពន្ធ័គេចាប់បានដែរ បើយើងធ្វើមិនត្រូវ គេចាប់ចំណុចដែលយើងបកសារហ្នឹងបានគេដឹង ។ គ្រាន់តែយើងវាយបញ្ជូន ហ្នឹងទៅគេចាប់អាសារ ដែលយើងបញ្ជូនទៅគេដឹងតែម្ដង ។ ដូចនេះនៅពេលវាយដឹងតែពីវាយទេ បញ្ជូនសារឲ្យគេ មិនដឹងគេនិយាយពីរឿងអីទេ!

បូលី ៖ ចុះមានដែលខាងលើភ្នំដែលគេនាំម្ហូបអាហារ នាំគ្រាប់អីចុះទៅឲ្យទេ?

យឺម ៖ អត់ទេ! ខ្ញុំស្ពាយទៅខ្លួនឯងតែម្ដង ។

បូលី ៖ អស់ពេលណារកខ្លួនឯងពេលនោះតែម្ដងទៅ ។

យឺម ៖ ដល់ចឹងហើយ(ស្ដាប់ពុំបាន) យើងក៏សុំគេទៅណា ។

បូលី ៖ ចុះពេលហ្នឹងពូ បានចេញពីភ្នំចេញពីអីមកខាងក្នុងដិតភូមិ ជិតឃុំចឹងទៅ ម៉េចក៏មិនរត់ចូលនេះតែម្ដងទៅ?

យឺម ៖ ចូលខាងណា បើកាលហ្នឹងយើងទំនាស់ស្រួចស្រាលស្លាប់រស់ជាមួយគ្នាហើយ ។ ចូលទៅបានន័យថាគេមិនទុកចិត្តយើងខាងនេះ ។ មិនទុកចិត្តយើងទេ អារម្មណ៍បើថាយើងទៅ គឺថាគេធ្វើយើង គេមិនទុកចិត្តយើងទេ ។ គេមិនទុកចិត្តយើង ឲ្យយើងនៅរស់ទេ ។

បូលី ៖ ខាងនេះគេអំពាវនាវឲ្យយើងចូលដែរ?

យឺម ៖ យើងទៅទី១ កសាងកម្លាំងគេ កម្លាំងប្រជាជនមានផែកការគាំទ្រខាងផ្នែកនយោបាយតស៊ូរបស់យើងនេះ ។ ទី២ គឺចលនាកម្លាំងអីមក ទាំងប្រុស ទាំងស្រី ទាំងចាស់ទាំងក្មេង ។ ចលនាកម្លាំងអីមកណា វាមិនមែនតែឃោសនាតែកម្លាំងយើងគាំទ្រទេនោះទេ ។ ទី១ ឃោសនាពីរឿងនយោបាយហើយគាត់មានការគាំទ្រផ្នែកនយោបាយ ការតស៊ូរបស់យើងហ្នឹង ឃើញពីគោលនយោបាយសំខាន់ៗ ដើម្បីយើងតស៊ូរំដោះទឹកដីហ្នឹងវាយជាមួយយួនហ្នឹង ។ ហើយទី២ទៀតចលនាកម្លាំង(ស្ដាប់ពុំបាន) កម្លាំងនោះបានមកភាគច្រើនបន្ត ។

បូលី ៖ មានផែនការទេ ខាងលើគេដាក់ផែនការមកថា១ខែត្រូវតែកសាងឲ្យបានប៉ុន្មានអីចឹង?

យឺម ៖ មានតា!

បូលី ៖ ប៉ុន្មានទៅ ប៉ុន្មានខែ?

យឺម ៖ បើខែ កសាង ព្រោះវិធីកសាង គេកសាងបន្តគ្នា ។ ឧទាហរណ៍ថាកសាងចឹង ម្នាក់ទៅយើងដឹងហើយថាប្រពន្ធ ។ ប្រពន្ធកសាងកូន ហៅថាកសាងបុគ្គល និងគ្រួសារ ហើយបាន

គេពង្រីកក្រុមគ្រួសារទៀត ។ ក្រុមគ្រួសារដែលមានកូនដូចខ្ញុំចឹង នៅអប់រំកូនគេទៅទៀត អាហ្នឹងបន្តគ្នាទៅចឹងទេ ។

បូលី : កសាងបុគ្គល និងកសាងគ្រួសារ ។

យឹម : កាសាងគ្រួសារ ។ ដំបូងយើងទាញបានតែប្ដី ឬក៏ប្រពន្ធទេ ទម្រាំតែគេគាំទ្រនយោបាយយើង គឺពន្យល់ប្ដីឲ្យគាត់យល់សព្វគ្រប់ សព្វបែបយ៉ាងហើយ បានប្រពន្ធទៅនិយាយជាមួយប្ដី ឬក៏ប្ដីទៅនិយាយជាមួយប្រពន្ធ ។ ពីរនាក់ឯកភាពគ្នាហើយ បានទៅនិយាយជាមួយកូន ។

បូលី : អាហ្នឹងជាមេរៀន ដែលគេបង្ហាត់ចឹងមកតែម្ដង?

យឹម : វាវិធីសាស្ត្រក្នុងការកសាងវាច្រើនយ៉ាងដែរ ។

បូលី : មានវិធីសាស្ត្រអីច្រើនទៀតទេពូ?

យឹម : មានច្រើនទេតដែលទៀតហ្នឹងណា ។

បូលី : ពូអាចជួយ ក្រៅពីកសាងបុគ្គល គ្រួសារហ្នឹង ។

យឹម : អាហ្នឹងដូចហៅថាកសាងពី១ទៅ២ ទៅ៣ ទៅ៦ហ្នឹងណា ក្នុងមេរៀនដែលធ្វើការនយោបាយច្រើនដែរ ។ រូបមន្តច្រើនដែរ ភ្លេចអស់ហើយតែចាំបានតែប៉ុណ្ណឹងទេ ។

បូលី : បើរូបមន្តល្អតែម្ដង នៅចាំរូបមន្តនោះអត់ ២,៦នោះ?

យឹម : បានន័យថា២,៦! ពីម្នាក់ទៅ ម្នាក់ណា ហើយបានរីកពី២ ទៅ៣នាក់ចឹងទៅ៦នាក់ចឹងទៅ ។

បូលី : (ស្ដាប់ពុំបាន)!

យឹម : ៣ ទៅ៦ ។

បូលី : ៣ទៅ៦?

យឹម : បាទ!

បូលី : បានន័យថា៣ ទៅ៦?

យឹម : បាទ! ៣តគ្នា ។

បូលី : ៣ហ្នឹង នរណាគេខ្លះ៣ហ្នឹង?

យឹម : ៣ហ្នឹង ឧទាហរណ៍ដូច ខ្ញុំប្ដីប្រពន្ធសោះបាន បង្រៀនទៅកូនទៅណា ហើយទៅកូនតគ្នាទៅ ហើយតទៅអ្នកដទៃទៀតមិនមែនសាច់ញាតិយើង ដែលយើងរាប់អានគ្នា ស្គាល់ទុកចិត្តគ្នាក៏យើងកសាងបានដែរ ។ គេហៅថាកសាងរបៀបខ្នូតស៊ុំឈើ ។

បូលី : គេហៅអីទេពូ?

យឹម : ខ្នូតស៊ុំឈើ ។

បូលី  :  គេហៅភាសារចិនតែម្តង?

យីម  :  គេហៅតែចិន ។

បូលី  :  យ៉ាងម៉េច ខ្មុតស៊ីឈើហ្នឹង?

យីម  :  ព្រោះធម្មតា ខ្មុតវាស៊ីឯខាងក្នុង ឯខាងក្រៅ រូបភាពវាល្អ ។ ខាងក្នុងវារលួយ រលះអស់ ។

បូលី  :  បានន័យថាខាងក្រៅស្អាត សសស្អាតចេះ?

យីម  :  វាចូលទៅខាងក្នុងវាស៊ីអស់ហើយ អាហ្នឹងវាប្រៀបបានហ្នឹងខ្មុតទៅស៊ីឈើតា ។ បាទ! វាអង្កៀមស៊ីម្តងបន្តិចៗ ស៊ីទាល់តែអស់ ។ អាហ្នឹងវិធីកសាងអីចឹងឯង កសាងរបៀបខ្មុតស៊ីឈើ ។ (ស្តាប់ពុំបាន) សម្ងាត់ ។

បូលី  :  ហេតុអីបានសម្ងាត់យ៉ាងម៉េចទៅ?

យីម  :  យើងបែកគ្នាពុំបានទេ ព្រោះខាងនោះគេឃ្លាំមើលយើងដែរ ។ អ្នកដែលធ្វើការហ្នឹងគឺប្រយត្ន័ណាស់ ។ តែបែកហួងហើយ នៅអត់បានទេ គឺចូលព្រៃនោះឯង ។ កម្លាំងដែលចូលគឺភាគច្រើនកម្លាំងដែលបែកហួងហ្នឹងឯង ។ ចឹងកងខេមរភូមិន្ទយើង មិនមែនអាជ្ញាធរដែនដីខាងក្នុងមិនមែនឲ្យយើងនៅ នៅបានគេដឹង គេរករឿងយើងអ្នកគាំទ្រខាងនេះណា៎ ចឹងយើងមិនអាចដឹងបានទេ តែបែក គឺក្នុងព្រៃហើយ ។

បូលី  :  ភាគច្រើនអ្នកដែលនៅខាង អ្នកដែលរត់ចូលព្រៃគឺអ្នកដែលបែកកសាងបានហើយហ្នឹង ទទួលនាទីកសាងបន្ត ហើយយុវជនដែលមកនេះ មកស្រើបស្រាលតាមគ្នាទេ ជាការស្រលាញ់គ្នាវវាងកងទ័ពខាងនេះ នារីនោះចឹងទៅណាអាហ្នឹងជាមនោសញ្ចេតនាទេនោះ ។ តែបើកម្លាំងផ្ទៃក្នុងនោះគឺ បែក តែបែកហើយគឺនៅមិនបានទេ ។

យីម  :  យើងកសាងកម្លាំងផ្ទៃក្នុងណ៎?

បូលី  :  បាទ!

យីម  :  ព្រោះវាហ្នឹង វាសម្ងាត់ ។

បូលី  :  មានដែលបែកការទេ?

យីម  :  បែកភាគច្រើន រកអ្នកធ្វើការនៅខាងក្នុង ខាងអី គេហៅថាកម្លាំងស្នូលរបស់យើងគាត់មិនអាចរក្សាការសម្ងាត់ហ្នឹងបាន គេតាមដានយើងដែរណា វាបែកតែបែកហើយរករឿងភ្លាមអត់នៅយូរបានទេ ។

បូលី  :  ក្រៅពីវិធីសាស្ត្រខ្មុតស៊ីឈើ តើមានវិធីសាស្ត្រអីផ្សេងទៀតទេ? ខ្មុតស៊ីឈើអាចមានប្រែះស៊ីដែកទេមើលទៅ?

យឹម : ប្រហាក់ប្រហែលគ្នា ។

បូលី : ព្រោះកាលហ៊ុន សុិនប៊ិច គេទើបចូលមកថ្មីៗ គេថាវិធីសាស្ត្រគេច្រែះស៊ីដែក ស៊ីបន្តិចម្តងៗ ។

យឹម : ខ្ញុំមិនដែលឮទេអាហ្នឹង ។

បូលី : មានទៅច្រែះស៊ីដែកណា ដែកស៊ីច្រែះវិញ ។

យឹម : អាហ្នឹងបើច្រែះស៊ីដែក ដែកហ្នឹងវាបន្លាញ អាច្រែះហ្នឹងវាឃើញបន្លាញរូបភាពដែកនៅក្រៅហ្នឹង ។

បូលី : ទៅឃើញច្បាស់ក្រលែតនោះ ។

យឹម : ឃើញច្បាស់ក្រឡែត មានលាក់ការអត់ទេ ។ ស៊ីដាច់ហរ!

បូលី : ស៊ីដាច់ហណ៌ពូ?

យឹម : បាទ!

បូលី : បើប្រើវិធីសាស្ត្រខ្ទួតស៊ីឈើអាចជោគជ័យកាលហ្នឹង ។

យឹម : បាទ! ជោគជ័យជាងកាលហ្នឹង សម័យខ្មែរក្រហមអត់ប្រើទេ អារបៀបច្រែះស៊ីដែកហ្នឹង ។

បូលី : ច្រែះស៊ីដែកហ្នឹងឃើញច្បាស់ក្រឡែតហ្នឹង ។

យឹម : បាទ! ច្បាស់ថែស ។

បូលី : ដល់ចឹងគេខាត់ចោលបាត់ លាក់ការ!

យឹម : ការពារខ្លួនម៉េចបានបើរូបភាពដែលយើង ធ្វើសកម្ម ភាពដើម្បីចំហរ ពេញធឹងទៅហើយ ។ ហើយយើងទៅធ្វើការនៅក្នុងគេហៅថាក្នុងសំបុករបស់ សត្រូវដែលគេកំពុងតែតាមរកអាហ្នឹងរបៀបទៅធ្វើមិនបានទេ ។ ធ្វើរបៀបគាត់ធ្វើផាប់ខ្លួន ឯងតែម្តង ។

បូលី : ចឹងបានបរាជ័យ?

យឹម : បាទ!

បូលី : ពូអាចនឹកឃើញពីមេរៀនអីដូចថាល្អចឹងពូ ព្រោះវាល្អណា ខ្ញុំចាប់អារម្មណ៍តែម្តងអារឿងវិធីសាស្ត្រខ្ទួតស៊ីឈើហ្នឹង ។ មានវិធីសាស្ត្រអីផ្សេងទៀតដែលពូអាចនឹកឃើញទេ? សាកនឹកមើលបន្តិចមើលពូ?

យឹម : វាយូរដែរទៅហើយ ការតស៊ូរហ្នឹងវា ខ្ញុំបើនិយាយពីរឿងរៀនអប់រំចឹងយើងនឹកឃើញរឿងនយោបាយយើងត្រូវការអប់រំពង្រឹងស្មារតី ពង្រឹងយុទ្ធសាស្ត្រថ្មីៗរហូត ដើម្បីដំណើរការធ្វើការតស៊ូរហ្នឹងឲ្យវារីកចម្រើននោះ ។

បូលី  :  អ្នកណាគេអ្នកបង្ហាត់អាវិធីសាស្រ្តខ្វួតស៊ីឈើ?

យឹម  :  ខ្ញុំមិនដឹងថាច្រកយើងអាខាង១០០១ហ្នឹង តាសុន សេនហ្នឹង។

បូលី  :  តាសុន សេនហ្នឹងតែម្តង?

យឹម  :  បាទ! តា សុន សេន គាត់អ្នកបង្ហឹក ទាំងផ្នែកការងារមូលដ្ឋានទាំងផ្នែកយោធាហ្នឹងណា បាទ នៅលើគាត់ហ្នឹងឯង។ តាសុន សេន គាត់ទទួលច្រក១០០១ហ្នឹង។

បូលី  :  បាទ! គាត់អ្នកបង្ហាត់?

យឹម  :  បាទ!

បូលី  :  មុនពេលចូលមកពូ ពូទទួលការបង្ហាត់ពីគាត់ផ្ទាល់ ឬក៏បន្តពីអ្នកផ្សេងវិញ?

យឹម  :  អត់ទេ! គាត់ផ្ទាល់តែម្តង។

បូលី  :  រៀនប៉ុន្មានថ្ងៃបាន យើងចុះមកខាងក្រោម?

យឹម  :  រៀនដួនកាល ១ថ្ងៃ ឬក៏៣ថ្ងៃអីចឹងទៅ។

បូលី  :  រៀន២ ទៅ៣ថ្ងៃដែរ។

យឹម  :  បាទ! រៀននៅអីលើនេះភ្នំដងរែកហ្នឹងណា រៀនចំរុះទាំងកងទ័ព ទាំងអ្នកធ្វើការមូលដ្ឋានហ្នឹង រៀនចំរុះគ្នាទេ។

បូលី  :  នៅជីឯនោះ?

យឹម  :  ទៅទីតាំងយើង! រៀនចំរុះគ្នាទេ។

បូលី  :  នៅជីថៃឯនោះ?

យឹម  :  អត់ទេ! នៅមូលដ្ឋានយើងភ្នំដងរែក ទីតាំងយើង។ នៅភ្នំដងរែកនៅជី នៅកន្លែងយើង មូលដ្ឋានយើងហ្នឹង។

បូលី  :  ចុះយុទ្ធសាស្រ្តកងទ័ពវិញពូមានចាំទេ ពេលគាត់បង្រៀន អាហ្នឹងយើងប្រើយុទ្ធអី កងទ័ព យើង?

យឹម  :  កងទ័ពគេ និយាយផ្សេងទេអានោះ។ គេមានយុទ្ធសាស្រ្តរបស់គេផ្សេង។ អានោះគេ និយាយជាមួយមេៗ គេមិនចំហបានទេអាហ្នឹងនោះ។ បើចំហ គេបែកខាងទាហាន កងទ័ព។

បូលី  :  មីន នៅខាងលើនេះទេ?

យឹម  :  បាទ!

បូលី  :  ពូចុះទៅខាងក្នុង។

យឹម ៖ ខ្ញុំចុះទៅខាងត្បូង បានយ៉ាងយូរណាស់ ១០ថ្ងៃ កន្លះខែមិនចង់បានផងមកលើ ។ មកគ្រាន់តែរៀនសូត្រហើយចប់ទៅវិញបាត់ ។

បូលី ៖ អត់ដែលបាននៅយូរទេចឹង? ក្រែងគេមានវេនគេចឹង?

យឹម ៖ អត់មាន!

បូលី ៖ ១ឆ្នាំ វេនពូទៅ?

យឹម ៖ អត់ទេ! អត់មានវេនទេ! កម្លាំងយើងវាតិច ។

បូលី ៖ ត្រូវចុះទៅរហូតតែម្ដង?

យឹម ៖ បាទ! ទៅរហូត ។

បូលី ៖ បែកពីប្រពន្ធកូនទៅរហូត?

យឹម ៖ បែករហូត! អត់បាននៅជុំគ្នាទេ ។

បូលី ៖ មកបានប៉ុន្មានថ្ងៃ?

យឹម ៖ មកបានកន្លះខែទៅវិញហើយ ។ មិនចង់បានផងកន្លះខែនោះ យ៉ាងយូរ១០ថ្ងៃ ។

ប្រពន្ធយឹម៖ ប្រពន្ធមានកូនខ្ចី នៅជាមួយអ្នកជិតខាងទៀត ។

យឹម ៖ តែកាលហ្នឹងយើងនិយាយពីការរស់នៅរបស់ប្រពន្ធកូនក្រោយ វាមិនព្រួយបារម្ភ ។ ការហូបចុកគ្រប់គ្រាន់ ឈឺស្កាត់អីថ្នាំពេទ្យគេមិនយកលុយទេ ។

បូលី ៖ អាហ្នឹងជាការលើកទឹកចិត្តមួយដែលមែនទេ?

យឹម ៖ ពួកទាហាន! កាលហ្នឹងខ្មែរក្រហមមានលុយឯណាចាយ បើទៅធ្វើការដោយទឹកចិត្ត លះបង់អាយុជីវិតដោយគ្មានគិតពីរឿងលុយកាក់ប្រាក់ខែអីទេ ។ ទៅហ្នឹងទៅ ដូចថាដាច់ខាតតែម្ដងណា ព្រោះបើមិនរៀបចំប្រពន្ធកូននៅខាងក្រោយនេះអត់មានជីវភាពរស់នៅ ហូបចុកគ្រប់គ្រាន់ទេ អ្នកទៅធ្វើការមុខក៏អត់រីករាយដែរ ។

បូលី ៖ អារម្មណ៍អត់មូលទេ?

យឹម ៖ បាទ! មិនមូលព្រោះឃើញប្រពន្ធកូននៅខាងក្រោយមិនដឹងជាបានហូបអី គ្រប់គ្រាន់ ឬក៏ខ្វះខាត មិនដឹងជាឈឺគ្រុនយ៉ាងម៉េច ថ្នាំសង្កូវព្យាបាលយ៉ាងម៉េច ចឹងអ្នកខាងក្រោយនេះខាងមូលដ្ឋាន អាខាងក្រោយនេះ គេយកចិត្តទុកដាក់ណាស់ ។ គេមិនឲ្យពិបាកទេ! ១អាទិត្យបើអង្ករម្ដង ហូបសល់យកទៅលក់ទៀត ។ អាគេឲ្យសោះហ្នឹងណា ។

ប្រពន្ធយឹម៖ ខោអាវ បើក១ឆ្នាំ២ដង ។

យឹម ៖ ខោអាវ១ឆ្នាំ២កំប្លេ ហើយម្ហូប ១អាទិត្យ ហើយ១០ថ្ងៃបើកម្ដង ។

បូលី ៖ ចុះពូ ពេលដែលទៅខាងក្នុងពេលឈឺថ្កាត់អីយ៉ាងម៉េចដែរទៅ?

យឹម ៖ ថ្នាំពេទ្យយើងម្ចាស់ការយើងដោះស្រាយ ។ ពេទ្យមាន!

បូលី ៖ ពេទ្យគេទៅតាមតែម្តង?

យឹម ៖ បាទ! នៅតាមសមរភូមិមានរបស់គេស្រេច ពេទ្យតាមសមរភូមិមានរបស់គេស្រេច មិនឲ្យលំបាកទេ ។

បូលី ៖ ចុះពេលមានដែរ ដើរជាន់មីនជាន់អីទេ?

យឹម ៖ មានតា! សំខាន់មីនដែលគេដាក់ កាត់តាមផ្លូវហ្នឹងយួន ។

បូលី ៖ ញឹកញាប់ ឬម្តងម្កាល?

យឹម ៖ មិនជាញឹកញាប់ទេ ម្តងម្កាលទេ ។

បូលី ៖ ដល់ជាន់ចឹងទៅពេទ្យដែលទៅតាមហ្នឹង មានលិទ្ធភាពអាចព្យាបាលបានទេ អ្នកជិតាញ?

យឹម ៖ ដល់ផ្តាច់ខ្លួន មានតែសែងយក មកមូលដ្ឋានហ្នឹងឯង ។ យកមកនេះ ពេទ្យធំខាងលើនេះ ។

បូលី ៖ អឹចាម៉េចមិញ?

ប្រពន្ធយឹមៈ ចងការ៉ូ!

បូលី ៖ ចងការ៉ូ?

ប្រពន្ធយឹមៈ ចងការ៉ូ ខ្សែកៅស៊ូខាង ដាច់ត្រឹមនេះចងត្រឹមនេះទៅ បើថាដាច់ត្រឹមនេះចងត្រឹមនេះមក

បូលី ៖ ចងកុំឲ្យឈាមហូរ?

ប្រពន្ធ ៖ ចងកុំឲ្យឈាមចេញ ។

យឹម ៖ បើមីនស្គរតូចរបស់ចិននោះ ។ ដាច់ត្រឹមៗនេះទេ អស់ជើងត្រឹមនេះ សល់ពីនេះទៅ!

ប្រពន្ធយឹម ៖ គេកាត់រំលាយសសៃ ។

យឹម ៖ បើមីនស្ទាច់ បុកទៅទៀត អាក្រហម អាធំនោះ អាហ្នឹងសោយដល់នេះឯង ។ ខោអាវ ១ឆ្នាំ ២កំប្លេហើយម្ហូប មួយអាទិត្យ ឬ១០ថ្ងៃ បានបើកម្តង?

ប្រពន្ធយឹម ៖ មួយអាទិត្យ ។

បូលី ៖ ចុះពូពេលដែលទៅខាងក្នុងពេលដែលឈឺថ្កាត់អីយ៉ាងម៉េចទៅ?

យឹម ៖ ថ្នាំពេទ្យយើងម្ចាស់ការពីនេះទៅស្រេចពេទ្យគេមាន ។

បូលី ៖ ពេទ្យគេទៅតាមតែម្តង?

យឹម ៖ បាទ! មានពេទ្យគេស្រេចអត់លំបាកទេ ។

បូលី ៖ ចុះពេលមានដែលដើរជាន់អីទេ?

យីម ៖ មានតា! សំខាន់មីនដែលគេដាក់តាមផ្លូវហ្នឹងយួន ។

បូលី ៖ ញឹកដាប់ ឬក៏ម្តងម្កាល?

យីម ៖ មិនដាញឹកញាប់ទេ ម្តងម្កាលទេ ។

បូលី ៖ ដល់ជាន់ចឹងទៅពេទ្យដែលទៅតាមហ្នឹង មានលទ្ធិភាពអាចព្យាបាលបានទេ អ្នកជាន់មីនហ្នឹង?

យីម ៖ ដល់ដាច់ជើង សែងមកមូលដ្ឋានឯក្រោយហ្នឹងឯង ។

ប្រពន្ធយីម៖ ចុះឯក្រោយហ្នឹងឯង វាណែន ។

យីម៖ ពេទ្យឯលើយើងហ្នឹង ពេទ្យធំហ្នឹងនេះ ។

បូលី ៖ អ៊ឹចាម៉េច ចង់អីមេញ?

ប្រពន្ធយីម៖ ចង់ការ៉ូ ខ្សែកៅស៊ូយើងហ្នឹង ដាច់ត្រឹមនេះ ចងឯនេះទៅបើ ថាដាច់ដល់នេះចងអានេះមកកាត់ឯនេះ ។

បូលី ៖ ចងកុំឲ្យកំឲ្យឈាមហូរ ។

យីម ៖ ដូចអាមីនស្តុរបស់ចិននោះ ប្រហែលត្រឹមនេះ អស់ត្រឹមជើងត្រឹមនេះ ត្រឹមនេះនៅ គេកាត់លាសសៃមកបានកាត់ត្រឹមនេះ ។ បើមីនស្ទាច់វាបុកទៅទៀត វាអាមីន អាក្រហមអាធំនោះ អាហ្នឹងសោយដល់នេះឯង ។

បូលី ៖ មីនពេលដែលវាផ្ទុះខ្ទេចឆ្អឹង ឬក៏សោយតែសាច់ទេ?

យីម ៖ បាទ!មិនស្តុរអាតូចហ្នឹងអស់ដែលហ្នឹងអាប្រអប់ជើងស្បែករយ៉េរយ៉ៃទៅណា ។ អាមីនរបស់ចិននោះតូច ។ មីនមាន២ធី អាមីនរបស់ចិននោះប៉ុណ្ណោះទេ អាមីនខៀវនោះណារបស់សូវៀតអារបស់យួននោះធំ អាក្រហមនោះ ។

បូលី ៖ អាម៉េចទៅវាសោយសាច់ឡើង?

យីម ៖ សោយឡើងតែម្តង អានោះធំខ្លាំងណាអានោះ ។

បូលី ៖ ឆ្អឹងសស្វាញតែម្តង?

យីម ៖ ខ្ទេចទាំងឆ្អឹងទៀតហ្នឹង ។

បូលី ៖ ខ្ទេចទាំងឆ្អឹងទៀត?

យីម ៖ បាទ! អានោះសោយបានហ្នឹងឯង ។ ជួនកាលទាំងពីរហ្នឹងឯង ជើងដាច់ ។

បូលី ៖ ប៉ុនអំដាច់ទេ?

យីម ៖ ទេ! បើមិនចងវុំដូចម៉េចហ្នឹងគឺស្លាប់គាត់ចឹង ស្លាប់!

ប្រពន្ធយីម ៖ មិនចងស្រែកដូចទឹកដូចអី ឆាប់ហើយ ។

យឹម ៖ ព្រោះអីវាដាច់សរសៃឈាមហើយ ទាល់តែចងការូ ។

ប្រពន្ធយឹម ៖ ចងឲ្យណែនទៅ វាអត់ ។

បូលី ៖ ក្រុមរបស់ពូដែលចុះទេហ្នឹងវាមានបានជួបប្រទះរឿងណាខ្លះៗទេ?

យឹម ៖ មាន ។

បូលី ៖ ដល់ពេលជួបប្រទះចឹងទៅ ធ្វើម៉េចទៅ?

យឹម ៖ របួសស្រាលៗ អត់មានព្យាបាលគេកាលហ្នឹង នៅសមរភូមិហ្នឹងឯង របួសដាច់ជើងទាល់តែយកមកវិញ ។

បូលី ៖ សែងមក?

យឹម ៖ បាទ! ចាត់កម្លាំងសែងយកមកក្រោយវិញ ដាក់មក មកតែម្តង ។

បូលី ៖ បានប៉ុន្មានថ្ងៃបានមកដល់?

យឹម ៖ តាមទីជិតឆ្ងាយ ។

ប្រពន្ធយឹម ៖ ពេទ្យដាក់សារ៉ូម ដាក់អីតាមផ្ទះ ឬស្សីអី ។

យឹម ៖ បើយើងពីភ្នំដងរែកទៅ ទៅធ្វើការនៅកំពង់ធំអី ឆ្លងទៅខាងទន្លេនោះដើររាប់ខែនោះណា ។

បូលី ៖ ដើររាប់ខែរទម្រាំដល់ប្រាសាទ?

យឹម ៖ តែបើថាដល់មូលដ្ឋានក្នុងតំបន់មានពេទ្យគេធំនៅហ្នឹងតែម្តង ។

បូលី ៖ មកដល់ណាវិញ?

យឹម ៖ មកដល់កន្លែងមូលដ្ឋានកន្លែងកងទ័ពធ្វើការចំរុះណា មានប្រធាន មានកងពលគេនៅប្រចាំការហ្នឹងមានពេទ្យគេសម្រាប់វះកាត់នៅហ្នឹងបណ្តោយ អត់បានទេ ។ តែបើយើងកំពង់ធ្វើដំណើរចឹង ឧបសគ្គតាមផ្លូវ អាហ្នឹងបកមកក្រោយហើយ ។ ទៅមុខក៏ឆ្ងាយ ទៅក្រោយក៏! ម្លោះក៏មានបកមកក្រោយ ។

បូលី ៖ ហើយពូចុះទៅហ្នឹង ក្រៅពីស្រុកខែបមានទៅណាទៀតទេ?

យឹម ៖ ខ្ញុំទៅធ្វើការឡូទៅអីខាងជាប់ព្រំដែនលាវ អីកំពង់ស្រឡៅ ។

បូលី ៖ កំពង់ស្រឡៅ?

យឹម ៖ កំពង់ស្រឡៅ កំពង់ឥន កំពង់សាមី អីនោះ ។

បូលី ៖ ខេត្តអីហ្នឹង?

យឹម ៖ នៅក្នុងខេត្តព្រះវិហារអីជៃរគា គេហៅស្រុកកំពង់ស្រឡៅនោះ ពីដើមគេហៅស្រុកសម្រិតតែស្រុកហ្នឹងវានៅក្នុងស្រុកខេត្តទេ ។

បូលី ៖ ក្នុងដែរបងដែរទេ?

យីម ៖ បាទ! ប៉ុន្តែគេចែកហើយមិនដឹង?

បូលី ៖ មានដែរចេញពីធ្វើទាហាន ទៅខេត្តផ្សេងទេ?

យីម ៖ អត់ទេ!

បូលី ៖ នៅតាមតំបន់ព្រះវិហារហ្នឹងទេ?

យីម ៖ បាទ! ខ្ញុំមកដល់២០០០ មើល២០០០ប៉ុន្មានទេ បានចូលមកកងទ័ពនេះ ហើយខ្ញុំធ្វើការមូលដ្ឋានហើយ ខ្ញុំរំលាយខាងកងមូលដ្ឋានឲ្យចូលមកធ្វើការកងទ័ពវិញនោះ ទាល់មុខ៨០២ ។

បូលី ៖ ៨០២ណ៎! របស់តាណា?

យីម ៖ តាឆន ។ តាឆនហ្នឹងគាត់ត្រូវជាប្អូនថ្លៃរបស់តាសុន សេន ។

បូលី ៖ ៨០២ហ្នឹង បំបែកចេញពី៨០១?

យីម ៖ បំបែកចេញពី៨០១ ។

បូលី ៖ ចុះហេតុម៉េចបានជាគេបំបែកច្រើនម្ល៉េះ?

យីម ៖ អាហ្នឹងដកចេញពីវរសេនាធំ ដកចេញពីវរសេនាធំគ្រប់អង្គភាពហ្នឹងណា ពី៨០១ហ្នឹង ។

បូលី ៖ ដល់ពេលចូលមក៨០២ហ្នឹង គេបញ្ជូនពូទៅខាងណា?

យីម ៖ ក្នុងកងពល៨០២ហ្នឹងឯង ធ្វើការនៅកំពង់ធំ ។

បូលី ៖ កំពង់ធំ?

យីម ៖ បាទ!

បូលី ៖ កំពង់ធំនៅតំបន់ណាពូ?

យីម ៖ កំពង់ធំនៅតំបន់ ខ្ញុំគេឲ្យទៅធ្វើការនៅស្រុកនែក ស្រុកឡើងទៅលើស្រុក ។

បូលី ៖ ស្រុកស្ទោង?

យីម ៖ មិនមែនទេ! ស្រុកសណ្ដាន់ ។

បូលី ៖ អូ៎! ទៅសណ្ដាន់វិញហ៎?

យីម ៖ បាទ!

បូលី ៖ ទៅសណ្ដាន់មកគៀកព្រំដែនជាមួយភ្នំដី?

យីម ៖ បាទ! ភ្នំដីហ្នឹងឯង ។

បូលី ៖ សម្បូរវិញណ៎?

យីម ៖ អាហ្នឹងមកជាប់ព្រះវិហារហ្នឹងឯងអាហ្នឹងហើយនោះ ។

បូលី  :  មកជាប់ព្រំដែននៅព្រះវិហារ?

យឹម  :  បាទ! ស្រុកសណ្ដាន់ម៉ុំទាហានដែរ ។ ខ្ញុំចូលកៅហើយមិនដឹងទៅ ។

ប្រពន្ធយឹមៈ  កៅហើយ ៩៣,៩៤ហើយ ។

យឹម  :  ទេ!  នៅក្នុងកៅអីទេយាយ! នៅក្នុង៨៧,៨៨ឥលូវហ្នឹងទេហ្នឹង ។

ប្រពន្ធយឹមៈ  ៨៧,៨៨! មីអូនដុតគេ៩៧ហើយ ។

បូលី  :  គៀកក្របេះអត់ពូ?

យឹម  :  អត់ទេ! ក្របេះណានៅនេះ ។

បូលី  :  សណ្ដាន់!

យឹម  :  សណ្ដាន់ខាងនៅជើងកំពង់ធំ ។

ប្រពន្ធយឹមៈ  នៅជិតកំពង់ចាម ខាងកម្មាយមារហ្នឹង ។

យឹម  :  មកតាមផ្លូវឆៀតលេងអ៊ុកហ្នឹង ប៉ុន្មានមកព្រះវិហារណាស់ ។

បូលី  :  ព្រះវិហារដូចជា៦២, ៦៣!

យឹម  :  ផ្លូវជាតិឥលូវគេធ្វើថ្មីហើយ មកម៉ុំអូរពោធិ៍អីនេះ ។

បូលី  :  ចុះមកកំពង់ធំមករយៈពេលប៉ុន្មាន?

យឹម  :  មកនៅហ្នឹង?

បូលី  :  បាទ!

យឹម  :  ខ្ញុំទៅធ្វើការនៅកំពង់ធំខ្ញុំតាំងពីកងពលខ្ញុំនៅហ្នឹងតែម្ដង ។

បូលី  :  ទៅ៨០២?

យឹម  :  បាទ! ទៅ៨០២តែម្ដង ។

បូលី  :  ពេលហ្នឹង១០០១បែកនៅ?

យឹម  :  ១០០១ បែកហើយ ។

បូលី  :  វៀតណាមវាបែកហើយ?

យឹម  :  បាទ! វាយបែកហើយ ។

បូលី  :  មកណាវិញហើយ?

យឹម  :  វាយបែកពួកខ្ញុំមកនៅអីខែដន អីដល់អីណានស្ទូ នៅតាមជំរុំជាប់ដីថៃនេះ នៅម៉ុំស្ទី នៅស្ទី! ពួកយាយឯងនៅនោះ? នៅលើដីគេណានោះ ។ លែងជាប់ដីយើងបានហើយ នៅដីថៃអានោះ ។

បូលី ៖ មកដល់ដីថៃហើយនោះ?

យឹម ៖ បាទ! ដីថៃហើយ ។ ១០០១ បែក៨៤ ។

បូលី ៖ ចុង៨៤ ចូល៨៥ ។ ពេលនោះវៀតណាមគេចាប់ផ្តើមបោះសំអាតតាមព្រំដែន?

យឹម ៖ បាទ! ហ្នឹងហើយ ។ ខ្ញុំចាប់ផ្តើមវាយ ។

យឹម ៖ វាយខ្ចាត នៅដីថៃទាំងអស់! ខ្ញុំវាយ ដូចខ្ញុំមករត់នៅរតនគិរី លើកទី២ហើយនោះ ខ្ញុំហ្នឹង ។

បូលី ៖ វាបានកាន់កាំភ្លើងធំលើកទី២ទៀត?

យឹម ៖ បាទ! កាំភ្លើងធំរបស់វៀតណាម ១៣០,១០៥ មួយយប់ទល់ភ្លឺវាយអត់ចេញទេ វាឆ្លង មែនទែន អាវាយ១០០១ហ្នឹងណា ។

ប្រពន្ធយឹម ៖ នៅគ្រប់តែកន្លែងលំបាក១ជួរព្រំដែនហ្នឹង ។

បូលី ៖ ពេលវាបោសសំអាតនេះគឺ ខ្ចាតទៅនៅដីអស់រលីង ។

យឹម ៖ អត់រលីង ចូលទៅនៅដីថៃទាំងអស់បណ្តោយ ។

បូលី ៖ យើងនៅតាមជំរុំ ឬនៅតាមភូមិឃុំរបស់ថៃ?

យឹម ៖ នៅតាមជំរុំ ។

ប្រពន្ធយឹម ៖ នៅតាមអង្គភាពយើងទេ ។ ជំរុំមានអ្នកផ្សេងនៅមួយឡែកទៀត យើងនៅតាមកងពល នីមួយៗ ។

បូលី ៖ តាមកងពលមួយៗ?

យឹម ៖ បាទ!នៅតាដីគេ ទៅតាមព្រៃណា៎ ។

បូលី ៖ មិនមែនចូលទៅនៅជំរុំ?

យឹម ៖ អាជំរុំនោះផ្សេង ។

ប្រពន្ធយឹមៈ អាជំរុំនោះផ្សេង អាអង្គការអីទំនប់អីថៃនោះផ្សេង ។

បូលី ៖ អាជំរុំសាយធូរ?

យឹម ៖ សាយធូរ!

បូលី ៖ សាយភីចឹងទេណ៎?

យឹម ៖ បាទ! អាហ្នឹងផ្សេង ។

បូលី ៖ អាហ្នឹងប្រជាជនស៊ីវិលផ្សេងទេ?

យឹម ៖ បាទ! ផ្សេងទេអានោះ ។

បូលី  :  បាទ!  ដែលយើងខាងខ្មែរក្រហមនេះគឺថា  កាលណាវៀតណាមវាយចូលយើងទៅតាមអន្តភាពរបស់ពួកយើង គ្រាន់ថាវានៅក្នុងដីថៃ ។

យឹម  :  បាទ! នៅក្នុងដីថៃ ។

បូលី  :  តាមព្រៃ តាមអីចឹងទៅ ។ អត់មានតង់របស់ UN អីទេ?

យឹម  :  អត់ទេ ។ អាហ្នឹងដោះស្រាយខ្លួនឯងទៅនោះ ។

បូលី  :  ហើយមានការផ្គត់ផ្គង់ដូចដែលយើងកាលនៅ១០០១ទេ ចែក(ស្តាប់ពុំបាន)ចឹងទេ?

យឹម  :  អ្នកដែល!

ប្រពន្ធយឹម  :  ចែកដូចគ្នា ។

បូលី  :  ចែកដូចគ្នា ។

យឹម  :  នៅតែចែកម្ហូបអាហារនោះ ។

បូលី  :  ហើយបានមកពីណាម្ហូបអាហារនោះ?

យឹម  :  ដូចខ្ញុំនិយាយមិញចឹង បានមកពីចិនហ្នឹងហើយ ។

ប្រពន្ធយឹម  :  រដ្ឋាភិបាលផង ។

បូលី  :  គេមានឃ្លាំងមួយសម្រាប់ចែកនៅក្នុងដីថៃ?

យឹម  :  បាទនៅក្នុងដីថៃនោះឯង ។

បូលី  :  បើសិនជាឃ្លាំងនៅក្នុងដីខ្មែរ វៀតណាមវាយដែរ ។

យឹម  :  ហ្នឹងហើយ! នៅដីខ្មែរមិនបានទេ នៅដីថៃនោះឯង ។

បូលី  :  មានអីចែកទៀត?

យឹម  :  កម្លាំងទៅដល់ណាក៏ដោយ របស់ឧបត្ថម្ភនោះទៅដល់នោះឯង អត់ដាច់បានទេ ។

ប្រពន្ធយឹម  :  ពេលផ្លាស់កន្លែងម្តងៗ  សឹងតែយកមិនរួច  ខ្លះខ្វាយចោលអស់តែម្តងណា១មួយអាទិត្យៗ បើត្រីខកំប៉ុងអាធំៗអាតូចសុទ្ធតែឲ្យស៊ីឆ្ងាញ់ៗប្រពន្ធទ័ព ឈឺគ្រុនកូនចៅអីផ្គត់ផ្គង់អីមិនឲ្យប្តីនៅមុខនោះមានអីល្អក់កករជាមួយប្រពន្ធទេ មានកម្លាំងនៅជួយមើល ។ កូនខ្ញុំ២ជាង២ឆ្នាំហើយ បានប្តីមកឃើញម្តង ។ ចឹងបានថា មិនគួររស់លោកអើយ ប៉ុន្តែខ្លះម្តងស្តាយអន្តរ ស្តាយអីវេទនាណាស់ ។

យឹម  :  កំសត់ដែល ។

បូលី  :  បើស្តាយកូន ស្តាយរបស់ទៅ ។

យឹម  :  បាទ!

ប្រពន្ធយឹម ៖ ពួកវាភ្លើថា គេជិតដល់ទីនេះ គេជម្រាត់ស្រយឹងស្រយោង ទឹកភ្នែកទឹកអីខ្លះចឹងទៅណា ។ ធម្មតាថាយើងអ្នកតស៊ូទៅតែចឹង ។

បូលី ៖ ចុះកាលនៅសម័យ៣ឆ្នាំ ៨ខែហ្នឹងគេបានហូបចុកគ្រប់គ្រាន់ ចឹងទេ? គេចែកឲ្យចឹងទេ ត្រីខ ត្រីកំប៉ុងចឹង?

យឹម ៖ អត់ទេ!

ប្រពន្ធយឹម ៖ ពួកខ្ញុំនៅមិន(ស្តាប់ពុំបាន) ហូបតែឆ្ងាញ់ចឹងឯង ។

បូលី ៖ អត់សូវបានបបរភាវអីទេហី ។

ប្រពន្ធយឹង ៖ នេះតាមពូណា បបរដំឡូង បបរអីខ្ញុំអត់ដែរទេ ។ មានដែរនៅរតនៈគីរីនោះ គេបាយ វាល់បាយគេដាំបាយលឿង គេចែកបាយហូប ហូបមានដែលអស់ផងហ្នឹង ។ ខ្ញុំហូបតែ បន្តិចៗហ្នឹង ។ មនុស្សប្រុស ហូបច្រើនជាងមនុស្សស្រី (ស្តាប់ពុំបាន)១ចានដូចគ្នាណា ។

បូលី ៖ ចុះអ៊ំ ពេលបែក១០០១ យើងទៅកំពង់ធំ ដល់ពេលឡើងមកវិញ នៅមូលដ្ឋាន ម្តុំណាវិញ ? អង្គភាពណា រត់មកម្តុំណាវិញ ។

យឹម ៖ អង្គភាពមីងៗ?

បូលី ៖ អង្គភាពរបស់ពូ? អង្គភាពរបស់ពូនៅដងទង់?

យឹម ៖ នៅដងទង់!

បូលី ៖ ដងទង់វាមកប៉ះ១០០៣ហើយ?

ប្រពន្ធយឹម ៖ ដងទង់ហ្នឹង ហែន ដន, ណន ស្ងួនម្តុំគេហ្នឹងជិតៗគ្នាហ្នឹង ។

បូលី ៖ ដីថៃ?

បូលី ៖ នៅទល់មុខជាមួយអន្លង់វែង ឬក៏យ៉ាងម៉េចដងទង់ហ្នឹង?

ប្រពន្ធយឹមៈ នៅឯក្នុងនោះ?

យឹម ៖ ទេ! ដូចទល់មុខហ្នឹង ។

ប្រពន្ធយឹមៈ ទល់មុខនៅនេះអីនោះអី នៅនេះហួសៗ ហួសទៅនោះ ។

បូលី ៖ យើងដឹងថាអាដងទង់ដីថៃណា គឺទល់អីជាមួយដីខ្មែរ(ស្តាប់ពុំបាន) ទល់ជាមួយព្រះវិហារ ឬត្រពាំងប្រាសាទ ។ ឬក៏ណាផ្សេងទៀត? ទល់ជាមួយអី?

ប្រពន្ធយឹមៈ ទល់អីទេកាលហ្នឹងព្រោះព្រំដែនហ៎!

បូលី ៖ ដាំក្បាន ស្រអែម ឬក៏យ៉ាងម៉េច?

ប្រពន្ធយឹមៈ ត្រឹមចងក ចង់អីទេនេះ(ស្តាប់ពុំបាន) ដងទង់ណាទេ ប-៤០ អីទេអីនេះមិនដឹង ។

យឹម ៖ ដងទង់ដូចទល់ពី!

ប្រពន្ធយឹម៖ អានេះប-៤០ជន្ទួសជាំស្លា ។

យឹម ៖ ទល់មុខព្រះប្រឡាយនេះ ។

ប្រពន្ធយឹម៖ ហ្នឹងហើយ! ទល់មុខព្រះប្រឡាយ ។

បូលី ៖ ទល់មុខព្រះប្រឡាយ?

យឹម ៖ ទល់មុខព្រះប្រឡាយនោះហើយ យុំព្រះប្រឡាយនោះឯង ។

បូលី ៖ ជាំស្លានៅម្ដុំណា?

យឹម ៖ ជាំស្លា!

ប្រពន្ធយឹម៖ ម្ដុំឈូករុននេះ ឈូករុន ។

បូលី ៖ ខ្ញុំសូមសួរអានេះតិចមើល ព្រោះអីខ្ញុំងអត់សូវច្បាស់ ។ បើយើងប្រើពាក្យថាជាំស្លា និង ឈូករុន អាហ្នឹងបានន័យថាម៉េច? ខុសគ្នាយ៉ាងម៉េចអា២ហ្នឹង?

ប្រពន្ធយឹម៖ ឈូករុននៅខាងនេះ ហួសព្រហប្រឡាយតិច ។

យឹម ៖ ជាំស្លាផ្សេង ។

ប្រពន្ធយឹម៖ នៅខាងក្នុងទៀត ។

បូលី ៖ ជាំស្លាជាច្រកព្រំដែន ឬក៏ជាអី ជាតំបន់អន្លុភាព?

ប្រពន្ធយឹម៖ ជាំស្លាដីថៃ បើដីយើងមិនទេ ប៉ុន្តែគម្ទាំងនៅតាមអន្លុភាពមួយៗថាជាំស្លា របៀបដូចថា នៅក-អន្លង់ នៅ ក-៣អីចឹងទៅណា នៅ១០០៣ចឹទៅ ។ តាមដំណាក់ៗ គេចឹងទៅ ។

យឹម ៖ តាមមើលណៅក្នុងដីយើងទេ?

ប្រពន្ធយឹម៖ គាមមើលនៅក្នុងដីយើងដដែរ ។

បូលី ៖ ចុះឈូករុនជាអ្វី ជាច្រកព្រំដែន?

ប្រពន្ធយឹម៖ ឈូករុន ដីយើងដែរ ។

បូលី ៖ ឧទាហរណ៍ថាបើសិនណាយើងនិយាយ យើងនិយាយពាក្យថាជាំមួយម៉ាត់ ឬក៏ជាស្រុងាំយើង ដឹងភ្លាមថាអាហ្នឹងច្រកព្រំដែន ចុះបើយើងនិយាយពាក្យថាជាំស្លា ឬក៏ ឈូករុននោះក៏នៅ ព្រំដែនដែរ អាហ្នឹងស្អីអាហ្នឹងជាភូមិ ជាច្រក ឬក៏ជាអី?

យឹម ៖ កន្លែងហ្នឹងជាជាំតែម្ដង ។ កាលហ្នឹងគាគាត់រៀប ចង់ធ្វើផ្លូវមួយសម្រាប់ថៃវារកស៊ីជាមួយ យើងនោះ ដឹកឈើតាមផ្លូវឈូករុននោះឯង ។

បូលី ៖ ចឹងបានន័យថាឈូករុនជាច្រកឆ្លងកាត់?

យឹម  :  បាទ!

បូលី  :  រវាងខ្មែរ និងថៃមួយដែរ?

យឹម  :  ហ្នឹងហើយ ។ ថៃ វាដឹកឈើ ដូចច្រកជាំស្រង់ចិនដែរណ៎ា ។ គាទៅរៀបចំឲ្យឈូសឆាយធ្វើផ្លូវហ្នឹងមួយ ឡើងទៅថៃដើម្បីឲ្យថៃ ធ្វើចេញពីដើងទៅកាលហ្នឹង ។

បូលី  :  នៅក្នុងឃុំអី?

យឹម  :  កាលហ្នឹងនៅក្នុងឃុំព្រះប្រឡាយ ។

បូលី  :  ភូមិអី?

យឹម  :  បើនិយាយពីកងពលកាលហ្នឹង នៅក្នុងកងពល៦១២ ទេ ។ កងពលតាហឿន!

បូលី  :  ហ្ន៎! ចឹងច្រកតាហឿន?

យឹម  :  បាទ! កងពល៦១៦ណ៎ា កងពល!

បូលី  :  កងពល៦១២ហេ៎?

យឹម  :  បាទ! ៦១២ របស់តាហឿន ។

បូលី  :  ចឹងបានន័យថាកងពល៦១២ ទៅច្រកតាហឿនហ្នឹងនៅច្រកឈូករុនហ្នឹងឯង?

យឹម  :  កាលហ្នឹង អត់ជាភូមិឃុំនៅឡើយទេ នៅក្នុងអង្គភាពកងពល ។

បូលី  :  ចុះសព្វថ្ងៃនេះ ភូមិអីគេ?

យឹម  :  សព្វថ្ងៃនៅភូមិព្រះប្រឡាយ ។

បូលី  :  ឃុំអីគេ?

យឹម  :  មិនដឹងឃុំអីគេទេនេះ សួរបង សិន បានដឹង ។

ប្រពន្ធយឹមៈ ច្រកហ្នឹង សួរបងសន ខាងលិចពួកខ្ញុំ ។

បូលី  :  ចឹងបើយើងចង់ទៅឈូករុន យើងទៅដល់?

យឹម  :  ដល់តា ។

បូលី  :  ជិះឡានដល់ទេ?

យឹម  :  កាលមុនឡានដល់ តែឥលូវមិនដឹងយ៉ាងម៉េច ខ្ញុំខានទៅយូរហើយ ព្រោះអត់ខ្ពស់ប៉ុន្មានដែរទេកាលនោះឡាន ។

បូលី  :  ផ្លូវគ្រួសក្រហម ឬក៏ផ្លូវដី?

យឹម  :  ផ្លូវគ្រួស ។

បូលី  :  ផ្លូវគ្រួស! ឡានបើកបានទេ?

យឹម ៖ ឡានកាលនោះថៃវាចុចៗ

ប្រពន្ធយឹម ៖ ថៃឥលូវវាកើនមកកន្លែងយើងៗ

យឹម ៖ ថៃកាលហ្នឹងវាដូចច្រកដាំៗ

ប្រពន្ធយឹម ៖ ឥលូវថៃ វារំកិលមកដល់ផ្ទះជិតដល់ផ្ទះតាជាតនោះហើយៗ

បូលី ៖ ផ្លូវចូលបីផ្លូវជាតិ ចូលទៅតាមណា?

យឹម ៖ ទៅពីនោះទៅតាមនោះដាច់ បត់ទៅឆ្វេងៗ

បូលី ៖ ចូលតាមខ្លោងទ្វារវត្តនឹងមែន?

យឹម ៖ បាទ! ទៅត្រង់ៗ

បូលី ៖ ទៅត្រង់យើងកាត់ទំនប់ដាច់ត្រូវទេៗ កាត់ទំនប់ដាច់យើងទៅត្រង់ទៀត?

យឹម ៖ ទៅត្រង់រហូតទៅមានផ្លូវបំបែកឆ្វេង-ស្តាំ ហើយសួរគេទៅមាន(ស្តាប់ពុំបាន) ២,៣នោះៗ

បូលី ៖ ទៅដល់ហ្នឹង បត់ស្តាំ ឬក៏បត់ឆ្វេង?

យឹម ៖ ទៅពីហ្នឹងទៅដើងចឹង ហ្នឹងផ្លូវទៅប្រាសាទ(ស្តាប់ពុំបាន) ៗ

បូកលី ៖ ប្រាសាទព្រះវិហារ?

យឹម ៖ បាទ!

ប្រពន្ធយឹម ៖ ប៉ុន្តែថៃ វារំកិលទឹតាំងហើយអានោះៗ

បូលី ៖ យើងនាំមក មកតាមអន្លង់វែងវិញហេ៎?

យឹម ៖ បាទ! ផ្លូវនោះធ្លុះទៅដល់អន្លង់វែងទៀតៗ ផ្លូវក្រហមនោះ ផ្លូវនោះទើបតែធ្វើដែរទេៗ
ផ្លូវឥលូវច្រើនខ្សែណាស់ផ្លូវ ពីមុនមានតែផ្លូវបារាំងៗ

បូលី ៖ ប៉ុនយើងបើបាន យើងទាហានអត់មានឃាត់យើងអីទេ?

យឹម ៖ អត់ឃាត់ទេ! ឃាត់តែឡានដឹកក្រញូង កុំដឹកក្រញូង អាហ្នឹងបានគេឃាត់ៗ

បូលី ៖ ឥលូវអត់មានដឹកក្រញូងអីទេ(សើច)!

យឹម ៖ គ្រួសារកងទ័ព!

បូលី ៖ ចាំមើលពេលខ្ញុំទៅវិញ ខ្ញុំប្រហែលជាចង់ទៅមើលឈូករុន និងបន្ទិច ហើយចង់មើលឈូករុន
នឹងបន្តិច ហើយទៅចេញពី ឈូករុនហ្នឹងមក បើកតាមអន្លង់វែងហ្នឹងវិញៗ

ប្រជាជន ៖ ឆ្លងកាត់ទៅចូលទៅដីថៃ! ប៉ុនផ្លូវទួល ដីថៃ ៗ

បូលី ៖ ប៉ុននៅខាងដីខ្មែរយើង មានកងទ័ពការពារទេ?

យឹម ៖ មានណាខាងយើងនោះៗ

ប្រជាជន ៖ (ស្តាប់ពុំបាន) ។

បូលី ៖ ផ្លូវហ្នឹង មានក្រលាក់ទេមើលទៅ?

ប្រជាជន ៖ (ស្តាប់ពុំបាន) ។

យឹម ៖ ខ្ញុំខានទៅយូរហើយ អត់ដឹងទេអាហ្នឹងនោះ ។ ខានដើទៅហ្នឹងយូរហើយ ។

បូលី ៖ ខ្ញុំកាលទៅមុនដំបូង ខ្ញុំទៅបានត្រឹមនេះ ទៅបានត្រឹមស្ពឹងខ្សាច់ តែខ្ញុំអត់បានទៅមុខតទៀតណា ។ (ស្តាប់ពុំបាន)

ប្រពន្ធយឹម ៖ រូបរាងនេះ ដូចជារូបរាងគាត់ម៉េះ?

បូលី ៖ បាទ! រូបខ្ញុំ!

ប្រពន្ធយឹម ៖ រូបហ្នឹង រូបអាកាលសម័យខ្មែរក្រហមអាកាលដែលគេថតដាក់ ។

យឹម ៖ ស៊ីគាត់មើលបន្តិចបានទេណ៎?

បូលី ៖ អាហ្នឹងជូនអ៊ីតា ។ រូបណាថតដាក់អ៊ី?

ប្រពន្ធយឹម ៖ រូបអស់ហ្នឹង ។

បូលី ៖ រូបហ្នឹង សុទ្ធតែរូបពិតអត់មានក្លែងភេទផង ។ រូបហ្នឹងយើងសេសសល់ សល់ពីសម័យហ្នឹងអានេះបានរូបថ្មី ។ ច្បាស់ជាងគេធ្វេញហ្នឹងតែម្តង!

ប្រពន្ធយឹម ៖ ដូចក្នុងនេះចាស់ណាស់ ។

យឹម ៖ បាទ! មកពីបច្ចេសថតទេ ។

ប្រពន្ធយឹម ៖ ប៉ុន ខ្ញុំថាហ្នឹង! តែតានេះ គាត់អត់ជឿ ហើយក៏ខ្ញុំសួរទៅ ។

បូលី ៖ ចុះអ៊ីអើ! ក្រោយមកពីឆ្នាំណាបានយើងចុះមកក្រោម មកអន្លង់វែងត្រពាំងប្រាសាទ?

យឹម ៖ មកត្រពាំងប្រាសាទជំនាន់អ៊ុនគាក់ចូលកិច្ចព្រមព្រៀង ៩៣ ។

បូលី ៖ ៩៣?

យឹម ៖ បាទ!

បូលី ៖ ៩៣ ឬ៩៨?

យឹម ៖ ៩៨! ហ៎! មកមុន ។

ប្រពន្ធយឹម ៖ ហ៎! មកនៅអន្លង់វែងបានយូរហើយ អូរជីកក្រោយយូរហើយ បានអ៊ុនគាក់ ។

យឹម ៖ មកមុន មកតាំងពី៩១នោះ ។

បូលី ៖ តាំងពី៩១?

យឹម ៖ ៩១! ហ្នឹងហើយ ។

ប្រពន្ធយឹម ៖ ចុះពីដងទង់ ចុះពីនេះមក ។

យឹម ៖ ៩១,៩៣ បានកិច្ចព្រមព្រៀង! ចាប់ផ្តើមដងការភ្លើងដកអី ទុកម្តុំហើយអានោះ ។

បូលី ៖ ខាងដងទង់មកហើយអានោះ?

យឹម ៖ បាទ! និយាយរួមគ្រប់ប្រកខាងកងពលតាហឿនហ្នឹងគាត់ចុះមកព្រះប្រឡាយហ្នឹងហើយ ហើយខ្ញុំ៨០១,៨០២ហ្នឹងនៅជុំគ្នាជាមួយ ។ បាទ! ៨០១នៅទំនប់ដាច់នេះ ខ្ញុំ៨០២នៅអន្លង់វែងនេះ ជាមួយហ្នឹងកងពលខាង៨៨៥អីនោះណា ។

បូលី ៖ ប៉ុនមុនពេលដែលចុះមកអន្លង់វែងត្រពាំងប្រាសាទនោះ យើងនៅប៉ុន្មានកន្លែង? នៅខាងដីថៃនោះ?

យឹម ៖ នៅច្រើនកន្លែង ។

ប្រពន្ធយឹម ៖ ប្រទល់ព្រំដែនរហូត ។

យឹម ៖ នៅតាមកងពលមួយ នៅដាច់ៗពីគ្នា ។

បូលី ៖ កងពលយើង មុនពេលចុះមកតាមព្រំដែនដាច់ពីគ្នាទេណ៎?

យឹម ៖ បាទ!

បូលី ៖ កន្លែងដងទង់ កងពលអីគេ?

យឹម ៖ កងរបស់តាហឿន ។

បូលី ៖ កងរបស់តាហឿនសែស?

យឹម ៖ បាទ!

បូលី ៖ ក្រៅពីកងតាហឿន មានកងពលផ្សេងទេ?

ប្រពន្ធយឹម ៖ កងពលលេខប៉ុន្មានៗទេ ។

បូលី ៖ លេខ៨០២ ។

យឹម ៖ ៨០២ ពួកខ្ញុំនេះ!

បូលី ៖ តាហឿន?

យឹម ៖ អត់ទេ! តាឆន ។

បូលី ៖ តាឆន បើ៦១២ តាហឿន?

យឹម ៖ តាហឿន ។

បូលី ៖ ចឹងតាឆនជាមួយតាហឿន កងពលគាត់នៅកន្លែងដងទង់ហ្នឹង?

យឹម ៖ ពួកខ្ញុំអត់ទេ ។

បូលី ៖ ពូនៅឯណាវិញ?

យឹម ៖ ខ្ញុំកាលហ្នឹង មិននៅណាពួកយើង។

ប្រពន្ធយឹម ៖ ចំរុះគ្នា កាលពីនៅដងទន់ ជុំគ្នាគ្នាទាំងអស់តាំងពីដងទន់ ទាំងមូលទៅណាមកណា ជួបជុំគ្នាល្អណានៅជុំគ្នាទាំងអស់ហើយ កូនតាហឿន៩២០ ហើយណាៗអីជុំគ្នាទាំងអស់នោះ អាហ្នឹងនៅជុំៗអស់ហើយ។

យឹម ៖ នៅជុំគ្នាហើយបានសប្បាយ! បានតាម៉ុក គាត់រៀបចំបែក។

បូលី ៖ ហើយបានតាម៉ុក គាត់នៅឯណាតាម៉ុក?

យឹម ៖ តាម៉ុក គាត់នៅ! គាត់នៅអី ដូចយើងនេះជិតជាប់ នៅលើឯនោះ ជួនការនៅក្រោយ ជួនការនៅលើ នៅក្បាលទន្លេរាង។

បូលី ៖ មុនពេល៩០ដែលយើងចុះមកហ្នឹង ខ្ញុំចង់ដឹងមុនហ្នឹងសិន! បើមុនពេលដែលវាយបានអន្លង់វែងនៅម្តុំណាតាម៉ុក?

យឹម ៖ តាម៉ុក មុនវាយបានអន្លង់វែង គាត់នៅឯភ្នំនោះ។

បូលី ៖ គេហៅនៅម្តុំហ្នឹង ?ដូចពូនៅដងទង់ចឹងណា ដូចមីងដូចអីថា ចឹងណា។

ប្រពន្ធយឹម ៖ គាត់នៅមិនឆ្ងាយដូចពួកប្រជាជន។

យឹម ៖ ដូចយើងនៅម្តុំជាំស្វាអាកន្លែងនោះឯង! នៅជាំនោះឯង។

បូលី ៖ ជប់ម្ទូ?

យឹម ៖ បាទ!ជប់ម្ទូនោះ។ មុនហ្នឹងបែកអន្លង់វែងនៅនោះឯង។

បូលី ៖ ជប់ម្ទូនោះដីខ្មែរ ឬក៏នៅដីថៃ?

ប្រពន្ធយឹម ៖ ក្បាលទន្លេរាងជប់ម្ទូនោះហាក់ដូចជា។

បូលី ៖ ជប់ម្ទូនៅម្តុំណាអី?

ប្រពន្ធយឹម ៖ នៅដីខ្មែរ! ជាំហ្នឹង នៅជាំផ្សារថៃ ក្បាលទន្លេរាងហួសពីអន្លង់វែងទៅចឹង។

បូលី ៖ អាហ្នឹង នៅជប់ម្ទូហើយនៅក្បាលទន្លេរាងហ្នឹង?

ប្រពន្ធយឹម ៖ ហ្នឹងហើយ។

បូលី ៖ ចុះអូរគ្រាវនៅឯណាវិញ?

ប្រពន្ធយឹម ៖ អីក្នុងនោះទៀត។

យឹម ៖ អូរគ្រាវនៅដីថៃនោះ។

បូលី ៖ អាហ្នឹងអគ្គភាពខ្មែរក្រហមយើងនេះដែរ?

ប្រពន្ធយឹម ៖ នៅហ្នឹងតា!

បូលី ៖ ឬក៏តាប្រជាជនស៊ីវិលទេ?

ប្រពន្ធយឹម ៖ មេៗ ។

យឹម ៖ ប៉ុនមិនមែនប្រជាជនស៊ីវិលទេ

ប្រពន្ធយឹម ៖ សុទ្ធតែប្រពន្ធទ័ព ។

បូលី ៖ មិនមែនជនភៀសខ្លួនទេណ៎?

ប្រពន្ធយឹម ៖ មិនទេ!

បូលី ៖ ព្រោះជំរុំជនភៀសខ្លួនវាផ្សេងណាអ៊ំ ។ ឧទាហរណ៍ថាសាយប៊ី សាយធូរ ឬក៏សាយអេកអ៊ី អាហ្នឹង អាហ្នឹងជំរុំជនភៀសខ្លួនផ្សេង ។

ប្រពន្ធយឹម ៖ អាហ្នឹងប្រពន្ធខ្មែរក្រហមមួយចំនួនដែរ ប៉ុនគេទៅនៅជំរុំណា! គេទៅនៅជំរុំទៅនៅមួយជួរព្រំដែនទាំងអស់ហ្នឹង នៅក្នុងកងពលមួយៗ

បូលី ៖ បើនៅខាងកងទ័ពកម្លាំងប្រពន្ធ គ្រួសារខ្មែរក្រហមយើងណោក្នុងតាមព្រំដែន! គ្រាន់ថាវាដីថៃនែក?

ប្រពន្ធយឹម ៖ ខ្លះវានៅជំរុំចឹងដែរ! ខ្លះស្ម័គ្រចិត្ត ។

បូលី ៖ ចុះអូរត្រាវនរណាគេកាន់កាប់?

ប្រពន្ធយឹម ៖ អូរត្រាវពីណាគេទេ!

បូលី ៖ របស់តាម៉ុក កាន់កាប់ដែរ ឬក៏យ៉ាងម៉េច ឬក៏ខាងកាកបាទក្រហមគេកាន់កាប់?

ប្រពន្ធយឹម ៖ គ្មានទេ! គេកាកបាទក្រហមគេ ឧបត្ថម្ភដែរប៉ុន្តែ!

យឹម ៖ ខាងកាកបាទទេ អូរត្រាវនោះ ។

ប្រពន្ធយឹម ៖ កាកបាទក្រហម ប៉ុនដូចមិន(ស្តាប់ពុំបាន) ធ្វើកងពលអីដែរ នៅហ្នឹង ។ ដឹងពីណាគេអង្គភាពគេផ្សេង ។

បូលី ៖ ខ្ញុំកិច្ចការខាងហ្នឹង ខ្ញុំមិនសូវយល់ទេ នៅហ្នឹងទេ ។

(ប្រពន្ធយឹម ហើយនិងយឹមនិយាយគ្នា)

យឹម ៖ ព្រោះគេនេះ គេនៅជាប់ ខាងក្រោយគេដឹងរឿងច្រើន ។

ប្រពន្ធយឹម ៖ ពួកពីលិចមក គេនៅជំរុំហើយកាកបាទ គេឧបត្ថម្ភទាំងស្រុងតែម្តង បើពួកខ្ញុំអត់ទេ ។

បូលី ៖ ចុះស៊ីងចាន់?

ប្រពន្ធយឹម ៖ ហ្នឹងហើយស៊ីងចាន់ ដងទង់ហ្នឹងជាមួយគាត្នា ស៊ីងចាន់ខៃដន ណនសុងជាមួយគ្នាទាំងអស់ ។

ថន ៖ ខ្ញុំសុំឈ្មោះអ៊ីតិច?

បូលី ៖ អាហ្នឹងនៅជាប់គ្នាតែម្ដងហេ៎?

ប្រពន្ធយឹម ៖ ចា៎ស! ជាប់គ្នា ។

បូលី ៖ អាលូវយើងហៅទី១ស៊ីងចាន់ បន្ទាប់មក ដងទង់?

ប្រពន្ធយឹម ៖ ហ្នឹងហើយ ដងទង់ ស៊ីងចាន់នៅជាប់តែគ្នា ។ ស៊ីងចាន់ចេះ ហើយវានៅខាងនេះ ហើយដងទង់នៅឯនោះ កន្លែងវានៅមន្ទីរអឺងាន់ហ្នឹង ហើយមកដល់មួយសន្ទុះមករកនៅមាត់អូរទៀតទៅ ។

បូលី ៖ ដងទង់ហើយទៅ ខៃដនហេ៎?

ប្រពន្ធយឹម ៖ ខៃដន ណនសុង មកពីនោះមកវិញ?

បូលី ៖ ខៃដន ណនសុង ។ អាហ្នឹងសុទ្ធតែតំបន់ដែលក្រុមគ្រួសាររបស់ខ្មែរក្រហមរស់នៅហើយណ៎? ពេលដែលវៀតណាមវាយបុកឆ្ងាយទៅអស់ហើយ ។ បាទ! ស៊ីងចាន់ ដងទង់ ខៃដន ណនសុង ។

ប្រពន្ធយឹម ៖ (ស្ដាប់ពុំបាន) ឃើញអើយ ស្រាវជ្រាវអីឃើញខ្មែរក្រហមយកទៅវាយចោលទាំងអស់ ។

បូលី ៖ ងាប់ហើយអឺ សម័យនោះយកទៅយចោល យកទៅអីទៀតអឺអើយ ។ បើចេះវាយចោលមកដល់ត្រពាំងប្រាសាទ៨-១០, ២០ឆ្នាំធ្វើអី ។ វាយទាំងពី៩៩ទៅហើយ ។

យឹម ៖ ខ្ញុំគ្មានបារម្ភទេ អាចឹងៗនោះ ។

បូលី ៖ បាទ!

ប្រពន្ធយឹម ៖ ចំនាស់នេះហើយ ខ្វិលគិតច្រើន ។

បូលី ៖ អត់ទេ! ឥលូវផ្សះផ្សារសន្តិភាពគេអឺ មានសង្គ្រាមតទៀត ។

យឹម ៖ យើងមានគំនិតចឹង បានន័យថាខ្មែរយើង មានគំនិតសុខ សាន្ត នៅវាលែងសន្តិភាពហើយ ។

បូលី ៖ អស់ហើយ! វាលែងមានសន្តិភាពហើយ បើនៅតែសង្គ្រាមតទៀត ។

យឹម ៖ ចេះតែខ្វាចគ្នាទៅវិញទៅមក វាកើតគូបដិបក្សរួចហើយ ។

បូលី ៖ ពីណាសុខចិត្ត ឲ្យគេអង្គុយវាយលេងៗ គាកេវាយមិនរើ ។

យឹម ៖ វាចឹងហើយ ។

បូលី ៖ ហើយមានទៀតអីទេអ៊ំ ក្រៅពីស៊ឹងចាន់ ជប់ម្ហូ អូរត្រាវ ដងទង់ ខៃដន ណានសុង អ៊ំមានស្គាល់តំបន់អីទៀតដែលក្រុមគ្រួសារខាងខ្មែរក្រហមនៅតាមបណ្តោយព្រំដែន ព្រោះថាមុនពេលដែលយើងចុះមក អន្លង់វែង ត្រពាំងប្រាសាទ យើងមកតាមជំនាន់នេះអ៊ំ មិនចាំងអីអ៊ំ? ប៉ុនឈ្មោះអីខ្លះហ្នឹងខាងមួយជំនាអ៊ំ?

ប្រពន្ធយឹម ៖ ពេលចុះពីហ្នឹងមក មានតែមក អូរជីកយើង តែអូរជីកក្រោម ។

បូលី ៖ ក្រោយមកនេះទេ?

យឹម ៖ នៅឯក្រោយ ។

ប្រពន្ធយឹម ៖ ពីមុនមកយើងមកតាំងពី (ស្តាប់ពុំបាន) បារាំងធ្លាក់ ៨០៨មក!

យឹម ៖ អាហ្នឹងមកតាំងយូរហើយ ។

បូលី ៖ តាំងពី៨០,៨១មក ។ មកបារាំងធ្លាក់មកខាងនេះវិញ មកជំនារបាត់ដំបងវិញ? បាទ! អានេះយើងចេញពីមួយជំនាបន្ទាយមានជ័យ និងឧត្តរមានជ័យ ព្រោះមួយជំនានេះបាន វាទាក់ទងអន្លង់វែងណាអ៊ំ! បើមួយជំនានេះវាអត់ទាក់ទងអន្លង់វែងទេអ៊ំ ខ្ញុំស្រាវជ្រាវដែរ តែវាទុកម៉ុសិនយើងគិតម៉ុនេះសិន ។

ប្រពន្ធយឹម ៖ តាមកងពលមួយៗ ។

បូលី ៖ តាមកងពល នែកអ៊ំនែក?

យឹម ៖ ប៉ុន្តែនិយាយរួមកម្លាំងនៅក្រោយគេ គឺកម្លាំងជុំគ្នាទេ កងពល ប៉ុន្តែវានៅតាមអង្គភាពណាដូចថានៅជាំស្វានៅស៊ឹងចាន់អីហ្នឹង វាគ្រាន់តែអង្គភាពម៉្ញំៗ និយាយរួមនៅចម្រុះគ្នាតែម្តង ។

ប្រពន្ធយឹម ៖ ៨០១នៅនោះ ៨០២នៅនេះចឹងទៅ កងពលប៉ុន្មាន ៨១២នៅនេះគត្នាដែរចឹងទៅណា ។

បូលី ៖ ហើយកងទ័ពចូលមកក្នុងខ្លះទៅ?

យឹម ៖ និយាយរួមកម្លាំងប្តីៗដែលទៅកងពលទាំងប៉ុន្មានសុទ្ធតែទៅមុខទាំងអស់ នៅក្រោយនៅតែអ្នកពិការ អ្នកដែលនៅចាស់ ចាស់ជរាហ្នឹង អ្នកដែលខ្សោយសុខភាពទៅមិនបាន គឺទៅជាមួយគ្រួសារកងទ័ព ។

បូលី ៖ ក្រៅពីហ្នឹងគេឲ្យមកធ្វើការចូលមកក្នុងនេះ?

យឹម ៖ ដែលកម្លាំងមាំចូលធ្វើការនៅសមរភូមិទាំងអស់ ។

ប្រពន្ធយឹម ៖ មិននេះទេក្មេងៗ ព្រោះអីម្នាក់ ២នាក់នៅតាមគ្រួសារគេហ្នឹង គេថាមេៗអត់ឲ្យអត់នៅទេ គេហៅកងអង្គរក្សប៉ុនឥលូវគេហៅអង្គរក្ស នៅជាមួយក្រុមកូនចៅ ។

យឹម ៖ ទុកគ្រាន់ការពាររបស់មេៗទេ។ មេៗមិនបានទាំងអស់ទេអានោះ។

ប្រពន្ធយឹម ៖ ដូចថាយើងផ្លាស់កន្លែងហើយនោះ ធ្វើជម្រកជ្រកកោនហ្នឹងណាស់។

បូលី ៖ វាត្រូវការកម្លាំងកាប់ឈើ កាប់អីដែរ កាប់ឫស្សីកាប់អី។

យឹម ៖ នៅតូចៗហ្នឹង។

ប្រពន្ធយឹម ៖ គេមិនឲ្យអត់ទេនៅហ្នឹង។ បើអត់សោះអ្នកណាអ្នកធ្វើ។

បូលី ៖ ដល់ពេលដែលយើង តាម៉ុក គាតលំវាយបានអន្លង់វែងត្រពាំងប្រាសាទ កាលហ្នឹងយើងអត់ទាន់មានត្រពាំងប្រាសាទទេណា ត្រពាំងប្រាសាទគឺយើងរាប់ចូលទៅអន្លង់វែងហើយ ពេលវាយបានអន្លង់វែងហើយហ្នឹង យើងនាំគ្នាចុះមកមិនអីចឹងហ៎ពីភ្នំមក ចុះមកហ្នឹង ចុះមកតាមច្រកណា? ឈូករុន ឬជាំស្រង៉ាំ? មានប៉ុន្មានច្រកចុះមក?

យឹម ៖ ចុះមកនេះ។

ប្រពន្ធយឹម ៖ ចុះមកអន្លង់វែង ឈូកគគី។

យឹម ៖ ចុះដូជាំហ្នឹងឯង។

ប្រពន្ធយឹម ៖ ជាំក្បាលទន្សោងហ្នឹងឯង។ អាជាំផ្លូវដែលថៃ យើងធ្វើផ្សារហ្នឹង ចុះតាមហ្នឹងមក។

បូលី ៖ កន្លែងកកាស៊ីណូរបស់តាមលីមហេងហ្នឹងហ៎?

ប្រពន្ធយឹម ៖ ហ្នឹងហើយរបស់តាមលីមហេង?

បូលី ៖ ចុះហ្នឹងទាំងអស់គ្នា?

យឹម ៖ ជាំខាងនេះ គេចុះខាងនេះ! ច្រករបស់៨០១ ច្រករបស់៦១២នេះ គេច្រកគេចុះខាងនេះខាងអូរឈូករុន។

ប្រពន្ធយឹម ៖ ឈូករុន ជាំស្វានេះ។

យឹម ៖ គេចុះមកខាងនេះ។

បូលី ៖ អឺៗ! ជួយបែងចែងអាខាងនេះតិចមើល អាឈូករុនហ្នឹងជាំស្វា វាខុសគ្នារបៀបណា?

ប្រពន្ធយឹម ៖ តាមួយហ្នឹង គ្រាន់តែមួយហ្នឹងអាច ឈូករុននៅមុខ អាជាំស្វានៅក្នុងទេណា អាច្រកហ្នឹងតែមួយមក។

យឹម ៖ នៅជាប់គ្នាហ្នឹងទេ គ្រាន់តែឈ្មោះវាផ្សេងគ្នា។

បូលី ៖ ប៉ុនជាំស្វាកន្លែងយើងរស់នៅ?

យឹម ៖ បាទ!

បូលី ៖ ឈូករុនតាមព្រំដែន?

ប្រពន្ធយឹម ៖ តាមកន្លែងពលអាហ្នឹង ។

យឹម ៖ ហ្នឹងក៏ឈ្មោះដែរ ឈ្មោះកន្លែងដែរនៅ ដែរហ្នឹង មិនមែនជាច្រកទេ ។

បូលី ៖ កន្លែងដែលនៅដែរ?

យឹម ៖ បាទ! ជាឈ្មោះ!

បូលី ៖ ជាំស្វាហ្នឹង?

យឹម ៖ បាទ! ឈ្មោះជាំស្វា ឈ្មោះឈូករុននោះក៏វាមាន មិនមែនជាច្រកទេ ។

បូលី ៖ ប៉ុនឈូករុន វាជាច្រកមួយដែលអាចចេញចូលពីថៃមកបាន?

យឹម ៖ អាហ្នឹងបានដូចខ្ញុំនិយាយអំបាញ់មិនចឹង ។ កាលនោះគាត់ឈូសឆាយ ដើម្បីឲ្យថៃដឹកឈើ ។

បូលី ៖ ហើយកើតជំនាន់ អាពេលគាត់ឈូសហ្នឹងឯងគាត់ដាច់ជើងហ្នឹងមែន?

យឹម ៖ ទេ! ដាច់តាំងមុននោះទៀត?

បូលី ៖ ដាច់មុនហ្នឹងទៀតហេ៎?

យឹម ៖ បាទ!

ប្រពន្ធយឹម ៖ ឈូករុន ឈូកគគីហ្នឹង ហៅឈូកគគីៗអីចឹង ហៅឈូកគគីអីចឹងទៅ ។

បូលី ៖ គគីវាផ្សេងទៀត អាហ្នឹងនៅខាងនេះ នៅខាងថ្មពួកនេះ ។

យឹម ៖ រស់នៅនេះទេ អាហ្នឹងគាត់មិនឲ្យនិយាយទេនោះ ។

ប្រពន្ធយឹម ៖ និយាយរឿងចូលទៅបន្ទាយឆ្មារ ។

បូលី ៖ បន្ទាយឆ្មារនេះទេណ៎?

ប្រពន្ធយឹម ៖ ចា៎ស!

បូលី ៖ អានេះយើងនាំគ្នាចុះមកអន្លង់វែង ចុះតាមជាំស្រងាំនេះ?

យឹម ៖ អាពួកខ្ញុំ៨០១នេះ,៨០២ នែកតាម៉ុក ខាងនេះ ។

បូលី ៖ ចុះមកម្តុំណា?

យឹម ៖ ចុះមកពួកខ្ញុំនៅអន្លង់វែងហ្នឹងតែម្តង ។

បូលី ៖ នៅម្តុំកន្លែងផ្សារអី?

យឹម ៖ គេហៅថាផ្សារអូរជីក ផ្សារអូរជីកលើ ។

បូលី ៖ អូរជីកលើហេ៎?

យឹម ៖ បាទ! នៅតាមអូរជីកលើ មិននៅឯក្រោមទេ នៅលើនេះ ។

បូលី ៖ មិនមែនជើងភ្នំទេ?

ប្រពន្ធយឹម ៖ នៅឯក្រោមទឹកហូរពីនេះទៅ?

បូលី ៖ ពីអន្លង់វែងទៅយើង ។

យឹម ៖ នៅជិតអន្លង់វែងដែរ! ប៉ុន្តែ មិនមែននៅឯអីក្រោមមកទេ នៅឯ ។

បូលី ៖ ក្បែរផ្ទះតាទេ?

យឹម ៖ នៅលើផ្ទះតាទៀត ។

បូលី ៖ ហើយមកនៅបានប៉ុន្មានឆ្នាំពូ បានមកដល់កន្លែងនេះ?

យឹម ៖ នៅនេះបាន២ឆ្នាំអី! នៅនោះបានប្រហែល១ឆ្នាំ២ គេរៀបចំបំបែកឲ្យមករកដី គេរៀបចំធ្វើភូមិណា មកឲ្យមកមើលត្រពាំងប្រាសាទនេះឯង ។ ៤១៧ ឲ្យមើលខាងលិច មើលទៅខាងនោះ ។

បូលី ៖ ខាងថ្ងៃតនោះ?

យឹម ៖ បាទ! បានបែកឲ្យរស់នៅ ។

បូលី ៖ ៨០២របស់ពូមកនេះ នៅខាងដល់ត្រពាំងប្រាសាទនេះឯង ។ ពូមកខាងត្រពាំងប្រាសាទឆ្នាំណា?

យឹម ៖ បាទ! មកនៅត្រពាំងប្រាសាទនេះឯង ។

បូលី ៖ ពូមកនៅនេះតាំងពីឆ្នាំណា?

យឹម ៖ ភ្លេចឆ្នាំនេះទៀត! យើងមកដូចកោ ។

បូលី ៖ យើងចុះពីភ្នំ៩០ណា?

យឹម ៖ ៩០, ៩៣អ៊ុនគាក់ចូល!

បូលី ៖ ៩៣អ៊ុនគាក់ចូល ។

ប្រពន្ធយឹម ៖ ព្រោះ៩៨ យើងបោះឆ្នោត ។

យឹម ៖ អាហ្នឹងនៅវាយគ្នាទៀតណា៩៣,៩៤,៩៥ មើលអាកូន កៅប៉ុន្មាន?

បូលី ៖ ចុះអីនៅសល់រូបថតពីដើមៗទេអី?

ប្រពន្ធយឹម ៖ នេះអស់ហើយ កូនខ្ញុំទុក(ស្តាប់ពុំបាន)កណ្តៀរកោអស់ហើយ ។

យឹម ៖ ចោលអស់ហើយចឹង?

បូលី ៖ ចោលអស់ហើយ ។

ប្រពន្ធយឹម ៖ ចោលអស់ហើយ!

បូលី ៖ អត់មានសល់អនុស្សាវរីយខ្លះសោះ?

ប្រពន្ធយឹម ៖ អត់!  មានតែថតឥលូវៗ ។

បូលី ៖ មានឯកសារពីដើមៗ ។ ចុះកំសៀវសល់តាំងពីដើមមក?

ប្រពន្ធយឹម ៖ កំសៀវ ទើបនេះមកឥលូវ ។

បូលី ៖ មិនមែនតាម៉ុកចែកឲ្យទេ?

ប្រពន្ធយឹម ៖ មិនមែនទេ ។

បូលី ៖ មានសល់អានុស្សាវរីយរបស់តាម៉ុកទេអី?

ប្រពន្ធយឹម ៖ អត់ទេ! មានតែ(ស្តាប់ពុំបាន)ចិន ។

បូលី ៖ អាវឡូស្តាយពីក្រោយ?

ប្រពន្ធយឹម ៖ អាហ្នឹងមាន!

បូលី ៖ ខ្ញុំសុំមើលតិចបានទេ?

ប្រពន្ធយឹម ៖ (សើច) ។

បូលី ៖ ឃើញអារបស់ពីដើម រាងវាយ៉ាងម៉េច!

យឹម ៖ មក៩៣នេះ ។

បូលី ៖ ពូអាសៀវភៅនេះអីគេពូ?

យឹម ៖ (ស្តាប់ពុំបាន) ។

បូលី ៖ ពុំមែនជារបៀបអាគេហៅអីកំណត់ហេតុ អត់តាំងពីដើមហ្នឹងមក?

យឹម ៖ (ស្តាប់ពុំបាន) សៀវភៅថ្នាំបូរាណ ។

បូលី ៖ ចឹង៩៣ ពូមកនៅនេះតែម្តង?

យឹម ៖ មកកើតនៅត្រពាំងប្រាសាទនេះឯង ។

បូលី ៖ មកនៅម្តុំនេះតែម្តង ឬក៏មកនៅនោះ?

យឹម ៖ បាទ! មកនៅខានោះ ។

បូលី ៖ ជិតផ្សារ?

យឹម ៖ អានេះខ្ញុំមកនៅនេះ

បូលី ៖ មកដល់ដំបូងត្រពាំងប្រាសាទ មានភូមិ មានមនុស្សរស់នៅ?

យឹម ៖ ដូចខ្ញុំថាចឹង អត់មានទេ ។ មានតែបងប្អូនជនពិការ គេមួយក្រុមមកនៅឯនេះ នៅមាត់ត្រពាំងនោះឯង ។

បូលី ៖ មាត់ត្រពាំងក្បែរអាប្រាសាទចាស់មែនទេ?

យឹម ៖ បាទ! នៅក្បែរប្រាសាទចាស់ជិតសាលាស្រុក ។
បូលី ៖ ជិតសាលាស្រុកហ្នឹងហេ៎?
យឹម ៖ បាទ! ជិតសាលាស្រុក និងហើយពួកគាត់ ។
បូលី ៖ អត់ទាន់មានជាភូមិឃុំអីទេ?
យឹម ៖ អត់ទាន់មានទេ សុទ្ធតែព្រៃ ព្រៃសុទ្ធតែម្តង ។
បូលី ៖ ពីណា បានប៉ុន្មានភូមិៗ ។
យឹម ៖ ខ្ញុំកងពល ទាំងអស់
បូលី ៖ ៨០២ហ្នឹងហេ៎?
យឹម ៖ ៨០២ហ្នឹង ។
បូលី ៖ យើងហៅភូមិអីដំបូងបំផុត?
យឹម ៖ កាលហ្នឹងមិនទាន់ហៅផង ហោ!
បូលី ៖ ៨០២?
យឹម ៖ ៨០២! គ្រាន់តែឈ្មោះ ដាក់ត្រពាំងប្រាសាទ ដែលក្រោយមកបានរៀបចំទៅជាឃុំត្រពាំងប្រាសាទ ។
បូលី ៖ ពីណារៀបចំ?
យឹម ៖ តារៀបចំ?
បូលី ៖ តាម៉ុកហេ៎?
យឹម ៖ បាទ! ខ្សែកងពល៨០២ហ្នឹង ដាក់ឃុំត្រពាំងប្រាសាទ ។ ចំនុះឲ្យត្រពាំងប្រាសាទ ចំនុះឲ្យស្រុកអន្លង់វែង ។
បូលី ៖ អត់ទាន់មានស្រុកត្រពាំងប្រាសាទទេ?
យឹម ៖ បាទ! នៅទេ ។
បូលី ៖ ចុះតា០៥ គាត់នៅណាវិញ?
យឹម ៖ តា០៥ គាត់នៅទំនប់ដាច់ ។
បូលី ៖ អាហ្នឹងឃុំដែរអត់ទេ?
យឹម ៖ អាហ្នឹងឃុំទំនប់ដាច់ ។ របស់កងពល៨០២ ។
បូលី ៖ ៨០១ហេ៎?
យឹម ៖ បាទ!

បូលី ៖ហ៊ូ!មែនវឡូចិន ។

ប្រពន្ធយឹម ៖ ចិន ។

យឹម ៖ អានេះនៅថ្មីតាអឹ?

ប្រពន្ធយឹម ៖ វឡូចិន កាដុផចិន!

បូលី ៖ មានកាដុនដែរអឹ?

យឹម ៖ មានតាយកតាដុផមួយមកទៀតមក ។

បូលី ៖ សុំមើលញកាដុផតិចមើលអឹ ។ អឹអត់ប្រើទេអី បានសុទ្ធតែពីផពាផចឹផ?

យឹម ៖ អត់ប្រើ! ទុកក្រែផលោមានវល់អី វត់ទៅនេះទៅនោះអី ទុកដាក់អីវ៉ានស្ពាយទៀត ព្រោះអាហ្នឹផស្ពាយស្រួលណា ។

បូលី ៖ បាទ! ប៉ុនរបស់ខ្ញុំដែរ មើលទៅ ។

យឹម ៖ ខ្ញុំសមរភូមិនៅនេះឯផ ខោអាវ ។

បូលី ៖ ធនអានេះដាប់ហ៉ា!

យឹម ៖ ហើយធានាទឹកភ្លៀផទៀត ។

បូលី ៖ អ៊ូ! មែនាវ៉ាមានអាកៅស៊ូពីក្នុផ ។

យឹម ៖ អត់ព្រួយថាទឹកចូលទេ ឲ្យតែយើផចផបានល្អ កុំឲ្យតែយើផថាទៅគឺ ។

បូលី ៖ អានេះនៅថ្មី ។ ខ្ញុំសុំចែកគេពីអន្លង់វែផមក វ៉ាវាផចាស់ៗ រហែកនេះបន្តិច ។

យឹម ៖ រហែកអាហ្នឹផយើផ វ៉ាចាស់ដែរហើយ ។

បូលី ៖ វ៉ាយូរណាស់ហើយ ។

យឹម ៖ កូនចផ់ប្រើដែរ តែខ្ញុំថាអត់ឲ្យប្រើ! ទុកវ៉ា ។ វ៉ាផចផ់ប្រើទៅទីនេះទីនោះអី ដាកលនេះដាក់នោះស្ពាយ ។

បូលី ៖ សម័យនេះហើយ ស្ពាយអានេះ?

យឹម ៖ ទេ! ពេលយើផទៅចម្ការហើយទេ ។ ចផ់ប្រើ ខ្ញុំថាមិនបាច់ប្រើ វែកផយើផទៅនេះទៅនោះស្រណុកដាក់ឥវ៉ាន់ស្ពាយ ។

បូលី ៖ អាលូវគេមានលក់ដែរតា អាប្រភេទចឹផ?

យឹម ៖ មានដែរ?

បូលី ៖ មានតានៅផ្សារ ។

យឹម ៖ តែអត់សុទ្ធដូចរបស់អានេះទេអី?

បូលី ៖ ខ្ញុំថាវាមិនមែនរបស់សល់ពីសម័យសង្គ្រាម អាចមាំជាងហ្នឹងក៏មានដែរអី ប៉ុនក្រែងវាមិនមែនជារបស់សល់ពីសង្គ្រាម ។ អានេះវាអនុស្សាវរីយ សល់ពីសង្គ្រាម ។

យឹម ៖ នៅខាងហ្នឹង នៅតា អ៊ូ! នោះឆ្នាំង ។

បូលី ៖ មានឆ្នាំងតាម៉ុកចែកឲ្យដែរ?

យឹម ៖ កម្ររមានដែរ អាឆ្នាំងចិនណា!

ប្រពន្ធយឹម ៖ អាឆ្នាំងវឡូចិនទាំងអស់ហ្នឹង ។

បូលី ៖ ហ៊ូ!នេះ អត់ដែលប្រើទេ ទុកចោលតែម្ដង?

ប្រពន្ធយឹម ៖ ទុកចោល តែចាស់យកចាក់ឆ្នាំងហើយ ។

បូលី ៖ ចាក់ឆ្នាំងយ៉ាងម៉េចទៅ?

ប្រពន្ធយឹម ៖ ចាក់ឆ្នាំងដាំបាយយើងល្អណាស់ ។

បូលី ៖ យកទៅរំលាយវា?

ប្រពន្ធយឹម ៖ រំលាយ! ចាក់ឆ្នាំង ទៅដែកវាអត់ច្រែះអត់អីទេ អាហ្នឹងអាតូចអានោះអាធំ ។

យឹម ៖ អាហ្នឹងកាលបីជំនាន់នោះឯងហ្នឹង ។

បូលី ៖ ជំនាន់តាម៉ុកនោះ?

យឹម ៖ ជំនាន់យើងតស៊ូ តស៊ូរបស់តាប៉ុលពត ។

ប្រពន្ធយឹម ៖ អានោះមួយទៀត អាឆ្នាំងដាប់ៗណា ។

បូលី ៖ ដាក់ក្រោមសិនទៅណាអី ចាំខ្ញុំមើល ។ អឹបើអឹមិនយល់ទាស់ទេ សុំចែក ។

យឹម ៖ ចង់បានយកទៅចុះ ។

ប្រពន្ធយឹម ៖ ខ្ញុំពាក់ចោលអត់ឃើញ ។

យឹម ៖ អត់មានប្រើអីផង ។

បូលី ៖ សុំចែកអាហ្នឹងមួយយកទៅទុកមើល ។

យឹម ៖ យកទៅ!

បូលី ៖ ចុះអានេះសុំចែកបានទេអី?

យឹម ៖ មានអីយកទៅចុះ ។

បូលី ៖ អឹចែកឲ្យមែន?

យឹម ៖ បាទ!

បូលី ៖ ដាក់ជូនអឹ២ ទៅ៣ម៉ឺន ។

យឹម : យកទៅ! យកទៅទុក ។

បូលី : ដាក់សារមន្ទីរ ។

យឹម : ខ្ញុំនៅ១ទៀត ។

បូលី : ហ៊ូចឹងអឺ សុំថែក១ ស្មានតាអឺ!

យឹម : ពួកនេះគ្មានដឹងអីទេ កើតមិនទាន់អីទេ ។ មិនបាច់លុយ មិនបាច់កាក់អីទេ ។

បូលី : អត់ទេអឺ សុំថែក អឺ ។

យឹម : អត់ទេ! យកទៅ ។

បូលី : ខ្ញុំដូចជាអស់សំនួរអីហើយអឺ!ចង់ដឹងមែនទែន ចង់ដឹងជីវិតរស់នៅលើភ្នំហ្នឹងឯង ថាតើយើងតស៊ូយ៉ាងម៉េច អីយ៉ាងម៉េច ហើយព័ត៌មានដែលខ្ញុំយកទៅនេះ គឺជាបម្រើឲ្យការអប់រំ ។ សៀវភៅនេះ គេដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រដ្ឋឲ្យក្មេងរៀន កុំឲ្យក្មេងវាភ្លេចព្រឹត្តិការណ៍របស់យើង ។

យឹម : មែនហើយត្រូវ រំឭកគាត់នោះណា ។

បូលី : ហើយខ្ញុំចង់បាន ដមណឹងពីឈូករុនអីហ្នឹង គឺខ្ញុំចង់បានដៅនៅក្នុងចំណុចដែនទីនេះ ដើម្បីលើក្រោយ!

យឹម : ម្ដុំនេះបើល្អ បានជួបជាមួយហ្នឹងបង ចាន់ ស៊ិន ហើយនៅ?

បូលី : ចាន់ ស៊ិន ជួបនៅ?

យឹម : ក្រុមប្រឹក្សាស្រុកដែរណា! ព្រោះគាត់នៅហ្នឹង គាត់កងពលតាហឿនហ្នឹងឯង ។ តា ចាន់ស៊ិនហ្នឹង នៅជិតផ្សារហ្នឹង ។

វណ្ណៈ : បាទ! ច្រើនម៉ោងដែរ ។

យឹម : ចឹង! គាត់នៅល្អិត ។

បូលី : ដូចកូនក្មេង!

យឹម : បាទ! នោះហើយកូនក្មេង ។ នៅកន្លែងវង្វង់មូលតិច ។

ប្រពន្ធយឹម : គាត់អត់ចាស់ទេ តែប៉ុណ្ណឹង តាំងពីសម័យសង្គ្រាម ។

វណ្ណៈ : អាយុ៦០ជាងហើយ ៦៨ ។

ប្រពន្ធយឹម : គាត់បងពួកខ្ញុំ ៣ទៅ៤ឆ្នាំ ។ កាលនោះគាត់នៅហ្នឹងឯង នៅឈូករុននោះតែម្ដងផ្ទះគាត់នោះនៅនោះឯង ។

វណ្ណៈ : បាទ! គាត់ធូរធាររបស់គាត់ ។

យឹម ៖ ខ្ញុំមកផ្កាច់ខ្លួនហើយ ហើយមេឃុំនោះគេបាន ប្រហែលជា១ឆ្នាំ ២ ។ សូម្បីតែដីផ្សារមួយចង្អោមក៏មិនយកដែរ ។

យឹម ៖ ពេលមេឃុំ២០០២នេះ ជាមេឃុំតាំងបីយើងតស៊ូ ។ តាំងពី៩៣ ទៅ៩!

«ចប់»